

ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត

- មិនស្គាល់ប្រវត្តិសាស្ត្រ
- ការបង្កើតការទទួលខុសត្រូវសម្រាប់មេដឹកនាំខ្មែរក្រហមចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិ

[illegible]

លេខ ៦០ ខែធ្នូ ឆ្នាំ២០០៤

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៦១ ខែមករា ឆ្នាំ២០០៥


## មាតិកា


◆ សំបុត្រ ៖ មិនស្គាល់ប្រវត្តិសាស្ត្រ ....................................... ១

**ផ្នែកឯកសារ**

◆ តូច ខាំឡឿន ........................................................................ ៤

◆ ញត្តិគាំទ្រសេចក្ដីសម្រេចចិត្ត .............................................. ៨

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ ....... ១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ហ៊ុន ឃួន ........................................................... ១២

◆ ស្លាប់ដោយសារមានកំណើតជាខ្មែរក្រោម ............................ ១៥

◆ ហេតុអ្វីខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម្ល៉េះ? ...................... ១៧

**ផ្នែកច្បាប់**

◆ ការបង្កើតការទទួលខុសត្រូវសម្រាប់មេដឹកនាំខ្មែរក្រហម ......... ២៥

**វេទិកាពិភាក្សាសាធារណៈ**

◆ តើសាលាជំនុំជម្រះក្ដីមេដឹកនាំខ្មែរក្រហម ............................. ៣៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ជីវិតក្នុងភាពនឹងថ្កល់ ............................................... ៥០




ស៊ឹម, ជីដូនរបស់ ស្រ៊ិន សុង និង ទូច ថតប្រហែលក្នុងឆ្នាំ១៩៧៥ ។ ដកស្រង់ចេញពីសៀវភៅ "ជីវិតក្នុងភាពនឹងថ្កល់" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។



បាន សាភ៉ាត (រូបទីពីររាប់ពីខាងស្ដាំ) ប្អូនស្រីរបស់ បាន សាវឿន ថតនៅសៀមរាប ឆ្នាំ១៩៦០


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះៈ** យិន នាន, ឡុង ដានី, ម៉ូង សាន់ឃីស, ដារីដ ច័យ **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូ ហ្វារីណ **អ្នកបកប្រែៈ** ដាត រចនា, ជី ទេវិទ្ធិ **និពន្ធនាយករងៈ** សាន់ កល្យាណ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# មិនស្គាល់ប្រវត្តិសាស្ត្រ

នៅដើមខែមករាឆ្នាំ២០០៥នេះ ក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុករៀបចំការងារសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម បាននាំអ្នកយកពត៌មានក្នុងស្រុកមួយក្រុមមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ គោលបំណងនៃទស្សនកិច្ចនេះគឺដើម្បីស្វែងយល់ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាបានសិក្សាស្រាវជ្រាវនិងតម្កល់ទុកឯកសារដោយរបៀបណាសម្រាប់បម្រើដល់សាធារណជនទូទៅនិងសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនាពេលខាងមុខនេះ ។ នៅក្នុងដំណើរទស្សនកិច្ចនេះ អ្នកយកពត៌មានបានសួរសំណួរជាច្រើនទាក់ទងទៅនឹងការរៀបចំឯកសារ ។ ក្រៅពីនេះមានសំណួរពីរដែលទាក់ទងទៅនឹងមេដឹកនាំខ្មែរក្រហម គឺសមមិត្ត អៀង សារី និងសមមិត្ត នួន ជា ។



*សមមិត្ត អៀង សារី*

អ្នកយកសារពត៌មានម្នាក់បានសួរខ្ញុំថាតើខ្ញុំមានប្រតិកម្មយ៉ាងដូចម្តេចចំពោះសម្តីរបស់សមមិត្ត អៀង សារី ដែលបាននិយាយថា យុវជនយុវនារីជំនាន់ក្រោយដែលមានរូបខ្ញុំដែរនោះមិនស្គាល់ប្រវត្តិសាស្ត្រ (ខ្មែរក្រហម) ទេ? ខ្ញុំបានឆ្លើយថា សមមិត្ត អៀង សារី និយាយនេះពិតជាត្រឹមត្រូវណាស់ ព្រោះយុវជនយុវនារីទាំងអស់ដែលកើតក្រោយរបបខ្មែរក្រហមព្រមទាំងរូបខ្ញុំដែលនៅពេលនោះនៅជាក្មេងជំទង់នៅឡើយពិតជាមិនស្គាល់និងមិនយល់អំពីបដិវត្តន៍របស់ខ្មែរក្រហមទេ ។ ទន្ទឹមនឹងនោះដែរ យុវជនយុវនារីនិងរូបខ្ញុំដែលជាក្មេងជំនាន់ក្រោយពិតជាពុំបានចូលរួមចំណែកបន្តវិនាសកម្មដល់កម្ពុជាដូចសមមិត្ត អៀង សារី, ពិតជាពុំបានចូលរួមចំណែកដឹកនាំប្រទេសដែលបានធ្វើឲ្យប្រជាជនរាប់លាននាក់ស្លាប់ដោយសារការខ្វះអាហារ ថ្នាំពេទ្យ បង្ខំឲ្យធ្វើការនិងសម្លាប់ចោល ដូចសមមិត្ត អៀង សារី, ពិតជាពុំបានប្រព្រឹត្តអំពើពុករលួយ កេងប្រវ័ញ្ចលើភាពក្រីក្ររបស់ប្រជាជនកម្ពុជាដូចសមមិត្ត អៀង សារី នោះទេ ។

សមមិត្ត អៀង សារី នៅតែជាមេដឹកនាំខ្មែរក្រហមម្នាក់ដែលមិនស្គាល់អ្វីទៅដែលហៅថាការពិត និងអ្វីទៅដែលហៅថាប្រវត្តិសាស្ត្រ ។ ប្រវត្តិសាស្ត្រគឺមានន័យថា “អ្វីដែលមនុស្សដឹងដោយការសួរ” ។ យុវជនយុវនារីនិងរូបខ្ញុំបានសួរអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម និងបានដឹងច្បាស់អំពីចម្លើយ ហើយចងក្រងចម្លើយទាំងនោះដោយផ្ទាល់ ។ ការប្រមូលចងក្រងរបៀបនេះគឺជាការចងក្រងនូវការពិត ។ ការពិតនោះគឺថា ប្រជាជនកម្ពុជានិងសកលលោកទាំងមូលបានដឹងថាមានរបបខ្មែរក្រហមនៅកម្ពុជាដែលបានធ្វើឲ្យមនុស្សស្លាប់យ៉ាងច្រើនបំផុតនៅលើសកលលោកបើប្រៀបធៀបទៅនឹងរបបដទៃទៀតក្នុងសតវត្សរ៍ទី២០ ។ កម្ពុជានិងពិភពលោកក៏បានដឹងទៀតថា សមមិត្ត អៀង សារី គឺជាមេដឹកនាំខ្មែរក្រហមម្នាក់ដែលត្រូវបានរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាយកមកកាត់ទោសប្រហារជីវិតដោយកំបាំងមុខពីបទធ្វើឲ្យមានរបបប្រល័យពូជសាសន៍នៅកម្ពុជា ។ ទាំងអស់ខាងលើនេះគឺជាប្រវត្តិសាស្ត្រនិងជាការពិតដែលយុវជនយុវនារីជំនាន់ក្រោយនិងរូបខ្ញុំបានរកឃើញតាមការសាកសួរ ។

ខ្ញុំសង្ឃឹមថាសមមិត្ត អៀង សារី នឹងចូលខ្លួនមកឆ្លើយបំភ្លឺនៅចំពោះមុខតុលាការនិងប្រជាជនកម្ពុជា ។ ក៏ប៉ុន្តែ មុននឹងដំណើរការរបស់តុលាការឈានមកដល់ ខ្ញុំសង្ឃឹមថាសមមិត្ត អៀង សារី នឹងឆ្លើយបំភ្លឺចំពោះខ្លួនឯងជាមុនសិន ហើយគួរបញ្ឈប់ការប្រើប្រាស់អតីតកងទ័ពខ្មែរក្រហមផ្តាច់ខ្លួនតូចតាចជារបាំងការពារទង្វើរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទៀត ។ **ឆាំង យុ**



# សមមិត្ត អៀង សារី និងមេដឹកនាំចិន
# នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ







*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# តួច ខាំឌឿន



តួច ខាំឌឿន ហៅ តួច ជាអតីតមន្ត្រីក្រសួងការបរទេសប្រចាំនៅប្រទេសគុយបានិងទីក្រុងប៉េកាំង ។ ជួន សូភាស៊ី ជាភ្នាក់ងារសេ.អ៊ី.អា និង អូវែរតុន ជាគ្រូបង្រៀនផ្នែកភាសាអង់គ្លេស បានឃោសនាអំពីភាពអស្ចារ្យរបស់សេ.អ៊ី.អា ហើយបញ្ចុះបញ្ចូល ខាំឌឿន ឲ្យចូលជាសមាជិករបស់ខ្លួន ។ ខាំឌឿន បានសម្រេចចិត្តចូលបម្រើសេ.អ៊ី.អា នៅពេលគាត់កំពុងរៀននៅវិទ្យាល័យស៊ីសុវត្ថិនៅឡើយ ។ នៅឆ្នាំ១៩៥៤ ខាំឌឿន បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង ។ នៅពាក់កណ្តាលឆ្នាំ១៩៥៨ ដោយមានការគាំទ្រពីនិស្សិតខ្មែរនិងភ្នាក់ងារកាហ្សេបេនៅប្រទេសបារាំង ខាំឌឿន បានជាប់ឆ្នោតជាប្រធានសហភាពនិស្សិតខ្មែរ ។ នៅពេលត្រឡប់មកប្រទេសកម្ពុជានាចុងឆ្នាំ១៩៧៥ ខាំឌឿន បានចូលក្រុមស៨០៨ (ក្រុមប្រឆាំងនឹងនយោបាយខ្មែរក្រហម) ដែលមានភិន ជាប្រធាន ។ រហូតដល់ថ្ងៃទី១៣ ខែ៤ ឆ្នាំ១៩៧៧ ខាំឌឿន ត្រូវអង្គការចាប់ខ្លួន ហើយបញ្ជូនមកមន្ទីរឃុំឃាំង ស-២១ នៅថ្ងៃទី៦ ខែ៥ ឆ្នាំ១៩៧៧ ។

នៅឆ្នាំ១៩៥៣ ខាំឌឿន រៀនថ្នាក់ទីបញ្ចប់នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។ ជនជាតិអាមេរិកាំងម្នាក់ឈ្មោះ អូវែរតុន ជាគ្រូបង្រៀនផ្នែកភាសាអង់គ្លេសនៅថ្នាក់របស់ ខាំឌឿន បានឃោសនាប្រាប់សិស្សអំពីភាពជឿនលឿនរបស់លោកសេរី ។ នៅខែ៤ ឆ្នាំ១៩៥៤ ជួន សូភាស៊ី បញ្ចុះបញ្ចូល ខាំឌឿន ឲ្យធ្វើជាភ្នាក់ងារសេ.អ៊ី.អាដោយសន្យាឧបត្ថម្ភដល់ការរៀនសូត្រនិងជួយរកការងារឲ្យធ្វើ ។ អូវែរតុន បានបញ្ចូល ខាំឌឿន និងសិស្សភាសាអង់គ្លេស៤នាក់ទៀត ជាសេ.អ៊ី.អានៅកន្លែងបេសកកម្មអេវ៉ង់សេលិស្តអាមេរិកាំង (នៅជិតវិទ្យាល័យព្រះស៊ីសុវត្ថិ) ហើយសន្យាឲ្យប្រាក់ខែ៥០០រៀលក្នុងមួយខែ បន្ទាប់មកក៏បញ្ជា ខាំឌឿន ឲ្យបំផុសបំផុលសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិឲ្យកោតសរសើរសហរដ្ឋអាមេរិកនិងពង្រីកខ្សែសេ.អ៊ី.អានៅក្នុងវិទ្យាល័យ ព្រមទាំងទប់ទល់មិនឲ្យមានឥទ្ធិពលកុម្មុយនិស្តក្នុងចំណោមនិស្សិត ។ នៅឆ្នាំដដែល ខាំឌឿន និង ជួន សូភាស៊ី អប់រំនិងបញ្ចូលសិស្ស៧នាក់ជាសមាជិកសេ.អ៊ី.អា ហើយសមាជិកទាំងនោះបានបន្តអូសទាញសិស្សឯទៀតជាបន្តបន្ទាប់ ។

ខាំឌឿន បានយកទស្សនាវដ្តីលោកសេរីមកពន្យល់សិស្សរួមថ្នាក់ហើយបបួលសិស្សទាំងនោះទៅមើលកាសែតរូបថតនៅការិយាល័យឃោសនាអាមេរិកាំង ហើយយករូបភាពនិងអត្ថបទប្រឆាំងកុម្មុយនិស្តនៅក្នុងទស្សនាវដ្តីលោកសេរីមកបំភ័យកុម្មុយនិស្តវិញ ។ ខាំឌឿន បានយកការណ៍ក្នុងចំណោមអ្នកដឹកនាំសិស្សវិទ្យាល័យដើម្បីឲ្យដឹងពីគោលបំណងពិតប្រាកដរបស់ "សិស្សសភា" ។ ដោយមានការជួយគាំទ្រពីមិត្តភក្តិជិតស្និទ្ធ ខាំឌឿន បានដឹងពីទិសដៅពិតប្រាកដរបស់សិស្សសភាគឺមិនមែនប្រជុំគ្នាដោះស្រាយជីវភាពសិស្សទេ ប៉ុន្តែបែរជាទិតៀនរិះគន់បញ្ឆិតបញ្ឆៀងសម្តេច សីហនុ និងរបបរបស់ព្រះអង្គទៅវិញ ។ ជួន សូភាស៊ី ប្រាប់ឲ្យ ខាំឌឿន រកវិធីទប់ស្កាត់បញ្ហានេះ ។

បន្ទាប់មក ក្នុងផែនការរបស់ចក្រពត្តិអាមេរិកចូលមកជំនួសបារាំងនៅកម្ពុជា អូវែរតុន បានគ្រោងរៀបចំមហាបាតុកម្មមួយដែលធ្វើឡើងដោយសិស្សានុសិស្សនៅខែ៤ ឆ្នាំ១៩៥៤ ដើម្បីប្រឆាំងវៀតមិញនិងបារាំង ។ ជាងនេះទៅទៀតដើម្បីឲ្យឆាកអន្តរជាតិកាន់តែចាប់អារម្មណ៍មកលើតួនាទីសំខាន់របស់យុវជនខ្មែរ និងដើម្បីជំរុញឲ្យអាមេរិកមកគ្រប់គ្រងកម្ពុជាជំនួសបារាំង អូវែរតុន បានផ្សព្វផ្សាយអំពីបាតុកម្មទៅដល់អន្តរជាតិ ។ អូវែរតុន បានតែងតាំង ជួន សូភាស៊ី ជាប្រធានគណៈកម្មការបាតុកម្ម, លឹម ស៊ីសាអាត និង វង់ សាវ៉ាន់ឌី ជាសមាជិក, សៅ ង៉ុយ ជាអ្នកទទួលខុសត្រូវខាងសន្តិសុខ, អ៊ុល ថុន ជាអ្នកទទួលខុសត្រូវខាងសម្ភារនិងស្បៀងសម្រាប់បាតុករ, កេង វ៉ាន់សាក់ មានភារកិច្ច

លើកទឹកចិត្តសិស្សឲ្យចូលរួមបាតុកម្ម ហើយចំណែក ខាំ ខឿន ទទួលខុសត្រូវខាងកៀងគរសិស្សានុសិស្ស ពិសេសពន្យល់អ្នកដឹកនាំសិស្សសភាឲ្យចូលរួមធ្វើបាតុកម្ម ។ ខាំ ខឿន បានទាក់ទងសមាគមសិស្សសាលាវិសុករសាធារណៈដែលមានខ្មែរសេ.អុី.អាមួយចំនួនបង្កប់នៅក្នុងនោះ ដើម្បីអូសទាញសិស្សឲ្យចូលរួមធ្វើបាតុកម្ម ។ កេង វ៉ាន់សាក់ បានជំទាស់បាតុកម្មនេះ ទោះបីជា ខាំ ខឿន ព្យាយាមបញ្ចុះបញ្ចូលនិងស្នើសុំមិនឲ្យមានការប្រឆាំងសម្តេច សីហនុ ក៏ដោយ ក៏ កេង វ៉ាន់សាក់, សៅ ង៉ុយ, ដុង សាញ, ស៊ឹម ញ៉ុក នៅតែមិនព្រម ជាហេតុបណ្តាលឲ្យមានទំនាស់គ្នា ។ ដោយខ្លាចបែកការណ៍និងប៉ះពាល់ដល់ប្រយោជន៍ធំ អូវ៉ែរគុន បានសម្រេចចិត្តរំលាយផែនការធ្វើបាតុកម្មនោះចោល ។

អូវ៉ែរគុន បានបញ្ជាឲ្យសេ.អុី.អាទាំង៣ក្រុមនៅវិទ្យាល័យព្រះស៊ីសុវត្ថិ គាំទ្រអស់ពីចិត្តពីថ្លើមនូវចលនាជីវពលដែលបង្កើតឡើងដោយសម្តេច សីហនុ ដើម្បីប្រឆាំងនឹងអ្នកតស៊ូដោយអាវុធទាមទារឯករាជ្យ ។ ជួន សូភាស៊ី បានចាត់ ខាំ ខឿន និងបក្សពួកទៅបបួលសិស្សឯទៀតៗឲ្យចូលរៀនហាត់ដើរស្ពាយកាំភ្លើងឈើនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិដែលរៀបចំឡើងដោយសម្តេច សីហនុ ។ ឯកសណ្ឋាននិងស្បែកជើងទាហានត្រូវបានផ្តល់ឲ្យដោយការិយាល័យឃោសនាអាមេរិកាំង ។

អូវ៉ែរគុន ណែនាំឲ្យសិស្សថ្នាក់ទីបញ្ចប់ឈ្មោះ អៀវចុង, នរោត្តមបាឡី, កែម អេឌូអា, សួយ សំផន, សូ អេងដុន និង ខាំ ខឿន ចុះឈ្មោះចូលរៀននៅសាលាបង្រៀនបើកបរយន្តហោះយោធានៅប្រទេសបារាំង ។ ទាំង៦នាក់ទៅពិនិត្យសុខភាពនៅព្រៃនគរ ក្នុងចំណោមនោះ៥នាក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការរៀនបើកបរយន្តហោះ លើកលែងតែ ខាំ ខឿន ដែលមិនអាចចូលរៀនបាន ។

ក្រោយមក អូវ៉ែរគុន បានណែនាំ វង់ សារ៉ាន់ឌី និង ខាំ ខឿន ឲ្យចូលរៀននៅសាលាយោធាជើងទឹក (ព្រោះឃើញថាសាលានេះទើបតែបញ្ជូនសិស្សថ្នាក់ទីបញ្ចប់ទៅរៀននៅប្រទេសបារាំង) ។ ដោយយោងលើសុខភាពរាងកាយមិនអំណោយផល ខាំ ខឿន បានបដិសេធ ។ ដូច្នេះ អូវ៉ែរគុន បានប្រាប់ ខាំ ខឿន ថា ការងារសមរម្យសម្រាប់គាត់គឺធ្វើការក្នុងចំណោមនិស្សិតនៅប្រទេសបារាំង ។ គាត់ខិតខំរៀនសូត្ររហូតប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាកម្រិតII ហើយទទួលបានអាហារូបករណ៍ពីក្រសួងសិក្សាធិការជាតិទៅបន្តការសិក្សានៅប្រទេសបារាំង ។ មុនពេលចេញដំណើរទៅប្រទេសបារាំង អូវ៉ែរគុន បានហៅ ខាំ ខឿន មកជួបហើយប្រគល់ភារកិច្ចមួយចំនួនឲ្យធ្វើ គឺចូលក្នុងចំណោមនិស្សិតឆ្វេង (និស្សិតខ្មែរប្រឆាំងអាមេរិក) ដើម្បីឲ្យនិស្សិតទទួលស្គាល់ ខាំ ខឿន ថាជាមនុស្សចម្រើន ។ យ៉ាងយូរ៦ឆ្នាំ ត្រូវមានសញ្ញាបត្រធំៗមកជាមួយនៅពេលត្រឡប់មកប្រទេសវិញ និងត្រូវសម្របខ្លួនជាមួយនិស្សិតខាងឆ្វេងនៅឆ្នាំដំបូង ហើយអូសទាញនិស្សិតទាំងនោះឲ្យគិតតែប្រយោជន៍ផ្ទាល់ខ្លួន ។ អូវ៉ែរគុន បានប្រាប់ទៀតថា និស្សិតខាងឆ្វេងមានចំនួនច្រើនជាងនិស្សិតស្តាំ (និស្សិតគាំទ្រអាមេរិក) ហើយកំពុងមានសកម្មភាពប្រឆាំងនឹងអាណានិគមបារាំងនិងអាមេរិកាំង ហើយមួយចំនួនចាប់ផ្តើមរៀនលទ្ធិម៉ាក្សលេនីន ។ អាមេរិកបានប្រើប្រាស់និស្សិតខាងស្តាំឲ្យប្រឆាំងនឹងកុម្មុយនិស្តជាចំហ ។ អូវ៉ែរគុន បានប្រាប់ឲ្យ ខាំ ខឿន ខស្សាហ៍ពិភាក្សាជាមួយ គួច ភឿន ដែលជាបងប្រុសរបស់ ខាំ ខឿន និងទាក់ទងជាមួយជនជាតិអាមេរិកាំងម្នាក់ឈ្មោះ សុនរូបស្តូន ។

នៅចុងឆ្នាំ១៩៥៤ ខាំ ខឿន ធ្វើដំណើរទៅប្រទេសបារាំងជាមួយឈ្មោះ ឡុង ស៊ីផៃ ដែលត្រូវធ្វើការនៅក្នុងចំណោមនិស្សិតស្តាំ ហើយនិងស្នាក់នៅជាមួយ គួច ភឿន ជាបណ្តោះអាសន្ន ។ សុនរូបស្តូន ដែលជាអ្នកទាក់ទងខ្មែរសេ.អុី.អា និងនិស្សិតខ្មែរកំពុងរៀននៅប្រទេសបារាំង បានមកជួបនិងណែនាំ ខាំ ខឿន ឲ្យចូលក្រុមម៉ាក្សលេនីន ។

២សប្តាហ៍ក្រោយមក សុនរូបស្តូន បានប្រាប់ឲ្យគាត់ប្រញាប់ចូលក្នុងក្រុមម៉ាក្សលេនីនដើម្បីរារាំងនិស្សិតកុំឲ្យបះបោរប្រឆាំងនឹងអាមេរិក បន្ទាប់មកបានឲ្យប្រាក់៣០០គ្រណោតបារាំងទៅ ខាំ ខឿន ព្រមទាំងសន្យាបើកប្រាក់ឲ្យរៀងរាល់ខែ ។ ដោយមានការជួយជ្រោមជ្រែងពី គួច ភឿន, ខាំ ខឿន បានចូលក្នុងក្រុមម៉ាក្សលេនីននៅដើមឆ្នាំ១៩៥៥ ហើយសកម្មភាពដំបូងរបស់គាត់គឺប្រឆាំងយ៉ាងដាច់ខាតជាមួយបារាំង ហើយ

សរសើរអាមេរិកដែលបានផ្តល់ជំនួយឲ្យកម្ពុជា ។

ខាំ ខឿន រិតខំបង្វែរមតិនិស្សិតកុំឲ្យយកចិត្តទុកដាក់នឹងសេអាតូដែលបង្កើតឡើងដោយអាមេរិក ដោយយកលេសថា បើគ្មានកម្លាំងនិស្សិតចូលរួម ក៏មិនអាចទៅរួចដែរ ។ ខាំ ខឿន ពិគ្រោះជាមួយ តូច ភឿន ដើម្បីរកវិធីទប់ទល់នឹងចលនាប្រឆាំងអាមេរិកដែលចេះតែកើនច្រើនឡើងៗ ហើយរកវិធីឲ្យ អៀង សារី ឆាប់ចាកចេញពីប្រទេសបារាំង ។

នៅពាក់កណ្តាលឆ្នាំ១៩៥៦ ខាំ ខឿន បានប្រាប់និស្សិតកុំឲ្យមកចូលរួមប្រជុំដែលរៀបចំឡើយដោយក្រុមម៉ាក្ស-លេនីន ក្នុងគោលបំណងកុំឲ្យញត្តិដែលក្រុមម៉ាក្ស-លេនីនរៀបចំឡើងប្រឆាំងនឹងសន្ធិសញ្ញារវាងអាមេរិកនិងរដ្ឋាភិបាល សីហនុ ទទួលបានហត្ថលេខាច្រើនពីនិស្សិត ។ នៅឆ្នាំដដែលពេលដែលនិស្សិតខ្មែររៀបចំពិធីបុណ្យចូលឆ្នាំ ខាំ ខឿន បានយកពាក្យស្លោក “សន្តិភាព” ធ្វើជាប្រធានបទធំមួយក្នុងទិសដៅបន្សាបគោលជំហរប្រយុទ្ធរបស់និស្សិតដែលប្រឆាំងនឹងអាមេរិក ។

នៅចុងឆ្នាំ១៩៥៦ នៅពេល តូច ភឿន តម្រូវឲ្យត្រឡប់មកប្រទេសកម្ពុជាវិញបានផ្តាំ ខាំ ខឿន ឲ្យចៀសវាងការផ្ញើសំបុត្រមានទាក់ទងនឹងសេ.អ៊ី.អា ព្រោះខ្លាចបែកការណ៍ ។ ចាប់តាំងពី អៀង សារី ចាកចេញពីប្រទេសបារាំងនៅឆ្នាំ១៩៥៧ ខាំ ខឿន មានលទ្ធភាពធ្វើសកម្មភាពបង្ក្រាបក្រុមម៉ាក្ស-លេនីនកាន់តែខ្លាំងឡើង ។

នៅចុងឆ្នាំ១៩៥៧ សុនរូបស្តួន បានចាត់ឲ្យ ខាំ ខឿន ទៅចូលរួមមហោស្រពយុវជនសកលលោកដើម្បីមិត្តភាពនិងសន្តិភាពនៅទីក្រុងមូស្គូដែលរៀបចំឡើងដោយយុវជនសូវៀត ។ គោលបំណងនៃការចូលរួមនោះគឺដើម្បីឲ្យដឹងថាតើ យុវជនសូវៀតមានបញ្ចុះបញ្ចូលយុវជនតតិយលោកឲ្យប្រឆាំងអាមេរិកដែរឬអត់ ។ នៅពេលទៅដល់ទីនោះ ខាំ ខឿន និង ហ៊ីង អ៊ុន បានចូលជាសមាជិកគណៈប្រតិភូសហភាពនិស្សិតខ្មែរ ។ នៅពេលត្រឡប់មកវិញ ខាំ ខឿន បានរាយការណ៍ប្រាប់ សុនរូបស្តួន ថា យុវជនសូវៀតចង់ឲ្យយុវជនតតិយលោករួមរស់ដោយសន្តិភាពជាមួយយុវជនអាមេរិកាំង ។ នៅឆ្នាំ១៩៥៨ ខាំ ខឿន បានអំពាវនាវឲ្យនិស្សិតខ្មែរឈប់ប្រឆាំងសម្តេច សីហនុ ហើយគាត់បានធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយ“ចាងហ្វាងផ្ទះខ្មែរ” នៅប្រទេសបារាំង ។

ខាំ ខឿន បានឡើងធ្វើជាប្រធានសហភាពនិស្សិតខ្មែរនៅពាក់កណ្តាលឆ្នាំ១៩៥៨ ។ គាត់បានជួបប្រជុំជាមួយនិស្សិតខ្មែរដែលទើបមករៀននៅប្រទេសបារាំងមាន ហ៊ីង អ៊ុន, សួន កាសេត, ស៊ាម ប៉េងសាម, លី បាយស៊ី, ព្រំ ធុច, កុក សុកគឹម និង ធាន សំអាន ដើម្បីក្តាប់ឲ្យបាននូវផ្នែកសហភាពនិស្សិតខ្មែរនៅតាមខេត្តនៃប្រទេសបារាំង ប្រទេសបែលស៊ិក និងប្រទេសស៊ីលី ដើម្បីរក្សាឥទ្ធិពលសេ.អ៊ី.អា ។

នៅឆ្នាំ១៩៦០ ខាំ ខឿន បានរៀបចំរំលាយសហភាពនិស្សិតខ្មែរដើម្បីបញ្ចូលជាមួយអង្គការនិស្សិតដែលបង្កើតឡើងដោយសម្តេច សីហនុ វិញ ដោយលើកហេតុផលថា គាត់ចង់ពង្រីកចំណងសាមគ្គីភាពឲ្យបានធំទូលាយជាមួយសម្តេច សីហនុ ប៉ុន្តែផែនការនេះមិនអាចធ្វើទៅបានឡើយដោយសារមានការជំទាស់ពីនិស្សិតខ្មែរឯទៀត ។

នៅឆ្នាំដដែល ខាំ ខឿន ណែនាំនិស្សិតឲ្យគិតគូរតែពីហិរញ្ញវត្ថុ អាហារូបករណ៍ប៉ុណ្ណោះ ដើម្បីបង្កើនជីវភាពរស់នៅ ស្វែងរកភាពសប្បាយរបៀបអឺរ៉ុប និងស្វែងរករៀននៅសាលាធំៗ ។

នៅឆ្នាំ១៩៦១ ខាំ ខឿន បានបង្ខំឲ្យសហភាពនិស្សិតខ្មែរទទួលយកនិស្សិត ជុំ ស៊ីរ៉ាក់ ធ្វើជាគណៈកម្មាធិការនាយកសហភាពនិស្សិតខ្មែរ ហើយបានពន្យល់និស្សិតឲ្យចុះហត្ថលេខាលើញត្តិគាំទ្រឲ្យសម្តេច សីហនុ ធ្វើជាអ្នកដឹកនាំនយោបាយអព្យាក្រឹត ។

ខាំ ខឿន បានទាក់ទងនិស្សិតមួយចំនួនដែលទើបទៅដល់ប្រទេសបារាំងហើយបានឧបត្ថម្ភគាំទ្រនិស្សិតនិយមកណ្តាលដែលដឹកនាំដោយ ប៉ាវ មួយហាក់, អៀប ទីឡុង និង អ៊ុក វ៉ាន់ដេត រហូតដល់ក្រុមនេះអាចក្លាយទៅជាកម្លាំងប្រឆាំងបដិវត្តន៍ ។ នៅឆ្នាំដដែល សុនរូបស្តុន បានស្នើឲ្យ ខាំ ខឿន បន្តអប់រំនិស្សិតឆ្វេងតទៅទៀត កុំអាលត្រឡប់មកប្រទេសកម្ពុជា ព្រោះនិស្សិតខ្មែរនៅក្នុងសហភាព និស្សិតខ្មែរក្តី នៅក្នុងក្រុមម៉ាក្ស-លេនីនក្តី លែងជាអ្នកបដិវត្តន៍ដូចកាល អៀង សារី ឬ សុន សេន នៅគ្រប់គ្រងទៀតហើយ ។ ខាំ ខឿន ក៏សម្រេចចិត្តស្នាក់នៅបន្ត ។

## សកម្មភាពកាហ្សេបេ

នៅចុងឆ្នាំ១៩៦២ ខាំខឿន បានទៅចូលរួមមហាស្រពសកលលោកស្តីពីយុវជនដើម្បីមិត្តភាពសន្តិភាព នៅហែលស៊ិនគី ប្រទេសហ្វាំងឡង់ ។ នៅពេលត្រឡប់មកវិញ ខាំខឿន បានចូលរួមសមាជនៃសហភាពនិស្សិតអន្តរជាតិនៅក្រុងឡេនីនក្រាដសហភាពសូវៀត ។ លេខាកុំសូម៉ុលក្រុងឡេនីនក្រាដឈ្មោះ នីកូឡា ដែលធ្លាប់បានទទួលគណៈប្រតិភូសហភាពនិស្សិតខ្មែរនៅមូស្គូ ឆ្នាំ១៩៥៧ និងតំណាងម្នាក់មកពីក្រសួងសន្តិសុខសូវៀត បានមកជួប ខាំខឿន ហើយប្រាប់ថា ថ្ងៃក្រោយ វ៉ាស៊ីឡេវ តំណាងក្រសួងសន្តិសុខ នឹងមកធ្វើការងារជាមួយគាត់ ។ ដោយមានការខទ្វេសនាមរបស់ នីកូឡា និងទទួលស្គាល់ដោយ វ៉ាស៊ីឡេវ, ខាំខឿន បានចូលជាសមាជិកកិត្តិយសកាហ្សេបេបរទេសនៅទីស្នាក់ការក្រសួងសន្តិសុខនៃទីក្រុងលេនីនក្រាដ ហើយទទួលភារកិច្ចមួយចំនួនគឺ ទទួលស្គាល់និងការពារនយោបាយបក្សនិងរដ្ឋាភិបាលសូវៀតនិង "មហាគ្រួសារប្រទេសសង្គមនិយម" តស៊ូដណ្តើមយករដ្ឋអំណាចនៅកម្ពុជា ដើម្បីស្ថាបនាសង្គមនិយមតាមរបៀបប្រទេសនៅក្នុងមហាគ្រួសារសង្គមនិយម ព្រមទាំងរក្សាឲ្យបានគ្រប់ពេលវេលានូវមិត្តភាពនិងសហប្រតិបត្តិការជាមួយបក្ស រដ្ឋាភិបាល និងក្រសួងសន្តិសុខរបស់សូវៀត ។ វ៉ាស៊ីឡេវ បញ្ជាក់ថា សមាជិកកិត្តិយសកាហ្សេបេពុំមែនជាភ្នាក់ងារកាហ្សេបេធម្មតាទេ ។ កាហ្សេបេធម្មតាលុះត្រាតែជាជនជាតិរុស្ស៊ីហើយឆ្លងកាត់ការហ្វឹកហ្វឺនសាកល្បងក្នុងការស៊ើបអង្កេតយកពត៌មាន ។ កាហ្សេបេកិត្តិយសបរទេសគ្រាន់តែជាអ្នកនយោបាយដែលជាប់ខ្សែស្រឡាយខ្លះៗជាមួយក្រសួងសន្តិសុខសូវៀត និងទទួលការឧបត្ថម្ភពីក្រសួងនេះប៉ុណ្ណោះ ។ បន្ទាប់មក ខាំខឿន បានស្នើឲ្យបក្សនិងរដ្ឋាភិបាលសូវៀតជួយឧបត្ថម្ភនៅពេលគាត់ត្រូវការជំនួយផ្នែកហិរញ្ញវត្ថុនិងយោធាក្នុងការដណ្តើមអំណាចនៅកម្ពុជា ។

**(នៅមានត)** **សូ ហ្វារីណា**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងរៀបចំកម្មវិធី "វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេស ឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

- រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។
- ជាវិធីមួយដើម្បីរំសាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខការឈឺចាប់មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។
- ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។
- ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងការរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងពត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# ញត្តិគាំទ្រសេចក្តីសម្រេចចិត្តរបស់រដ្ឋសភា និងលិខិតចំហរបស់បញ្ញាជននិងបព្វជិតនៃក្រសួង-មន្ទីរជុំវិញមជ្ឈិម

| ល.រ | ក្រសួង-មន្ទីរ | ញត្តិ | តំណាងចូលរួម | ហត្ថលេខា |
|---|---|---|---|---|
| ១ | គណៈចាត់តាំងមជ្ឈិម | ១ | ៦៩ | ៦៩ |
| ២ | ក្រសួងយុត្តិធម៌ | ១ | ១០៦ | ១០៦ |
| ៣ | សង្គមកិច្ច | ៥ | ៧៥ | ៧៥ |
| ៤ | គណៈឃោសនាអប់រំមជ្ឈិម | ៣ | ២៣០ | ២៣០ |
| ៥ | ខុទ្ទកាល័យរដ្ឋសភា | ១ | ៣១ | ៣១ |
| ៦ | ធនាគារជាតិកម្ពុជា | ១ | ១៨៤ | ១៨៤ |
| ៧ | ត្រួតពិនិត្យកិច្ចការរដ្ឋ | ១ | ២១ | ២១ |
| ៨ | ក្រសួងកសិកម្ម | ១ | ១០ | ១០ |
| ៩ | សមាគមនារីមជ្ឈិម | ១ | ៣១ | ៣១ |
| ១០ | ក្រសួងអប់រំ | ២ | ១.០៨៨ | ១.០៨៨ |
| ១១ | ក្រុមប្រឹក្សារណសិរ្ស | ១ | ៨៩ | ៨៩ |
| ១២ | បញ្ញាជននិងបព្វជិត | ៦ | ៣០០ | ៣៥ |
| ១៣ | សមាគមយុវជន | ១ | ៣៤ | ៣៤ |
| ១៤ | តំណាងជនជាតិ | ១ | ១.០៧៣ | ១.០៧៣ |
| ១៥ | ពាណិជ្ជកម្ម | ១ | ៦.០៦៥ | ១៩ |
| ១៦ | គមនាគមន៍ | ១ | ១៤៤ | ១៤៤ |
| ១៧ | ការបរទេស | ១ | ៥៦៧ | ៥៦៧ |
| ១៨ | វិទ្យុ | ១ | ២១៥ | ២១៥ |
| ១៩ | ក្រុមប្រឹក្សារដ្ឋមន្ត្រី | ៦ | ១៨១ | ១៨១ |
| ២០ | អគ្គនាយកចម្ការកៅស៊ូ | ១ | | (គ្មានសំណៅហត្ថលេខា) |
| ២១ | ក្រុមប្រឹក្សារដ្ឋ | ១ | ៥២ | ៥២ |
| ២២ | អេស ប៉េ កា | ១ | ៦៨១ | ៥ |
| **សរុប** | **២២** | **៣៩** | **១០,៨១៦** | **៤,២៦៩** |

## ញត្តិគាំទ្រសេចក្តីសម្រេចចិត្តរបស់រដ្ឋសភា និងលិខិតចំហរបស់បញ្ញាជននិងបព្វជិតនៃខេត្ត-ក្រុងនានា

| ល.រ | ក្រសួង-មន្ទីរ | ញត្តិ | តំណាងចូលរួម | ហត្ថលេខា |
|---|---|---|---|---|
| ១ | ក្រុងកំពង់សោម | ៥ | ៩៩ | ៩.០៤៩ |
| ២ | កំពង់ធំ | ១៥០ | ១៨៥.២៨៧ | ៧៤.៥៣០ |
| ៣ | ស្វាយរៀង | ៦ | ១.៨៨៣ | ១.៨៦៣ |
| ៤ | កំពង់ឆ្នាំង | ៨០ | ៩.១៧០ | ១.៩៧០ |
| ៥ | សៀមរាប-ឧត្តរមានជ័យ | ១៦៥ | ៣៧.៩២៧ | ៣៥.១១១ |
| ៦ | កណ្តាល | ៨៦៥ | ១៨៣.៥៩៧ | ១៨៣.៥៩៧ |
| ៧ | ក្រចេះ | ១ | ១៣៤ | ១៣៤ |
| ៨ | កំពត | ៦៨៩ | ១៨៥.៥៥៤ | ១៨៥.៥៥៤ |
| ៩ | បាត់ដំបង (ខ្មែរអាត់ថតសំឡេង) | ១៧៦ | ៦២.៣៣២ | ៥.៩៣៣ |
| ១០ | ពោធិសាត់ | ៥២៥ | ៩១.៧៧៣ | ៩១.៧៧៣ |
| ១១ | កំពង់ស្ពឺ | ១ | ៧៥ | គ្មានសំណៅហត្ថលេខា |
| ១២ | តាកែវ | ៦.៩៣០ | ២៩៩.៨៥២ | ៦.៨១១ |
| **សរុប** | **១២ខេត្ត** | **៩,១៩៣** | **៩៧៧,៦៨៣** | **៥៥៥,៩២៥** |

បានឃើញនិងឯកភាព

ភ្នំពេញ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៨៣

ជ-ក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្ស សាមគ្គី

កសាងការពារមាតុភូមិកម្ពុជា, អនុប្រធានទទួលបន្ទុកអចិន្ត្រៃយ៍

**ម៉ែន ឆន**

ភ្នំពេញ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៨៣

ការិយាល័យសរុប

**ស្រ៊ុន ស៊ាងលីម**


ស៊ឹម ស៊ឹម

# សេចក្តីប្រកាសរកបងប្រុស

ខ្ញុំបាទឈ្មោះ ស៊ឹម ស៊ឹម ហៅ ស៊ឹម ហ៊ឹម សព្វថ្ងៃរស់នៅភូមិកំពង់ពោធិ ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ។ ខ្ញុំបាទមានបងប្អូនទាំងអស់៦នាក់ ១) ឈ្មោះ ស៊ឹម ស្រ៊ាន ២) ស៊ឹម ស្រន ៣) ស៊ឹម ស្រ៊ុន ៤) ស៊ឹម ស្រេម ៥) ស៊ឹម ស្រី និង៦) ស៊ឹម ស៊ឹម (ខ្ញុំបាទផ្ទាល់) ។

ខ្ញុំបាទសូមសួររកបងប្រុសឈ្មោះ សុម ស្រ៊ុន បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមាននាទីជាយុទ្ធជន ក្រោយមកបានបែកគ្នានៅភូមិពាមទោល ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល ។

បើសាមីខ្លួនទាំងពីរបានឮ ឬបងប្អូនណាបានស្គាល់ឈ្មោះខាងលើនេះ សូមទាក់ទងខ្ញុំបាទផ្ទាល់តាមទូរស័ព្ទលេខ ០១១ ៦៥១ ៧០១ ឬទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារលេខ ០២៣ ២១០ ៣៥៨ ឬតាមរយៈប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៧៨២ | ប៊ុន ហ៊ី ហៅ ឡាយ | ពេទ្យវរសេនាធំ | កងពល៣១០ | ១៥-១០-៧៦ | ១៨-៣-៧៧ |
| ១៧៨៣ | ព្រុំ ម៉ន ហៅ ឆួន | យោធាកងធំ | កងពល៣១០ | ១១-១២-៧៦ | ១៨-៣-៧៧ |
| ១៧៨៤ | អ៊ុម ម៉ុល ហៅ ថន | ប្រធានពេទ្យ | កងពល៣១០ | ១១-១២-៧៦ | ១៨-៣-៧៧ |
| ១៧៨៥ | ឈូក សយ ហៅ ផល | អនុនយោបាយ | កងពល៣១០ | ២០-៩-៧៦ | ១៨-៣-៧៧ |
| ១៧៨៦ | ហែម ញាណ ហៅ បុល | វរសេនាតូច | កងពល៣១០ | ២២-៩-៧៦ | ១៨-៣-៧៧ |
| ១៧៨៧ | អេង លី ហៅ ខែត | កងហ | កងពល៣១០ | ៥-១២-៧៦ | ១៨-៣-៧៧ |
| ១៧៨៨ | ពុង យួន ហៅ យឿម | កងធំ | កងពល៣១០ | ៤-១២-៧៦ | ១៨-៣-៧៧ |
| ១៧៨៩ | នូ សុផល ហៅ ជាតិ | សមាជិកកងធំ | កងពល៣១០ | ១១-១២-៧៦ | ១៨-៣-៧៧ |
| ១៧៩០ | ភោគ មឿន ហៅ ម៉ុន | អនុលេខាកងធំ | កងពល៣១០ | ១០-១២-៧៦ | ១៨-៣-៧៧ |
| ១៧៩១ | ជាម ជឿន ហៅ ឯក | បញ្ជាការវរសេនាតូច | កងពល៣១០ | ២២-៩-៧៦ | ១៨-៣-៧៧ |
| ១៧៩២ | អ៊ុក ញាណ ហៅ បុល | លេខាកងធំ | កងពល៩២០ | ២៨-១០-៧៦ | ១៨-៣-៧៧ |
| ១៧៩៣ | ជាម ខេង ហៅ ផល | យុទ្ធជន | កងពល១៦៤ | ១៨-១២-៧៦ | ១៨-៣-៧៧ |
| ១៧៩៤ | ព្រុំ ទឹម | ប្រធានកងហ | កងពល១៦៤ | ១៨-១២-៧៦ | ១៨-៣-៧៧ |
| ១៧៩៥ | ង៉ាន គីមស៊ាន (ស្រី) | ប្រធានកងធំ | សេនាធិការ | ២២-១០-៧៦ | ១៨-៣-៧៧ |
| ១៧៩៦ | ឈឿង ឱឈាង ហៅ ឱសា | ភ្នាក់ងារព័ត៌មាន | តំបន់១០៣ | ១៨-៩-៧៦ | ១៨-៣-៧៧ |
| ១៧៩៧ | សេង ស៊ឹម | កងផលិតតំបន់ | តំបន់១៥ | ៣០-៩-៧៦ | ១៨-៣-៧៧ |
| ១៧៩៨ | ដួង សាម | ជំនួយការតំបន់ | តំបន់១៥ | ១៤-១០-៧៦ | ១៨-៣-៧៧ |
| ១៧៩៩ | ប្រុក ហៃល | យុទ្ធជន | ពេទ្យ១៧ | ១៨-៩-៧៦ | ១៨-៣-៧៧ |
| ១៨០០ | ឃុន ឃិន ហៅ ជុំ ជឿន | សមាជិកឃុំ | តំបន់៣៣ | ៧-១០-៧៦ | ១៨-៣-៧៧ |
| ១៨០១ | កង ឆន ហៅ សេន | សហករណ៍ឃុំ | តំបន់៣៣ | ៨-១០-៧៦ | ១៨-៣-៧៧ |
| ១៨០២ | យ៉ាង ភឿង | ជាងរហាត់ស្រុក | តំបន់៣៣ | ៨-១០-៧៦ | ១៨-៣-៧៧ |
| ១៨០៣ | ពៅ រ៉ា | កម្មកររចាស់ | មន្ទីរឡានទឹក | ២៦-១២-៧៦ | ១៨-៣-៧៧ |
| ១៨០៤ | ហែម សុខុម | កម្មកររចាស់ | មន្ទីរឡានទឹក | ៣១-១-៧៧ | ១៨-៣-៧៧ |
| ១៨០៥ | នៅ សារឿន | កម្មកររចាស់ | មន្ទីរឡានទឹក | ២៥-១០-៧៦ | ១៨-៣-៧៧ |
| ១៨០៦ | សុក សឿង ហៅ មឿន | កម្មកររចាស់ | មន្ទីរឡានទឹក | ២៥-១០-៧៦ | ១៨-៣-៧៧ |
| ១៨០៧ | ម៉ៃ សុខុន ហៅ លំ | សមាជិកមន្ទីរ | មន្ទីរស-៨ | ១៧-១០-៧៦ | ១៨-៣-៧៧ |
| ១៨០៨ | យិន សុផាន់យ៉ា | កម្មកររចាស់ | ឡានទឹក | ២៦-១២-៧៦ | ១៨-៣-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ១៨០៩ | ពៅ ភន | កម្មករចាស់ | ឡានទឹក | ២៦-១២-៧៦ | ១៨-៣-៧៧ |
| ១៨១០ | ង៉ែត ម៉ន ហៅ សោម | កម្មករចាស់ | មន្ទីរ ស-៨ | ២៦-១២-៧៦ | ១៨-៣-៧៧ |
| ១៨១១ | គឹម សុខន | កម្មករចាស់ | មន្ទីរ ស-៨ | ២៨-១០-៧៦ | ១៨-៣-៧៧ |
| ១៨១២ | ថៅ សន | កម្មករឡានទឹក | មន្ទីរ ស-៨ | ២៨-១០-៧៦ | ១៨-៣-៧៧ |
| ១៨១៣ | ហោ មុយជា | កម្មករថ្មី | ដឹកជញ្ជូន | ២៣-៩-៧៦ | ១៨-៣-៧៧ |
| ១៨១៤ | មៀច ឆាយ ហៅ សាវុធ | យុទ្ធជន | រោងចក្រ គ-៥ | ២០-៤-៧៦ | ១៨-៣-៧៧ |
| ១៨១៥ | ឈិត ថេង ហៅ ថាំ | ឧស្សាហកម្ម | តំបន់៣៣ | ៧-១០-៧៦ | ១៨-៣-៧៧ |
| ១៨១៦ | ដាត ចាន់ថា ហៅ ដៃ | មេក្រុម | រោងចក្រ ដ-១ | ២៧-១០-៧៦ | ១៨-៣-៧៧ |
| ១៨១៧ | ដួន ហេង ហៅ សមិត្ត | កម្មករថ្មី | រោងចក្រ ច-១ | ?-១០-៧៦ | ១៨-៣-៧៧ |
| ១៨១៨ | កែវ សារី ហៅ មាស សំអុល | មេក្រុម | រោងចក្រកង់ឡាន | ១៦-១១-៧៦ | ១៨-៣-៧៧ |
| ១៨១៩ | ស៊ឹម សាវុង ហៅ កែវគុន | យុទ្ធជន | រោងចក្រស្រា | ១៦-១១-៧៦ | ១៨-៣-៧៧ |
| ១៨២០ | ប៉ែន ដេង ហៅ ទៀង (ស្រី) | មេក្រុម | រោងចក្រ ប-៤ | ២២-១០-៧៦ | ១៨-៣-៧៧ |
| ១៨២១ | ឈួន សារូ (ស្រី) | មេក្រុម | រោងចក្រ គ-៣ | ២៥-១១-៧៦ | ១៨-៣-៧៧ |
| ១៨២២ | ទូច យ៉យ ហៅ វណ្ណា (ស្រី) | មេក្រុម | រោងចក្រ គ-៤ | ២០-១០-៧៦ | ១៨-៣-៧៧ |
| ១៨២៣ | វង់ ហ៊ាង (ស្រី) | មេពួក | រោងចក្រ គ-២ | ២៥-១០-៧៦ | ១៨-៣-៧៧ |
| ១៨២៤ | កែវ ភាន (ស្រី) | អនុក្រុម | រោងចក្រ គ-៦ | ២០-១០-៧៦ | ១៨-៣-៧៧ |
| ១៨២៥ | យូ និល | យុទ្ធជន | រោងចក្រ ដ-២ | ១៩-១០-៧៦ | ១៨-៣-៧៧ |
| ១៨២៦ | គឹម ឆិល ហៅ ម៉ៅ | កម្មករចាស់ | រោងចក្រ ដ-៤ | ២០-១០-៧៦ | ១៨-៣-៧៧ |
| ១៨២៧ | គង់ កៀត ហៅ ឈឿន | ប្រធានផ្នែក | រោងចក្រកែវ | ១៤-១១-៧៦ | ១៨-៣-៧៧ |
| ១៨២៨ | ដូ ហុ | យុទ្ធជន | រោងចក្រ ដ-១ | ១០-១០-៧៦ | ១៨-៣-៧៧ |
| ១៨២៩ | ឯម សំរ៉ែង | កម្មករចាស់ | រោងចក្រ ប-៤ | ១៥-១០-៧៦ | ១៨-៣-៧៧ |
| ១៨៣០ | ជា ហ៊ុ ហៅ ហុក | យុទ្ធជន | រោងចក្រចាន | ៣០-១០-៧៦ | ១៨-៣-៧៧ |
| ១៨៣១ | ង៉ែត សារិន ហៅ ទូច | កម្មករអណ្តូងរ៉ែ | ស្ទឹងប្រាល | ៧-៩-៧៦ | ១៨-៣-៧៧ |
| ១៨៣២ | ហៃ គឹមស៊ាង ហៅ សុក | លេខាធិការទូត | ស្រុកបារាំង | ៨-១២-៧៦ | ១៨-៣-៧៧ |
| ១៨៣៣ | ម៉ែន មូនីង៉ាម | វេជ្ជបណ្ឌិត | មន្ទីរ ក-១៥ | ១២-១០-៧៦ | ១៨-៣-៧៧ |
| ១៨៣៤ | ទា ម៉េងគេក | គ្រូបង្រៀន | បឹងត្របែក | ១២-១២-៧៦ | ១៨-៣-៧៧ |
| ១៨៣៥ | សុក ចំណង់ | និស្សិតពេទ្យ | ស្ទឹងប្រាល | ៥-៩-៧៦ | ១៨-៣-៧៧ |
| ១៨៣៦ | រស់ សារិន ហៅ ម៉ៅ | ក្រុមហ៊ុនអាកាស | ស្រុកបារាំង | ១២-១២-៧៦ | ១៨-៣-៧៧ |
| ១៨៣៧ | នា គឹមស្រ៊ាង | និស្សិត | ស្រុកបារាំង | ២៣-១០-៧៦ | ១៨-៣-៧៧ |
| ១៨៣៨ | ឡាំ វីរី | វិស្វករ | សូវៀត | ១២-១០-៧៦ | ១៨-៣-៧៧ |
| ១៨៣៩ | ទៀង គីនី | និស្សិត | បឹងត្របែក | ១២-១២-៧៦ | ១៨-៣-៧៧ |

(នៅមានត)

# ហ៊ុន ឃួនៈ ក្នុងរបបខ្មែរក្រហមយើងធ្វើការងារច្រើនប៉ុន្តែហូបតិច

នៅក្នុងសម័យខ្មែរក្រហមមិនមែនមានតែប្រជាជនថ្មី (ប្រជាជន១៧មេសា) ទេដែលទទួលរងការលំបាក ការភ័យខ្លាច ភាពអត់ឃ្លាន ការនិរាសព្រាត់ប្រាស និងការបាត់បង់ជីវិត ។



ប្រជាជនមូលដ្ឋានជាច្រើននាក់ក៏ទទួលរងនូវបញ្ហានេះដូចគ្នាដែរ ។ ហ៊ុន ឃួន គឺជាប្រជាជនមូលដ្ឋាននៅឃុំឫស្សីស្រុកខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត ក៏មិនខុសពីប្រជាជនខ្មែរដទៃទៀតប៉ុន្មានដែរ ។ បងប្រុសរបស់គាត់៣នាក់បានចូលបម្រើបដិវត្តន៍ ក្នុងនោះពីរនាក់បានស្លាប់ ហើយម្នាក់ទៀតបាត់ខ្លួនរហូតដល់បច្ចុប្បន្ន ។

នៅឆ្នាំ១៩៧០ ឃួន និងក្រុមគ្រួសារ ព្រមទាំងអ្នកភូមិដទៃទៀត បានភៀសខ្លួនពីស្រុកកំពង់ត្រាចទៅរស់នៅក្រុងកែប ដើម្បីគេចពីការទម្លាក់គ្រាប់បែកនិងការប្រយុទ្ធគ្នារវាងទាហានសាធារណរដ្ឋ ខ្មែរនិងទាហានយៀកកុង ។ បងប្រុសរបស់ ឃួន ឈ្មោះ ឃរ ដែលកំពុងតែបួសក៏បានលាចាកសិក្ខាបទហើយធ្វើដំណើរទៅជាមួយក្រុមគ្រួសារ ។ នៅឆ្នាំ១៩៧៣ ក្រុមគ្រួសាររបស់ ឃួន បានផ្លាស់ទៅរស់វត្តព្រៃសំណាង ។ ឃួន បានរៀបរាប់ថា នៅម៉ោង៨ព្រឹក ពេលភៀសខ្លួនទៅដល់វត្តព្រៃសំណាង គាត់បានឃើញខ្មែរក្រហមដឹកព្រះសង្ឃប្រហែល២០០អង្គ ពីវត្តផ្សេងៗមកដាក់នៅខាងមុខបរិវេណវត្តព្រៃសំណាង បន្ទាប់មកខ្មែរក្រហមក៏ចាប់ផ្តើមដោះស្បង់ចីពរសង្ឃទាំងនោះចេញភ្លាមៗ ។ ខ្មែរក្រហមបានប្រគល់ឲ្យព្រះសង្ឃគ្រប់អង្គក្រមាមួយ មួកបេរ៉េមួយ ខោអាវខ្មៅមួយកំប្លេ និងស្បែកជើងមួយគូ ព្រមទាំងបំពាក់កាំភ្លើងមួយ ហើយដាក់ឈ្មោះថា កងអនុទិត ។ បន្ទាប់មកខ្មែរក្រហមបានដឹកកងអនុទិតតាមឡានចេញទៅវិញអស់ ។ បើតាម ឃួន ដឹងខ្មែរក្រហមបានយកកម្លាំងកងអនុទិតនេះទៅច្បាំងជាមួយកងទ័ពវៀតណាម ។

ឆ្នាំ១៩៧៤ តំបន់៣៥ត្រូវកាន់កាប់ដោយខ្មែរក្រហម ពេលនោះក្រុមគ្រួសារ ឃួន បានត្រឡប់មករស់នៅក្នុងភូមិវិញ ។ មេភូមិបានបំពាក់បំប៉នគោលនយោបាយខ្មែរក្រហមដល់យុវជនថា កូនប្រុសត្រូវតែចូលធ្វើទ័ពតស៊ូដើម្បីប្រទេសជាតិ ។ ការឃោសនានោះស្របពេលជាមួយនឹងសេចក្តីអំពាវនាវរបស់សម្តេចសីហនុ ដែលផ្សាយតាមវិទ្យុពីទីក្រុងប៉េកាំងមកថា "សូមឲ្យយុវជន-យុវនារីចូលព្រៃតស៊ូដើម្បីដណ្តើមប្រទេសជាតិមកវិញ" ។ ឃរ ក៏ស្ម័គ្រចិត្តចូលធ្វើបដិវត្តន៍ ។

ឃរ និងយុវជនក្នុងភូមិមួយចំនួន ត្រូវប្រធានកងបញ្ជូនឲ្យទៅលើកទំនប់សារនេសនៅដំណាក់ចង្អើរ ។ ដោយសារគាត់នឹកផ្ទះនិងខស្យាហ៍មកលេងបងប្អូននិងក្មួយៗរបស់គាត់ ឃរ ត្រូវប្រធានយុវជនទិតៀនថា "មានកម្មសិទ្ធិក្រាស់លះបង់មិន



អស់" ។ យរ មានការអាម៉ាស់នឹងការទិតៀននេះ ក៏ចេញទៅតាមទ័ពហើយបាត់ខ្លួនរហូត ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមរៀបចំភូមិឃុំ និងធ្វើទំនប់ ។ ជំនឿសាសនា ទំនៀមទម្លាប់ប្រពៃណី ត្រូវខ្មែរក្រហមហាមឃាត់មិនឲ្យមាន ។ វត្តអារាមត្រូវយកធ្វើជាមូលដ្ឋានទ័ព ហើយផ្ទះសម្បែងរបស់ប្រជាជនត្រូវរុះរើធ្វើជារោងបាយសហករណ៍ ។ ខ្មែរក្រហមបានចាត់តាំងឲ្យយុវជនយុវនារីចូលកងចល័តគ្រប់គ្នា ។ យួន បានចេញទៅលើកទំនប់ដីវែងមួយនៅស្រុកទូកមាសដើម្បីទប់ព្រែកឈ្មោះ "ទំនប់ទាន់ហាន់" ។ នៅទីនោះសីលធម៌របស់អង្គការតឹងរ៉ឹងណាស់ បុរសនិងស្ត្រី ទោះបីជាស្គាល់គ្នាក៏ដោយ ក៏មិនអាចនិយាយលេងសើចជាមួយគ្នាឬសួរសុខទុក្ខគ្នាទៅវិញទៅមកបានដែរ ប្រសិនបើអ្នកណាហ៊ានល្មើស អង្គការនឹងយកទៅអប់រំកសាងខ្លួន ។

នៅឆ្នាំ១៩៧៧ អង្គការបានបញ្ជូន យួន ទៅនៅក្នុងកងចល័តតំបន់ ខេត្តកំពត ដែលមាន តាច្រិច ជាគណៈតំបន់ ។ នៅខែ៦ ឆ្នាំ១៩៧៨ អង្គការចាប់ផ្តើមផ្សំផ្គុំយុវជន-យុវនារីនៅក្នុងកងចល័តតាមរយៈការផ្គូផ្គងប្រវត្តិរូប ។ យួន ត្រូវបានអង្គការចាប់ផ្សំផ្គុំជាមួយបុរសម្នាក់ដែលគាត់មិនដែលស្គាល់មុខសោះ ។ គូរបស់ យួន និង៣០គូផ្សេងទៀត បានចាប់ដៃគ្នាឡើងប្តេជ្ញានៅចំពោះមុខអង្គការថានឹងយកគ្នាជាប្តីប្រពន្ធ ហើយស្មោះត្រង់នឹងបក្សជានិច្ច ។ យួន រស់នៅជាមួយប្តីបាន៣ថ្ងៃក៏ត្រូវបែកគ្នាទៅធ្វើការងាររៀងៗខ្លួន ។



នៅឆ្នាំ១៩៧៨ ពេលកងទ័ពវៀតណាមវាយលុកមកដល់ខេត្តកំពត កងរបស់ យួន បានភៀសខ្លួនទៅដល់ឃុំរបងរមាស ខេត្តពោធិសាត់ តំបន់១៣ ។ នៅទីនោះអង្គការបានប្រគល់ផ្ទះមួយខ្នងសម្រាប់ពីរគ្រួសារ និងឲ្យប្រជាជនពីរគ្រួសារជីកអណ្តូងមួយដែលមានជម្រៅ៣-៤ម៉ែត្រ ។ យួន មិនបានដឹងអំពីគោលបំណងរបស់អង្គការក្នុងការជីកអណ្តូងទេ ។

អង្គការបានចាត់តាំងយុវនារីទៅយួរស្រូវឲ្យបានមួយថាំងម្នាក់ក្នុងមួយថ្ងៃ ។ យួន ត្រូវងើបតាំងពីព្រលឹមដើម្បីធ្វើដំណើរទៅកន្លែងកើបស្រូវនៅជំណាក់កន្សែង ព្រោះថាទម្រាំទៅដល់ យួន ត្រូវចំណាយពេលមួយកំណាត់ថ្ងៃ ។ បន្ទាប់ពីសម្រាកហូបអាហារថ្ងៃត្រង់រួច យួន ត្រូវធ្វើដំណើរត្រឡប់មកវិញជាមួយស្រូវមួយថាំង ហើយមកដល់គោលដៅនៅម៉ោង៦ៈ៣០ល្ងាច ។ នៅពេលមកដល់កន្លែង អង្គការបានចែកបាយនិងសម្លស្លឹកអំពិលដែលមានទឹករាវៗឲ្យហូប ។ យួន បន្តថា "បើសិនជាយើងគ្មានចានដាក់បាយទេ យើងត្រូវប្រើបាតដៃធ្វើជាចាន ។នៅកន្លែងកើបស្រូវ របបអាហារតិចហូបមិនឆ្អែត ហើយអង្គការឲ្យហូបតែអង្ករសម្រូបរៀងរាល់ថ្ងៃ ។ ប្រជាជនជាច្រើនឈឺក្រពះដោយសារមិនធ្លាប់ហូបអង្ករសម្រូប" ។ យួន ឆ្ងល់ថា ស្រូវដែលប្រជាជនធ្វើបានច្រើនណាស់មិនដឹងអង្គការបញ្ជូនទៅទីណាបែរជាឲ្យប្រជាជនហូបអង្ករសម្រូបទៅវិញ ។

ប្រហែលជា២ខែក្រោយមក ដំណឹងរន្ធត់មួយបានលេចឮឡើងពីរឿងអណ្តូងដែលខ្មែរក្រហមជីកនៅក្បែរផ្ទះរបស់ យួន គឺអង្គការបានយកធ្វើជាកន្លែងសម្លាប់មនុស្ស ។ យួន បានលួចស្តាប់អ្នកមូលដ្ឋាននៅទីនោះនិយាយគ្នាថាអង្គការសម្លាប់មនុស្ស

ជាច្រើនទម្ងាក់ទៅក្នុងអណ្តូង ជាងនេះទៅទៀតអង្គការមានគម្រោងសម្លាប់ប្រជាជនដែលផ្លាស់មកពីតំបន់៣៥ ។ អង្គការបានសម្លាប់មនុស្សដោយចាក់មេក្រូខ្លាំងៗ ដើម្បីកុំឲ្យប្រជាជនចាប់អារម្មណ៍ ។

បន្ទាប់ពីបានដឹងថាគណៈតំបន់១៣មានបំណងសម្លាប់ប្រជាជនតំបន់៣៥ មេកងរបស់ យួន ឈ្មោះ តាចែម បានផ្ញើសំបុត្រមួយច្បាប់ឲ្យគណៈតំបន់១៣ដើម្បីស្នើសុំបញ្ជូនប្រជាជនត្រឡប់មកតំបន់៣៥វិញ ។ គ្រាន់តែឮថាបានត្រឡប់ទៅស្រុកកំណើត យួន រីករាយណាស់ ក៏ទៅរៀបចំអីវ៉ាន់ហើយចាកចេញទាំងយប់ ។ ស្របពេលជាមួយគ្នានេះ កងទ័ពវៀតណាមបានចូលលុកលុយប្រទេសកម្ពុជា យួន មិនបានត្រឡប់មកក្រោយវិញឡើយ គាត់ត្រូវមេកងបញ្ជាឲ្យរៀបចំស្បៀងនិងសម្ភារផ្សេងៗទៀតធ្វើដំណើរចូលព្រៃ អ្នកខ្លះរែក អ្នកខ្លះទូល អ្នកខ្លះទៀតបណ្តើរគោក្របី ។ មេកងបានគំរាមថា បើហ៊ានតែនៅឬត្រឡប់ទៅក្រោយ ប្រយ័ត្នយួនវះពោះច្រកស្លាបអារ-ក ។ យួន ធ្វើដំណើរលេចវាលចូលព្រៃសំដៅទៅភ្នំលះបង់នៅព្រំដែនកម្ពុជា-ថៃនៅតាមផ្លូវ ។ យួន បានប្រទះឃើញសាកសពជាច្រើនដេកស្លាប់នៅលើភ្នំ និងឃើញមនុស្សចាស់ជរា កុមារនិងទារកដែលទើបនឹងកើត ត្រូវកូនចៅឪពុកម្តាយទុកចោលនៅលើភ្នំ ។ យួន មិនដឹងថាអ្នកទាំងនោះមានវាសនាយ៉ាងម៉េចទេក្រោយមក ព្រោះគាត់ត្រូវបន្តដំណើរទៅមុខទៀត ។

យួន បានបន្តដំណើរទៅមុខរហូតជិតដល់ព្រំដែនកម្ពុជា-ថៃ ប៉ុន្តែគាត់មិនអាចឆ្លងកាត់ព្រំដែនបានទេដោយសារថា មានកងទ័ពវៀតណាមអមទៅដោយរថក្រោះនិងកាំភ្លើងតូចធំស្ទាក់ផ្លូវខាងមុខជាប់ ។ យួន និងប្តី បានរស់នៅលើភ្នំអស់រយៈពេល២ខែទើបវិលត្រឡប់មកស្រុកកំណើតវិញ ។ យួន បញ្ជាក់ថា «នៅពេលធ្វើដំណើរមកតាមផ្លូវ ខ្ញុំមិនបានឃើញកងទ័ពវៀតណាមវះពោះច្រកស្លាបអារ-កមនុស្សដូចមេកងនិយាយសោះ» ។

ក្រោយពេលមកដល់ភូមិទើប យួន ដឹងថា បងប្រុសរបស់គាត់ពីរនាក់បានស្លាប់នៅក្នុងសមរភូមិប្រយុទ្ធ ហើយម្នាក់ទៀតឈ្មោះ យរ ដែលចូលបដិវត្តន៍តាំងពីឆ្នាំ១៩៧៤ ក៏បាត់ដំណឹង ។ មកដល់សព្វថ្ងៃនេះ យួន នៅតែនឹករឭកបងប្រុសរបស់គាត់ជានិច្ច ។ គាត់ពោលថា «ឥឡូវនេះសល់តែខ្ញុំ២នាក់បងប្អូន ។ ខ្ញុំគិតថា បងប្រុស យរ របស់ខ្ញុំពិតជាស្លាប់ហើយ ប្រសិនបើគាត់នៅរស់ គាត់ប្រាកដជាមករកខ្ញុំមិនខាន ព្រោះទីនេះជាភូមិកំណើតរបស់គាត់ យ៉ាងណាៗក៏គាត់ត្រូវតែត្រឡប់មកវិញ» ។ ខ្ញុំយល់ថា «របបខ្មែរក្រហមជារបបលំបាកណាស់ ប្រជាជនធ្វើការងារច្រើន ប៉ុន្តែអង្គការចែកអាហារឲ្យហូបមិនគ្រប់គ្រាន់ ហើយថែមទាំងមានការគំរាមកំហែងដល់អាយុជីវិតទៀត» ។

**សូ ហ្វារីណា**

# សេចក្តីជូនដំណឹងស្តីអំពីការបើកឱ្យប្រើប្រាស់
# ការិយាល័យពត៌មានសាធារណៈ
## របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចាប់បើកទ្វារបម្រើសាធារណជនពីថ្ងៃនេះតទៅ ។ ការិយាល័យពត៌មានសាធារណៈគឺជាទីតាំងសម្រាប់អានឯកសារដែលទាក់ទងនឹងរបបខ្មែរក្រហម ទស្សនាខ្សែភាពយន្តឯកសារខ្មែរក្រហម និងចូលរួមកម្មវិធីពិភាក្សាជាមួយអ្នកច្បាប់និងអ្នកសិក្សាស្រាវជ្រាវអំពីប្រធានបទខ្មែរក្រហម យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមជាតិ និងប្រធានបទផងទៃទៀត ។ ទិសដៅសំខាន់ពីររបស់ការិយាល័យពត៌មានសាធារណៈគឺ ១) ផ្តល់ពត៌មាននិងអប់រំប្រជាជនខ្មែរអំពីរបបខ្មែរក្រហម ២) ផ្សព្វផ្សាយពត៌មានអំពីដំណើរការអង្គជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហមជូនសាធារណជនឲ្យបានទូលំទូលាយ ។

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានទីតាំងនៅផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ។ ពត៌មានបន្ថែមស្តីអំពីការិយាល័យពត៌មានសាធារណៈ សូមទាក់ទង **សុគ្គា អ៊ីរ៉ែន** ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ស្លាប់ដោយសារមានកំណើតជាខ្មែរក្រោម

រហូតមកដល់សព្វថ្ងៃនេះ សុខ សួង នៅតែមិនភ្លេចប្រពន្ធ និងកូនស្រីពៅរបស់គាត់ដែលស្លាប់ក្នុងរបបខ្មែរក្រហមដោយសារតែមានកំណើតជាជនជាតិខ្មែរក្រោម ។ ប្រពន្ធ កូនស្រីពៅ និងបងប្អូនសាច់ថ្លៃជាច្រើននាក់របស់ សួង ត្រូវខ្មែរក្រហមសម្លាប់នៅក្នុងយុទ្ធនាការបោសសម្អាតខ្មែរក្រោមនៅឃុំរំលេចខេត្តពោធិ៍សាត់ ។

សួង ជាជនជាតិខ្មែរកើតនៅឡើងខេត្តពោធិ៍សាត់ បានរៀបការជាមួយ ស គៀង មានកំណើតនៅភូមិរូងតាកុក ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ឪពុករបស់ គៀង ឈ្មោះ ស និងម្តាយឈ្មោះ សៀង ជាខ្មែរក្រោមនៅខេត្តត្រាយឹង ដែលមកកាប់ឆ្ការព្រៃពានដីតាំងទីលំនៅនៅក្នុងភូមិព្រៃឈើទាល ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ តាំងពីអំឡុងឆ្នាំ១៩៣០ ។ នៅក្នុងរបបអាណានិគមនិយមបារាំង ភូមិរូងតាកុកមានឈ្មោះថាភូមិព្រៃឈើទាល ។ មកដល់របបសង្គមរាស្ត្រនិយម ដោយសារតែភូមិព្រៃឈើទាលមានទំហំធំពេក រាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមក៏បានបំបែកជាបួនភូមិ គឺ ភូមិរូងតាកុក ភូមិរំលេច ភូមិកំប្រាក់កូន និងភូមិខ្នារទទឹង ។

ក្រោយពេលរៀបការរួច សួង និង គៀង រស់នៅនិងប្រកបរបរធ្វើស្រែចម្ការនៅក្នុងភូមិរូងតាកុក ។ ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ប្រជាជននៅក្នុងភូមិរូងតាកុកធ្វើស្រែចម្ការតាមគ្រួសារជាធម្មតា មិនទាន់មានការរៀបចំជាក្រុមសាមគ្គីឬជាសហករណ៍នៅឡើយទេ គឺមានតែការរៀបចំជាកងទ័ពដើម្បីប្រយុទ្ធជាមួយទាហានលន់ណុលតែប៉ុណ្ណោះ ។

បន្ទាប់ពីថ្ងៃជ័យជម្នះ១៧មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានរៀបចំជាសហករណ៍ដោយចាប់បង្ខំឲ្យប្រជាជនរស់នៅក្នុងការដ្ឋាន"ហូបរួមធ្វើរួម" ។ រវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៦ គណៈកងបានចុះស្រង់ប្រវត្តិរូបប្រជាជនខ្មែរកម្ពុជាក្រោមនៅភូមិរូងតាកុក ជាច្រើនដង ។ នៅពេលចុះស្រង់ប្រវត្តិរូបប្រជាជនម្តងៗ គណៈកងខ្មែរក្រហមប្រាប់ប្រជាជនថា "អង្គការចង់ដឹងឲ្យច្បាស់ថានរណាជាខ្មែរសុទ្ធហើយនរណាជាខ្មែរក្រោម" ។

ក្រុមគ្រួសាររបស់ សួង ត្រូវគណៈកងខ្មែរក្រហមចុះស្រង់ប្រវត្តិរូបលើកទីមួយនៅក្នុងឆ្នាំ១៩៧៥គឺបន្ទាប់ពីហូបបាយថ្ងៃត្រង់រួច ។ ពេលនោះ សួង ប្រាប់គណៈកងតាមត្រង់ថា គៀង ជាខ្មែរក្រោម ឪពុកម្តាយមានស្រុកកំណើតនៅខេត្តត្រាយឹង ប្រទេសវៀតណាម ។ សួង បញ្ជាក់ទៀតថា "ជំនាន់នោះ ទោះបីជាយើងចង់លាក់ក៏លាក់មិនជិតដែរ ពីព្រោះយើងរស់នៅស្រុកភូមិជាមួយគ្នា គណៈកងខ្មែរក្រហមស្គាល់យើងច្បាស់ណាស់ យើងមិនអាចលាក់បាំងបានទេ ។ បើអ្នកជម្លៀសមកពីភ្នំពេញអាចលាក់បានខ្លះ ពីព្រោះមិនមាននរណាស្គាល់ប្រវត្តិរូបពីមុនមក" ។ ការស្រង់ប្រវត្តិរូបលើកទី២ក៏ដូចជាលើកទីមួយដែរ ។ សួង និយាយថា "ការដែលខ្មែរក្រហមស្រង់ប្រវត្តិរូបប្រជាជនពីរដងគឺចង់ផ្ទៀងផ្ទាត់មើលតើត្រូវគ្នាឬអត់" ។

នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសគ្រួសារណាដែលមានដាប់ខ្សែស្រឡាយខ្មែរកម្ពុជាក្រោមឲ្យទៅរស់នៅភូមិកំប្រាក់កូន ។ គណៈសហករណ៍បានប្រាប់ប្រជាជនឲ្យដឹងមុនថ្ងៃចេញដំណើរ ។ នៅព្រឹកព្រលឹមថ្ងៃបន្ទាប់ ក្រុមគ្រួសារខ្មែរក្រោមទាំងអស់បានចេញដំណើរទៅដល់ភូមិកំប្រាក់កូននៅវេលាថ្ងៃត្រង់ ហើយស្នាក់នៅភូមិកំប្រាក់កូនបានតែ៣ម៉ោងប៉ុណ្ណោះ ក៏ត្រូវខ្មែរក្រហមជម្លៀសបន្តទៅភូមិខ្នារទទឹងទៀត ដោយយកលេសថានៅភូមិកំប្រាក់កូនគ្មានកន្លែងឲ្យស្នាក់នៅ ។ នៅភូមិខ្នារទទឹង ក្រុមគ្រួសារកម្ពុជាក្រោមទាំងអស់ត្រូវខ្មែរក្រហមបញ្ជាឲ្យទៅស្នាក់នៅតាមផ្ទះមួយជួរដែលសង់ដាច់ដោយឡែកពីប្រជាជនមូលដ្ឋាន ។ គណៈសហករណ៍ថ្មីបានបែងចែកប្រជាជនដែលទើបនឹងមកដល់ជាក្រុមជាកងដើម្បីធ្វើការងារ ។ ក្នុងមួយកងមានប្រជាជនប្រមាណ៣០នាក់ ។

សួង ធ្វើការនៅក្នុងក្រុមជាងដែក ។ គៀង ត្រូវគណៈសហករណ៍ចាត់តាំងឲ្យនៅក្នុងក្រុមនារី ហើយបញ្ជូនឲ្យទៅធ្វើស្រែឆ្ងាយពីភូមិ ។ ខ្មែរក្រហមបានស្រង់ប្រវត្តិរូបម្តងទៀត ។ សួង បានឲ្យដឹងថា "ការស្រង់ប្រវត្តិរូបលើកនេះគឺខុសពី២លើក

មុន គឺខ្មែរក្រហមជាអ្នកសួរហើយខ្ញុំជាអ្នកឆ្លើយ» ។ សួង មានអារម្មណ៍ថាខ្មែរក្រហមចាប់ផ្តើមបែងចែកខ្មែរសុទ្ធនិងខ្មែរក្រោមហើយ ប៉ុន្តែគាត់ពុំទាន់បានដឹងអំពីគោលបំណងនៃការបែងចែកនេះនៅឡើយទេ ។

ទាំងខ្មែរក្រោមនិងខ្មែរសុទ្ធធ្វើការនិងហូបចុកដូចគ្នា ។ រយៈពេលពីរខែក្រោយមក គឺនៅក្នុងឆ្នាំ១៩៧៧ដដែល ខ្មែរក្រហមបានយកខ្មែរក្រោមទៅសម្លាប់តាមរូបភាពផ្សេងៗ ដូចជាផ្លាស់អង្គភាពពីធ្វើស្រែមកធ្វើចម្ការនិងដកមនុស្សមួយចំនួនឲ្យទៅកាប់ពោតជាដើម ។ នៅឆ្នាំ១៩៧៨ ភឿង ត្រូវគណៈសហករណ៍បញ្ជូនទៅកាប់ពោត ។

សួង និងកូនៗ បានសុំគណៈសហករណ៍ទៅដែរ ប៉ុន្តែគណៈកងឈ្មោះ តាអាន បានទាញដៃចេញមកវិញ ។ កូនស្រីពៅម្នាក់របស់ សួង បានយំទារតាមម្តាយមិនព្រមឈប់សោះ ។ ភឿង ក៏យកកូនស្រីទៅជាមួយ ។ តាអាន បាននិយាយប្រាប់ សួង ថា «អឹងឯងខ្មែរសុទ្ធទៅផ្ទះទៅ គេយកតែខ្មែរក្រោមទេ» ។

ភឿង និងកូនស្រីពៅ បានចេញទៅកាប់ពោតនៅព្រៃធំជាមួយនឹងខ្មែរក្រោមប្រមាណ២០នាក់ទៀត ។ ខ្មែរក្រោមដែលត្រូវជូនឲ្យទៅកាប់ពោតពុំបានដឹងថាខ្មែរក្រហមយកខ្លួនទៅសម្លាប់ទេ ។ ម្នាក់ៗត្រេកអរណាស់ ពីព្រោះរាល់ថ្ងៃហូបតែបបររាវៗមួយកំប៉ុងអង្ករសម្រាប់មនុស្ស២០-៣០នាក់ គឺហូបមិនឆ្អែតឡើយ ដល់ឮថាបានទៅកាប់ពោតនឹកក្នុងចិត្តថាមុខជាបានពោតហូបដើម្បីសម្រន់ការស្រេកឃ្លានខ្លះហើយ ។

មានខ្មែរកម្ពុជាក្រោមតិចតួចណាស់ដែលដឹងមុនថាការដែលខ្មែរក្រហមផ្លាស់ប្តូរអង្គភាពឲ្យខ្មែរកម្ពុជាក្រោមគឺយកទៅសម្លាប់ចោល ។ បងស្រីនិងបងថ្លៃរបស់ ភឿង ឈ្មោះ ដឹង និង យន់ ដឹងថាខ្មែរក្រហមបញ្ជូនឲ្យទៅកាប់ពោតគឺយកទៅសម្លាប់ ។ អ្នកទាំងពីរបានមកលា សួង ទាំងយំសស្រិកសស្រាក់ថា «ប្អូននៅឲ្យបានសុខចុះ ពួកបងទៅនេះទៅស្លាប់ហើយ មិនរស់ទេ» ។ សួង ហាក់ដូចជាមិនចាប់ភ្ញាក់ចំពោះសម្តីទាំងនេះទាល់តែសោះ ពីព្រោះគាត់គិតថាមិនដែលនរណាធ្វើសង្គ្រាមយកមនុស្សទៅសម្លាប់ដូច្នេះទេ ។

បន្ទាប់ពីគណៈសហករណ៍បញ្ជូន ភឿង ទៅកាប់ពោតបានមួយថ្ងៃ មានប្រជាជននៅភូមិខ្នារទទឹងបានមកខ្សឹបប្រាប់ សួង ថា ភឿង និងកូនស្រី ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលហើយ ។ កន្លះខែក្រោយមកទៀតទើប សួង ដឹងច្បាស់ថាប្រពន្ធនិងកូនស្រីពៅរបស់គាត់ពិតជាត្រូវខ្មែរក្រហមសម្លាប់មែន ព្រោះគណៈសហករណ៍បានប្រាប់ សួង ឲ្យសម្លឹងរកមើលស្ត្រីមេម៉ាយណាម្នាក់ដែលខ្លួនពេញចិត្តដើម្បីរៀបការម្តងទៀត ។ ពេលនោះ សួង បានប្រាប់ទៅគណៈកងវិញថាគាត់មានប្រពន្ធកូនហើយ ស្រាប់តែគណៈសហករណ៍គំរាមថា «ម៉េចចង់ទៅជាមួយប្រពន្ធឬ?» សួង ក៏យល់ព្រមរៀបការម្តងទៀត ។

សួង បានរៀបការលើកទី២ជាមួយនារីម្នាក់ឈ្មោះ សន ។ សន ក៏ធ្លាប់មានប្តីរួចមកហើយដែរ ប្តីរបស់នាងត្រូវរបួសធ្ងន់ អង្គការបញ្ជូនមកដេកពេទ្យតំបន់នៅតាឡូ ហើយប្រធានសហករណ៍កុហកនាងថាប្តីរបស់នាងស្លាប់បាត់ទៅហើយ ។ បន្ទាប់ពីអ្នកទាំងពីររៀបការបានរយៈពេលមួយខែ ស្រាប់តែប្តីរបស់ សន ត្រឡប់មកភូមិហើយសុំយក សន ធ្វើជាប្រពន្ធវិញ ។

នៅចុងឆ្នាំ១៩៧៨ បន្ទាប់ពីសម្លាប់ខ្មែរកម្ពុជាក្រោមអស់ ខ្មែរក្រហមបានចាប់ផ្តើមអនុវត្តផែនការបោសសម្អាតខ្មែរសុទ្ធម្តង ។ សួង បានអះអាងថា គាត់បានឮផ្ទាល់ត្រចៀកនូវការពិភាក្សាអំពីផែនការសម្លាប់ប្រជាជននៅពេលដែលគាត់ដើរទៅយកប្រដាប់ប្រដាធ្វើឡាំងនៅរោងជាង ។ គាត់បានឃើញមិត្តនារីគណៈស្រុកនិងគណៈសហករណ៍ពីរបីនាក់កំពុងជំនុំគ្នា ហើយនិយាយខ្លាំងៗថា «ត្រូវបោសសម្អាតជាបន្ទាន់និងឲ្យអស់ក្នុងរយៈពេលមួយអាទិត្យ» ។ ព្រមពេលនោះ អង្គការជម្លៀសប្រជាជនជាច្រើនមកពីខាងភូមិភាគបូព៌ានិងមកពីទីរួមខេត្តពោធិ៍សាត់ គណៈឃុំខ្នារទទឹងក៏ផ្អាកផែនការសម្លាប់ប្រជាជនក្នុងឃុំ ហើយបែរមកសម្លាប់ប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ាសិន ។

បច្ចុប្បន្ន សុខ សួង រស់នៅជាមួយកូន៥នាក់ នៅក្នុងភូមិរូងតាកុកដដែល ។ គាត់នៅតែរកមិនឃើញចម្លើយចំពោះការស្លាប់របស់ប្រពន្ធនិងកូនគាត់នៅឡើយ ។ **ឡុង ដានី**

ពាក្យស្លោកខ្មែរក្រហម

**ទុកមិនចំណេញ ដកចេញមិនខាត។**

# ហេតុអ្វីខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម្ល៉េះ?

## ១) សេចក្តីផ្តើម

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានធ្វើដំណើរចូលក្នុងទីក្រុងភ្នំពេញ ។ បក្សកុម្មុយនិស្តកម្ពុជាបានគ្រប់គ្រងអំណាចនៅប្រទេសកម្ពុជារហូតដល់ថ្ងៃដែលត្រូវកងទ័ពវៀតណាមបណ្តេញចេញពីអំណាចនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

នៅក្នុងរយៈពេលមិនដល់៤ឆ្នាំផង បក្សកុម្មុយនិស្តកម្ពុជាបានប្រែក្លាយប្រទេសកម្ពុជាពី «ទឹកដីដ៏ទន់ភ្លន់» ឲ្យទៅជា «វាលពិឃាត» ។ មួយភាគប្រាំនៃចំនួនប្រជាជនសរុបបានស្លាប់ដោយសារការសម្លាប់រង្គាល ការអត់ឃ្លាន ការធ្វើការងារហួសកម្លាំង និងដោយសារជំងឺដែលមិនបានទទួលការព្យាបាល ។ នេះគឺខុសពីអំពើប្រល័យពូជសាសន៍នៅកន្លែងផ្សេងៗទៀតដោយសារថាជនរងគ្រោះនិងជនដៃដល់ជាមនុស្សដែលមានជាតិសាសន៍តែមួយ ហេតុដូច្នេះហើយបានជាអ្នកខ្លះហៅអំពើនេះថាជា «ការប្រល័យពូជសាសន៍ខ្លួនឯង» ។

អ្នកដែលនៅរស់រានមានជីវិតជាច្រើននាក់បាននិយាយថាខ្លួនមិនយល់អំពីអ្វីដែលបានកើតឡើងទេ ។ ជួនកាលអ្នកទាំងនោះបន្ទោស ប៉ុល ពត ឬក៏ជនកុម្មុយនិស្តដទៃទៀត ជួនកាលអ្នកទាំងនោះយល់ថានេះជាកម្មពៀរដែលខ្លួនបានកសាងពីជាតិមុនមក ។

### ក) ទំហំនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា

គ្មានអ្នកណាម្នាក់ដឹងអំពីចំនួនប្រជាជនដែលស្លាប់ពិតប្រាកដនោះទេ ។ ការធ្វើជំរឿនប្រជាជនបានបង្ហាញនូវលទ្ធផលខុសៗគ្នា ។ អ្នកជំនាញការរបស់អង្គការសហប្រជាជាតិបានសន្និដ្ឋានថាអត្រាមនុស្សស្លាប់មានចំនួនប្រមាណ២០ភាគរយ គឺចន្លោះពី ១,៤៦លានទៅ១,៥៨លាននាក់ក្នុងចំណោមប្រជាជនសរុបពី ៧,៣លានទៅ៧,៩លាននាក់គិតត្រឹមខែមេសាឆ្នាំ១៩៧៥ ។ ឃៀរនិន បាននិយាយថា ទិន្នន័យអ្នកស្លាប់គឺ ៣៣ភាគរយជាប្រជាជនថ្មី ១៥ភាគរយជាប្រជាជនចាស់ ៤០ភាគរយជាកម្ពុជាក្រោម ៥០ភាគរយនៃជនជាតិចិន ៣៥ភាគរយនៃជនជាតិចាម ៤០ភាគរយជាជនជាតិថៃ និង១៥ភាគរយជាជនជាតិភាគតិច ។ ប្រជាជនវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាក្រោយឆ្នាំ ១៩៧៥ បានស្លាប់បាត់បង់ជីវិតស្ទើរតែទាំងអស់ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញថា មានរណ្តៅសាកសពរួមចំនួន២០.៤៩២រណ្តៅ ដែលកប់សាកសពជនរងគ្រោះប្រមាណ១.១១២.៨២៩នាក់ ។ មានរណ្តៅសាកសពតូចៗជាច្រើនទៀត ដែលរណ្តៅនីមួយៗមានសាកសពប្រហែល ៥នាក់ ហើយដែលភាគច្រើននៃសាកសពទាំងនេះជាសមាជិកក្រុមគ្រួសារតែមួយ និងមានរណ្តៅទំហំមធ្យមខ្លះដែលមានសាកសពពី១រយទៅ៤ឬ៥រយ ។ សាក្សីបានប្រាប់ថា រណ្តៅសាកសពប្រភេទនេះភាគច្រើនត្រូវបានបង្កើតឡើងនៅពេលដែលគុកខ្វះកន្លែងសម្រាប់ដាក់អ្នកទោស ហេតុនេះត្រូវតែសម្លាប់អ្នកទោសចាស់ចោលដើម្បីឲ្យមានបន្ទប់ទំនេរសម្រាប់ដាក់អ្នកទោសថ្មី ។ ហេតុដូច្នេះហើយ ជួនកាលយើងឃើញមានរណ្តៅសាកសពរួមខ្លះមានទំហំធំៗ និងមានសាកសពរហូតដល់រាប់ពាន់នាក់ដែលហាក់បីដូចជាមានការជាប់ទាក់ទងទៅនឹងការបោសសម្អាតប្រជាជនក្នុងទ្រង់ទ្រាយធំ ។ រណ្តៅសាកសពដែលធំបំផុតត្រូវបានជឿជាក់ថា មានគ្រោងឆ្អឹងជនរងគ្រោះរហូតដល់៧ពាន់នាក់ ។

លើសពីនេះទៀតក៏មានទីតាំងសម្លាប់ជាច្រើនទៀតស្ថិតនៅក្នុងព្រៃ ដែលជនរងគ្រោះត្រូវសម្លាប់ហើយទុកចោលហាលវាល ។

ប្រសិនបើគ្មានការវិភាគលើគ្រោងឆ្អឹង យើងមិនអាចបែងចែកបានទេថា តើគ្រោងឆ្អឹងណាស្លាប់ដោយការសម្លាប់ ហើយគ្រោងឆ្អឹងណាស្លាប់ដោយមូលហេតុផ្សេងទៀត ។

### ខ) ការពន្យល់ពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

អ្នកសង្កេតការណ៍នៅកម្ពុជាជាច្រើននាក់បានពន្យល់អំពីភាពខុសគ្នានៃមនោគមវិជ្ជា វប្បធម៌ និងសង្គម ។ ភាគច្រើននៃ

អ្នកទាំងនោះនិយាយសំដៅទៅរកទម្រង់ផ្សេងៗគ្នានៃរបបកុម្មុយនិស្ត ដូចជា របបម៉ៅនិយម ស្តាលីននិយម ឥទ្ធិពលពីកូរ៉េខាងជើងនិងយូហ្គោស្លាវី យុទ្ធនាការអប់រំនិងកំណែទម្រង់ដីធ្លីនៅក្នុងប្រទេសចិននិងវៀតណាម ។ អ្នកខ្លះបានលើកឡើងថាទ្រឹស្តីរបស់ ម៉ាក្ស ដែលថា «ប្រទេសរីកចម្រើនជួយនឹងប្រទេសប្រតិកិរិយា» បាននាំឲ្យកើតមានការប្រកាន់ពូជសាសន៍ ។

ការពន្យល់បែបមនោគមវិជ្ជាមួយបែបទៀតផ្តោតទៅលើការសិក្សារបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជានៅទីក្រុងប៉ារីស ជាកន្លែងដែលមេដឹកនាំទាំងនោះចូលរួមជាមួយបក្សកុម្មុយនិស្តបារាំងដែលនិយមស្តាលីន ហើយក៏បានយល់ដឹងពីគំនិតរបស់បដិវត្តន៍នេះ ។ មេដឹកនាំទាំងនោះបានរកឃើញស្លាកស្នាមដែលបន្សល់ទុកដោយលទ្ធិជេកូប៊ីន (*Jacobinism*) ជាពិសេសពីរ៉ូបេសព្យែរ និង បាប៊ីហ្វ ។ អ្នកបដិវត្តន៍ដទៃទៀតមានដូចជា បាគូនីន, សូរែល និង ហ្វាណុន ជាដើម ។ មនុស្សមួយចំនួនតូចបានប្រៀបធៀបមនោគមវិជ្ជារបស់បក្សកុម្មុយនិស្តកម្ពុជាទៅនឹងភាពអនាធិបតេយ្យហិង្សារបស់កសិករនិងប្រជាជននៅអឺរ៉ុបខាងកើតនិងអេស្ប៉ាញ ហើយបាននិយាយថា លទ្ធិកសិករនិយមបានឈ្នះលទ្ធិកុម្មុយនិស្តនិយម ។ អ្នកនិពន្ធខ្លះបានស្វែងរកធាតុផ្សំពីក្នុងព្រះពុទ្ធសាសនាថែមទៀត ។

វាជារឿងមួយដ៏សាមញ្ញក្នុងការស្វែងរកការពន្យល់អំពីបដិវត្តន៍កុម្មុយនិស្តកម្ពុជា នៅក្នុងវប្បធម៌ប្រពៃណីនិងគំនិតជាតិនិយមរបស់ខ្មែរ និងបានភ្ជាប់ការពន្យល់នេះទៅនឹងទំនៀមទម្លាប់ដែលបន្សល់ពីសម័យអង្គរមក ។ ការភ័យខ្លាចរបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាចំពោះវិសមានចិត្តរបស់វៀតណាម បានចាក់ឫសនៅក្នុងប្រវត្តិសាស្ត្រ ហើយបានបង្កើតឲ្យមានគំនិតស្អប់ជនបរទេស និងការចាប់បដិសន្ធិនូវគំនិត «សង្គមខ្មែរសុទ្ធសាធ» ដែលគិតថាខ្លួនស្ថិតនៅក្រោមឥទ្ធិពលនយោបាយរបស់អ្នកដទៃ ។ ប្រភពនៃវប្បធម៌ហិង្សាគឺជាការគុំគួនមួយដែលនាំទៅដល់ការសងសឹកជ្រុលហួសហេតុ ។ ជនបទដាច់ស្រយាលនិងភាពក្រីក្របានរួមចំណែកបន្ថែមក្នុងការងាយស្រួលដល់បដិវត្តន៍ ។

ជួនកាល អំពើប្រល័យពូជសាសន៍នៅកម្ពុជាត្រូវបានមើលឃើញថាជាលទ្ធផលនៃសង្គ្រាមផ្ទៃក្នុងនិងការដណ្តើមអំណាចគ្នា ។ មានការលើកឡើងមួយថា មេដឹកនាំបក្សត្រូវតែផ្តល់រង្វាន់ខ្លះដល់កងទ័ពនិងកម្មាភិបាលរបស់ខ្លួន និងប្រជាជនចាស់ ជាថ្នូរនឹងការធ្វើសង្គ្រាម ហើយរង្វាន់នោះគឺបណ្តោយឲ្យក្រុមទាំងបីធ្វើទុក្ខទោសប្រជាជនថ្មី ។ អ្នកនិពន្ធម្នាក់បានលើកឡើងថា ការសម្លាប់ភាគច្រើនធ្វើឡើងដោយអាជ្ញាធរតំបន់និងអាជ្ញាធរមូលដ្ឋានដែលយល់ថាមិនអាចអប់រំប្រជាជនដោយមិនប្រើទណ្ឌកម្មបានទេនៅក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងតែជួបប្រទះនូវវិបត្តិនយោបាយនិងគ្រោះទុរ្ភិក្ស ។

## គ) ប្រវត្តិសាស្ត្រកម្ពុជា

បើធៀបទៅនឹងប្រទេសផ្សេងៗ កម្ពុជាជាប្រទេសតូចមួយ ។ ផ្ទៃដីរបស់ប្រទេសកម្ពុជាស្មើនឹងពាក់កណ្តាលផ្ទៃដីនៃប្រទេសន័រវេ៉ មានចំនួនប្រជាជន១៣លាននាក់ ហើយមានទីតាំងនៅចន្លោះប្រទេសវៀតណាម (ដែលមានប្រជាជន៨៣លាននាក់) និងប្រទេសថៃ (ដែលមានប្រជាជន៦២លាននាក់) ។ ប្រទេសនេះព័ទ្ធជុំវិញដោយព្រៃភ្នំ ។ តំបន់ទំនាបកណ្តាលលាតសន្ធឹងលើផ្ទៃដីប្រមាណជា៧៥ភាគរយនៃផ្ទៃប្រទេសទាំងមូល ។

ចាប់ពីខែឧសភាដល់ខែវិច្ឆិកា អាកាសធាតុមូសុងត្រូពិកបាននាំទឹកភ្លៀងដ៏លើសលប់មកឲ្យប្រទេសនេះ ។ ទឹកជាធនធានយ៉ាងសំខាន់បំផុតរហូតដល់ប្រជាជនហៅប្រទេសថាជា «ទឹកដី» ។

នៅមុនពេលមានសង្គ្រាម ៨៦ភាគរយនៃប្រជាជនកម្ពុជាជាជនជាតិខ្មែរ ។ ជនភាគតិចដែលសំខាន់ៗមានៈ វៀតណាម (៤សែននាក់) ចិន (៣សែននាក់) ចាមនិងម៉ាឡេស៊ីដែលនិយមហៅថាខ្មែរឥស្លាម (១សែន៩ម៉ឺននាក់) និងខ្មែរលើ (៧ម៉ឺននាក់) ។ ក្រៅពីនេះក៏មានជនជាតិឡាវនិងថៃដែរ ។ ជនភាគតិចចិននិងវៀតណាមភាគច្រើនរស់នៅតាមទីក្រុង ។ ថ្នាក់ដឹកនាំសំខាន់ៗភាគច្រើនជាជនជាតិចិន ដូចជា ពាណិជ្ជករធំៗ សាស្ត្រាចារ្យ វិស្វករ រដ្ឋមន្ត្រី មន្ត្រីដែលមានឋានៈខ្ពស់ និងនាយកសហគ្រាសឯកជន ។ ជនជាតិវៀតណាមភាគច្រើនជាសិប្បករ អ្នកជំនួញតូចតាច កម្មករ អ្នកនេសាទ និងអ្នកបម្រើ ។

ព្រះពុទ្ធសាសនានិកាយថេរវាទជាសាសនាដែលគ្របដណ្តប់ប្រទេសនេះ ។ គោលការណ៍មូលដ្ឋាននៃសាសនានេះរួមមានទាំងទស្សនៈកម្មផលផង ។ «កម្ម» គឺជាអំពើដែលមនុស្សម្នាក់បាន

ប្រព្រឹត្តកាលពីជាតិមុន ។ ជាតិនេះមនុស្សម្នាក់មានទ្រព្យសម្បត្តិដោយសារជាតិមុនអ្នកនោះធ្វើកុសលល្អ ហើយបើមនុស្សម្នាក់ក្រគឺដោយសារតែជាតិមុនអ្នកនោះប្រព្រឹត្តអំពើអកុសល ឬក៏មិនបានប្រព្រឹត្តអំពើជាកុសល ។ ទស្សនៈកម្មផលដើរតួនាទីសំខាន់ក្នុងការអប់រំពុទ្ធសាសនិកកម្ពុជា ។ អាចារ្យគឺសំដៅទៅរកអ្នកដែលមានតួនាទីជាអ្នករៀបចំពិធីសាសនាផ្សេងៗ ជាអ្នកដែលមានដួងវិញ្ញាណពិសេស ឬក៏អ្នកដែលមានចំណេះដឹងខាងផ្នែកអក្សរសាស្ត្រ ។

## គ-១) កសិកម្ម

បឹងទន្លេសាបជាអ្នកកំណត់លក្ខខណ្ឌនៃកសិកម្ម ។ នៅរដូវប្រាំង បឹងទន្លេសាបគ្របដណ្តប់ផ្ទៃដីប្រមាណ២ពាន់គីឡូម៉ែត្រការ៉េ ។ ទឹកភ្លៀងមូសុងបានធ្វើឲ្យផ្ទៃបឹងនេះរីករហូតដល់១ម៉ឺនគីឡូម៉ែត្រការ៉េ ។ បឹងនេះមានត្រីដ៏ច្រើនសន្ធឹកសន្ធាប់ដែលអាចចាប់ដោយដៃបាននៅក្នុងទឹករាក់ៗ ។

ប្រទេសកម្ពុជាមានប្រព័ន្ធកសិកម្មពីរបែបគឺ ដីចម្ការដ៏មានជីជាតិនៅតាមដងទន្លេនិងបឹងបួ និងដីវាលទំនាបដែលមិនសូវមានជីជាតិ ។ កម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសដែលទទួលបានទិន្នផលស្រូវទាបបំផុតនៅក្នុងពិភពលោក ។

នៅក្នុងឆ្នាំ១៩៦៩ ប្រទេសនេះផលិតស្រូវបាន៣,៨លានតោន ។ ការនាំស្រូវចេញបានច្រើនបំផុតគឺនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ គឺប្រមាណ៥សែនតោន ។ ក្រៅពីស្រូវកម្ពុជាក៏បាននាំចេញនូវផលិតផលពោត សណ្តែកបាយ និងសណ្តែកសៀងដែរ ។ ថ្នាំជក់ កប្បាស ក្រចៅ អំពៅ និងស្លឹកមនក៏ជាដំណាំឧស្សាហកម្មដ៏ចាំបាច់ ។ ការដាំដំណាំកៅស៊ូរបស់បារាំងបានផ្តល់ផលប្រមាណ៥ម៉ឺនតោននៅក្នុងឆ្នាំ១៩៦៨ ហើយការនាំកៅស៊ូចេញស្មើនឹង២១ភាគរយនៃការនាំចេញសរុប ។

អាណានិគមបារាំងមិនបានផ្លាស់ប្តូរការកាន់កាប់ដីធ្លីនៅកម្ពុជាដូចនៅវៀតណាមខាងត្បូងទេ ។ កសិករកម្ពុជានៅតែធ្វើស្រែនៅលើដីរបស់ខ្លួនដដែល ។ ចាប់តាំងពីពេលទទួលបានឯករាជ្យសកម្មភាពនេះបានផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ។ ដីសម្រាប់ដាំដំណាំត្រូវបានចាត់ចូលទៅក្នុងប្រភេទដីផលិតកម្មសម្រាប់វិនិយោគ ។ មន្ត្រីកម្ពុជានិងចិនបានចាប់ផ្តើមធ្វើកសិកម្មដោយទ្រង់ទ្រាយធំនៅក្នុងខេត្តបាត់ដំបង ។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ មន្ត្រីមានអំណាចបានចាប់ផ្តើមប្រមូលដីធ្លីពីកសិករ ។ កសិករដែលគ្មានដីបានកើនចំនួនពី៤ភាគរយនៅឆ្នាំ១៩៥០ទៅដល់២០ភាគរយនៅឆ្នាំ១៩៧០ ។ ក៏ប៉ុន្តែ អ្នកដែលមានដីធំៗក៏មិនសូវមានឥទ្ធិពលប៉ុន្មានដែរ ។ នៅឆ្នាំ១៩៦២ ការសិក្សាបានបង្ហាញថា ៣,៤នៃម្ចាស់ដីមានបំណុលជាប់ខ្លួន ហើយបំណុលនេះបានកើនឡើងជាលំដាប់ ។

ភូមិជាកន្លែងមួយដែលមានមនុស្សរស់នៅ ដោយមិនគិតអំពីចំនួនផ្ទះតិចឬច្រើនទេ ។ ភូមិខ្លះមានផ្ទះតែពីរប៉ុណ្ណោះ ភូមិខ្លះមានផ្ទះរហូតដល់រាប់រយខ្នង ។ អ្នកភូមិភាគច្រើនមានចំណងញាតិសន្តានពីនឹងគ្នា ។ យើងអាចមើលឃើញចំណងសាមគ្គីរបស់អ្នកភូមិនៅពេលមានពិធីបួងសួងវិញ្ញាណក្ខន្ធបុព្វបុរស ។ នៅតាមភូមិភាគច្រើនតំបន់ដែលមានផ្ទះរបស់ជនជាតិចិនច្រើនគឺជាផ្សារ ។ ផ្ទុយស្រឡះពីវៀតណាម កម្ពុជាគ្មានមន្ត្រីសម្រាប់សម្របសម្រួលការងាររវាងព្រះមហាក្សត្រនិងប្រជារាស្ត្រទេ ។ ជាងនេះទៅទៀត កម្ពុជាគ្មានប្រព័ន្ធគ្រប់គ្រងជាឃុំសង្កាត់ គ្មានដីរួម និងស្ទើរតែគ្មានសកម្មភាពរួម ។ វត្តគឺជាមជ្ឈមណ្ឌលប្រមូលផ្តុំរបស់ប្រជាជននៅជនបទ ។ ជាធម្មតា កសិករកំណត់ទីតាំងភូមិរបស់ខ្លួនដោយវត្ត ។ ការជួយគ្នាទៅវិញទៅមកគឺជារឿងធម្មតារបស់ប្រជាជននៅតាមភូមិរវាងអ្នកជិតខាងឬញាតិសន្តាន ដោយមានការព្រមព្រៀងគ្នា ។ ផ្ទះនីមួយៗនៅដាច់ឆ្ងាយពីគ្នាប្រៀបដូចជាកោះ ។

## គ-២) កេរដំណែលប្រវត្តិសាស្ត្រ

យុគសម័យអង្គរ (៨០២-១៤៣១) នៅតែត្រូវបានចងចាំថាជារយៈកាលរុងរឿងបំផុតរបស់ជនជាតិខ្មែរ ។ ក្នុងចំណោមប្រាសាទធំៗទាំងឡាយដែលកសាងឡើងនៅក្នុងរយៈពេលនោះ អង្គរវត្តបានក្លាយទៅជានិមិត្តរូបរបស់ជាតិ ហើយត្រូវបានដាក់នៅលើទង់ជាតិកម្ពុជាចាប់តាំងពីសម័យក្រោយអាណានិគមមក ។

ភាពរុងរឿងនៃអារ្យធម៌និងភាពមិនអាចកាត់ថ្លៃបាននៃស្នាដៃទាំងនេះគឺពឹងផ្អែកទាំងស្រុងទៅលើវិស័យកសិកម្មដែលក្នុងនោះប្រព័ន្ធធារាសាស្ត្រត្រូវបានរៀបចំយ៉ាងអស្ចារ្យ ។ នៅសម័យអង្គរ តំបន់អង្គរទាំងមូលគឺជាវាលស្រែដែលអាចប្រមូលផល

ស្រូវបានពី៣ទៅ៤ដងក្នុងមួយឆ្នាំៗ ។ ព្រះមហាក្សត្រជាអ្នកធានាឲ្យដីមានជីជាតិ ព្រោះថាប្រជារាស្ត្រគោរពព្រះមហាក្សត្រដូចជាព្រះ ។

ចក្រភពអង្គរគឺជាមហាអំណាចនៅអាស៊ី-អាគ្នេយ៍ មានផ្ទៃដីព័ទ្ធជុំវិញប្រទេសវៀតណាមភាគខាងត្បូងនិងភាគកណ្តាលបច្ចុប្បន្ន ប្រទេសឡាវ និងប្រទេសថៃ ។ នៅពេលដែលចក្រភពនេះចុះខ្សោយ ព្រះមហាក្សត្របានបោះបង់ចោលរាជធានីអង្គរ ។ ចក្រភពនេះបានបន្តចុះទន់ខ្សោយដោយសារការលូកដៃរបស់បរទេស ជាពិសេសពីសំណាក់ប្រទេសវៀតណាមដែលគ្រប់គ្រងអំណាចដោយអំពើហិង្សានិងការគំរាមកំហែង ។ វៀតណាមបានប្រកាន់គោលជំហរឧបត្ថម្ភដល់ប្រជាជនកម្ពុជាដូចដែលមានសរសេរនៅក្នុងការណែនាំរបស់អធិរាជនៅឆ្នាំ១៨៣៤ថាៈ "ឥឡូវនេះ មនុស្សដែលឥតមានអារ្យធម៌បានក្លាយទៅជាកូនធម៌របស់យើងហើយ ។ យើងទាំងអស់គ្នាគួរតែជួយនិងបង្រៀនអ្នកទាំងនោះនូវទំនៀមទម្លាប់របស់យើង បង្រៀនឲ្យអ្នកទាំងនោះចេះប្រើប្រាស់គោ ចេះធ្វើស្រែឲ្យបានច្រើនជាងមុន ចេះដាំដើមមន ចេះចិញ្ចឹមជ្រូកនិងទា ចំណែកឯភាសាវិញ យើងគួរតែបង្រៀនអ្នកទាំងនោះឲ្យនិយាយភាសាវៀតណាម ។ យើងត្រូវតែឲ្យអ្នកទាំងនោះយកតម្រាប់តាមការស្លៀកពាក់និងរបៀបរបបនៃការទទួលទានអាហាររបស់យើង ។ ប្រសិនបើមានទំនៀមទម្លាប់ចាស់គំរិល ឬទំនៀមទម្លាប់បែបឥតមានអារ្យធម៌ដែលអាចកែប្រែឬអាចបង្ក្រាបបាន យើងត្រូវតែធ្វើ ។ ប្រភពពត៌មានដែលចេញពីប្រជាជនកម្ពុជាភាគច្រើនគឺទាក់ទងទៅនឹងទារុណកម្ម ការប្រហារជីវិត ការលបវាយប្រហារ ការសម្លាប់រង្គាល ការដុតភូមិ និងកំណែនប្រជាជន ។ ការបះបោរប្រឆាំងវៀតណាមបានផ្ទុះឡើងនៅអំឡុងឆ្នាំ១៨២០ និងម្តងទៀតនៅឆ្នាំ១៨៤០ ។ អ្នកបះបោរម្នាក់បានសរសេរថាៈ "ខ្ញុំសប្បាយចិត្តក្នុងការសម្លាប់ជនជាតិវៀតណាម" ។ នៅទសវត្សរ៍ឆ្នាំ១៨៤០ កម្ពុជាលែងជារដ្ឋដែលមានការទទួលស្គាល់ទៀតហើយ ។ ព្រះមហាក្សត្របានស្វែងរកជំនួយពីប្រទេសបារាំង ហើយនៅឆ្នាំ១៨៦៣ សន្ធិសញ្ញាមួយត្រូវបានធ្វើឡើង ដែលក្នុងនោះកម្ពុជាបានក្លាយទៅជារដ្ឋក្រោមអាណាព្យាបាលរបស់បារាំង ។

ភាពអស្ចារ្យនៃអតីតកាលរបស់កម្ពុជាដែលបានកសាងឡើងវិញដោយបារាំងបានធ្វើឲ្យមេដឹកនាំមួយចំនួនដូចជាសម្តេចសីហនុ, លន់ ណុល និង ប៉ុល ពត ព្រួយបារម្ភយ៉ាងខ្លាំង ។ ការបាត់បង់នូវទឹកដីបានបណ្តាលឲ្យទៅជាមានការអាក់អន់ចិត្តនិងមានអារម្មណ៍ប្រឆាំងជនជាតិវៀតណាម ។

## ២) ការសិក្សាពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា



រ៉ាហ្វែល លឹមគីន មេធាវីជនជាតិប៉ូឡូញ បានបង្កើតពាក្យ "ប្រល័យពូជសាសន៍" ដែលត្រូវបានយកមកប្រើប្រាស់នៅក្នុងសាលាជំនុំជម្រះក្តីនៅនូរ៉ឹមប៊ឺក (ប្រទេសអាល្លឺម៉ង់) ។ នៅឆ្នាំ១៩៤៦ មហាសន្និបាតអង្គការសហប្រជាជាតិបានចេញសេចក្តីសម្រេចមួយស្តីពីអំពើប្រល័យពូជសាសន៍ ដែលនាំទៅដល់ការ

បង្កើតជាអនុសញ្ញាអន្តរជាតិស្តីពីអំពើប្រល័យពូជសាសន៍នៅឆ្នាំ ១៩៤៨។ អនុសញ្ញានេះចែងថាៈ «អំពើប្រល័យពូជសាសន៍គឺជាអំពើមួយក្នុងចំណោមអំពើខាងក្រោម ហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែកនៃក្រុមជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយៈ ក) ការធ្វើឃាតទៅលើសមាជិកនៃក្រុម ខ) ការធ្វើឲ្យរបួសធ្ងន់ធ្ងរដល់រូបរាងកាយឬ



សតិបញ្ញានៃសមាជិកក្រុម គ) ការធ្វើដោយចេតនាឲ្យក្រុមមួយទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុងឬមួយផ្នែក ឃ) ការដាក់វិធានការនានាដែលមានបំណងរារាំងមិនឲ្យមានកំណើតទារក ង) ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយផ្សេងទៀត» ។

## ក) ការស្រាវជ្រាវអំពើប្រល័យពូជសាសន៍

អ្នកស្រាវជ្រាវសង្គមភាគច្រើនមើលឃើញថា និយមន័យនៃអំពើប្រល័យពូជសាសន៍ដែលចែងនៅក្នុងអនុសញ្ញាមានអត្ថន័យចង្អៀតពេក ហើយបានលើកឡើងនូវនិយមន័យមួយទៀតដែលមានន័យទូលាយជាងមុនគឺៈ ជាការសម្លាប់រង្គាលផ្តាច់ពូជក្រុមជាតិពន្ធុ ក្រុមនយោបាយ និងប្រជាជនទូទៅ។ ហេឡែន ហ្វេន បានឲ្យនិយមន័យអំពើប្រល័យពូជសាសន៍តាមបែបសង្គមវិទ្យាថា «ជាអំពើដែលមានបំណងបំផ្លិចបំផ្លាញរាងកាយរបស់ជនមួយក្រុម ទោះដោយផ្ទាល់ឬដោយប្រយោល តាមរយៈការហាមឃាត់មិនឲ្យមានការបន្តពូជ ដោយមិនគិតអំពីការចុះចាញ់ ឬការគំរាមកំហែងដែលបង្កឡើងដោយជនរងគ្រោះឡើយ» ។

លោកស្រីរាប់បញ្ចូលទាំងការកាត់បន្ថយអាហារដែលបណ្តាលឲ្យមានគ្រោះទុរ្ភិក្សនិងជំងឺផង ។

អ្នកជំនាញផ្នែកច្បាប់គឺជាអ្នកដែលបានចាប់ផ្តើមដោះស្រាយបញ្ហាប្រល័យពូជសាសន៍ ។ ទើបតែនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ទេដែលអំពើប្រល័យពូជសាសន៍បានក្លាយទៅជាប្រធានបទនៃការសិក្សា ជាពិសេសផ្តោតទៅលើការសម្លាប់រង្គាលជនជាតិជ្វីហ្វនៅអាល្លឺម៉ង់ ។ នៅឆ្នាំ១៩៨១ ឡេអូ គូពើ បានសិក្សាទៅលើប្រធានបទមួយដែលទូលាយជាងមុន គឺផ្តោតទៅលើអំពើប្រល័យពូជសាសន៍ជនជាតិអាមេនីនៅក្នុងប្រទេសទួរគីនៅឆ្នាំ១៩១៥ ។ បន្តមកមានអ្នកប្រាជ្ញដទៃៗទៀតបានសិក្សាស្រាវជ្រាវលើប្រធានបទនេះដែរ ។ ហេឡែន ហ្វេន បានរៀបចំការសិក្សាទាំងនេះជាប្រព័ន្ធដោយឡែកៗ ។

ភាគច្រើន ការសរសេរពីអំពើប្រល័យពូជសាសន៍មានរបៀបជាការអត្ថាធិប្បាយ ហើយខ្វះខាតការភ្ជាប់ទំនាក់ទំនងទៅនឹងទ្រឹស្តីសង្គម ។ អាឡិក អាល់វ៉ារ៉េ បានផ្តល់នូវការពន្យល់ដែលអាចយកជាការបានខ្លះៗៈ ជាធម្មតា អំពើប្រល័យពូជសាសន៍មានភាពស្មុគស្មាញ ។ គំនិតវិទ្យាសាស្ត្រដែលសំអាងលើការពិសោធន៍បានសង្កត់ធ្ងន់ទៅលើវិធានការនិងបច្ចេកទេសជាជាងទៅលើទ្រឹស្តី ។ មិនមែនជាការងាយស្រួលទេក្នុងការសិក្សាស្រាវជ្រាវឆ្លងជាតិសាសន៍ ។ អាឡិកសាន់ដឺ ឡាបាន ហ៊ីនតុន គិតថា នរវិទូអាចមិនស្រណុកចិត្តនៅពេលដែលសិក្សាប្រធានបទ

ស្តីពីអំពើប្រល័យពូជសាសន៍ ដោយសារតែប្រធានបទនេះជាប់ទាក់ទងទៅនឹងពាក្យមួយចំនួនដូចជា ពូជសាសន៍ ជាតិពន្ធ និងវប្បធម៌ ។ ជាធម្មតា នរវិទូទាំងនោះមានអារម្មណ៍ថាខ្លួនកំពុងតែជាប់ផុងនៅក្នុងភាពចម្រូងចម្រាសនេះ ។ គំនិតអភិរក្សនិយមចំពោះចំណេះដឹង អាចមានតួនាទីសំខាន់នៅក្នុងបញ្ហានេះ ។

នៅទសវត្សរ៍ឆ្នាំ១៩៩០ បញ្ហាថ្មីៗបានកើតមានឡើង ដោយសារតែ «ការបោសសម្អាតជាតិពន្ធ» នៅក្នុងអតីតប្រទេសយូហ្គោស្លាវី ការសម្លាប់រង្គាលនៅរ៉ាន់ដា និងតួលេខដែលមិនគួរឲ្យជឿនៃការស្លាប់ដ៏សន្ធឹកសន្ធាប់ត្រូវបានបង្ហាញនៅពេលដែលបណ្ណសាររបស់សហភាពសូវៀតត្រូវបានបើកចំហ ។ ឥឡូវនេះ ការសិក្សាស្រាវជ្រាវភាគច្រើនផ្តោតទៅលើឧក្រិដ្ឋកម្មរបស់រដ្ឋកុម្មុយនិស្ត ។ ការសិក្សាមួយចំនួនត្រូវបានប្រមូលចងក្រងក្នុង «សៀវភៅខ្មៅនៃលទ្ធិកុម្មុយនិស្ត» ដែលពិនិត្យផ្ទៀងផ្ទាត់ដោយស្ទេហ្វាន ខឺតថឺស ដែលបានវែកញែកថា អំពើប្រល័យពូជសាសន៍ទៅលើក្រុមមួយដូចគ្នាទៅនឹងអំពើប្រល័យពូជសាសន៍ទៅលើអម្បូរមួយ ។

នៅឆ្នាំ១៩៩៨ សកលវិទ្យាល័យអ៊ុបសាឡានៃប្រទេសស៊ុយអែដបានបង្កើតកម្មវិធីមួយដើម្បីសិក្សាទៅលើអំពើសម្លាប់ផ្តាច់ពូជដែលធ្វើឡើងដោយណាហ្ស៊ីទៅលើជនជាតិជ្វីហ្វ និងសិក្សាលើអំពើប្រល័យពូជសាសន៍ ហើយវេទិកាអន្តរជាតិស្តុកខូមបានរៀបចំសន្និសីទបួនដងស្តីពីអំពើប្រល័យពូជសាសន៍ដែរ ។

### ១) កម្ពុជានៅក្នុងការសិក្សាពីអំពើប្រល័យពូជសាសន៍

អ្នកប្រាជ្ញបួនប្រាំនាក់ដែលសិក្សាអំពើប្រល័យពូជសាសន៍បានស្វែងរកការពន្យល់អំពីករណីរបស់ប្រទេសកម្ពុជា ។ អ្នកប្រាជ្ញទាំងនោះមានៈ សង្គមវិទូ ហេឡែន ហ្វេន និង លេអូ គូពើ, អ្នកវិទ្យាសាស្ត្រនយោបាយ រូដុហ្វ ជេ រ៉ាំមល, ចិត្តវិទូ អឺវីន ស្តូប, ឧក្រិដ្ឋវិទូ អាឡិក អាល់វ៉ារ៉េ, ហ្វ្រែង ឆក និង ខឺត ចូណេសិន ។ អ្នកប្រាជ្ញទាំងប៉ុន្មាននាក់នេះមើលឃើញថា អំពើប្រល័យពូជសាសន៍នៅកម្ពុជាជាលទ្ធផលនៃមនោគមវិជ្ជានិងទស្សនៈជាតិនិយមដែលភាគច្រើនជំរុញដោយស្តាលីន និង(ឬ) ម៉ៅ សេទុង ជាពិសេសដោយសារនយោបាយមហាលោតផ្លោះមហាអស្ចារ្យ និងបដិវត្តវប្បធម៌ ។ អឺវីន ស្តូប បានមើលឃើញថានេះជាឥទ្ធិពលដែលទទួលបានពីយូហ្គោស្លាវី ។

អាល់វ៉ារ៉េ, ហ្វ្រែង ឆក, ចូណេសិន, គូពើ និង ស្តូប យល់ថា គំនិតរបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាត្រូវបានជំរុញនិងលើកទឹកចិត្តដោយលទ្ធិរ៉ាឌីកាល់របស់បារាំង និងដោយសារនិក្ខេបបទរបស់ ខៀវ សំផន នៅឆ្នាំ១៩៥៩ ។ ទាក់ទងទៅនឹងមូលហេតុដែលជំរុញឲ្យមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាឈានទៅដល់ការប្រព្រឹត្តដូច្នេះ ស្តូប បានចង្អុលបង្ហាញទស្សនៈអនាធិបតេយ្យនិយមរបស់បាយូនីន និងគំនិតមួយដែលថា សេចក្តីសុខក្សេមក្សាន្តតែងតែរួមផ្សំជាមួយនឹងអំពើហិង្សា ។

អ្នកស្រាវជ្រាវមួយចំនួនបានស្វែងរកការពន្យល់នៅក្នុងអតីតកាលនៃសម័យអង្គររបស់កម្ពុជា ដោយគិតថាអតីតកាលដ៏រុងរឿងមួយនេះបានបន្សល់ទុកឲ្យប្រជាជនកម្ពុជានូវការប្រកាន់ពូជសាសន៍ អារម្មណ៍ប្រឆាំងនឹងជនជាតិវៀតណាម និងទស្សនៈមិនចូលចិត្តជនបរទេស ។ ហ្វេន បាននិយាយសំដៅទៅរកការប្រកាន់ពូជសាសន៍ គំនិតជាតិនិយម រចនាសម្ព័ន្ធសង្គម វប្បធម៌ សាសនា និងនយោបាយ ។ រ៉ាំមល គិតថា វប្បធម៌អាចជាមូលហេតុធ្វើឲ្យមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាក្លាយជាមនុស្សជ្រុលនិយមបែបនេះ ។ មេដឹកនាំទាំងនោះជឿជាក់ថាខ្លួនអាចធ្វើអ្វីដែលប្រទេសកុម្មុយនិស្តដទៃទៀតមិនអាចធ្វើបាន ពោលគឺបង្កើតរបបកុម្មុយនិស្តមួយឲ្យបានក្នុងរយៈពេល «ប្រាំពីរថ្ងៃប្រាំពីរយប់» ។

អ្នកនិពន្ធខ្លះទៀតបានគិតទៅដល់ការភ័យខ្លាចនិងការស្អប់ខ្ពើមដ៏ជ្រុលហួសហេតុរបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាចំពោះទីក្រុងនិងទីប្រជុំជនដែលខ្លួនមើលឃើញថាជាកន្លែងដែលពោរពេញទៅដោយគំនិតបរទេស និងជាកន្លែងដែលដួងវិញ្ញាណដ៏បរិសុទ្ធរបស់ខ្មែរត្រូវបំពុលដោយមូលធននិយមនិងអ្នកចេះដឹង ។ អាល់វ៉ារ៉េ, ឆក, ចូណេសិន និង ស្តូប យល់ថា មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាចង់ប្រែក្លាយសង្គមកម្ពុជាឲ្យទៅជាសង្គមមួយដែលមានតែកសិករសុទ្ធសាធ ។ គូពើ បានបដិសេធគំនិតដែលថាលទ្ធិកសិករនិយមបានទទួលជោគជ័យលើលទ្ធិម៉ាក្សនិយម ។

ការពន្យល់ផ្សេងៗទៀតអំពីទស្សនៈរបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាគឺទាក់ទងជាមួយនឹងវិបត្តិសង្គមនិងការបង្ក្រាប

ការបះបោរនៅមុនទសវត្សរ៍ឆ្នាំ១៩៧០ សង្គ្រាម និងការទម្លាក់គ្រាប់បែករបស់អាមេរិកពីឆ្នាំ១៩៧០ដល់១៩៧៥ ។ ហ៊េន បានលើកអំពីភាពស្របច្បាប់នៃការដណ្តើមអំណាចរបស់ក្រុមអ្នកមានអំណាចនិងមានលុយកាក់ ។ គូពើ បានសន្និដ្ឋានថា សត្រូវសំខាន់ៗពិតប្រាកដត្រូវតែកម្ទេចចោលដើម្បីបង្រួបបង្រួមបដិវត្តន៍ ។ ភុំមល និង ស្តូប បានសរសេរថា នៅពេលនោះមានការដណ្តើមអំណាចគ្នា ។ អស្ថិរភាពនិងរោគឆ្កួតបាននាំឲ្យមានបន្សុទ្ធកម្ម ដោយសារតែមេដឹកនាំខ្មែរក្រហមយល់ថាវៀតណាម សហរដ្ឋអាមេរិក និងសហភាពសូវៀត ចាប់ផ្តើមរៀបចំកលល្បិចបំផ្លាញរបបរបស់ខ្លួន ។

### គ) ការសិក្សាអំពី«បទល្មើសរបស់លទ្ធិកុម្មុយនិស្ត» នៅកម្ពុជា

នៅក្នុង«សៀវភៅខ្មៅនៃលទ្ធិកុម្មុយនិស្ត» ជីន លូីម៉ាហ្គោលីន បានលើកឡើងនូវកត្តាជំរុញមួយចំនួនដូចជា លទ្ធិលេនីននិយម, នយោបាយឃុំ-សង្កត់និងមហាលោតផ្លោះរបស់ចិន (មិនមែនបដិវត្តន៍វប្បធម៌ទេ), វៀតណាម, គីម អ៊ីលស៊ុង និងលទ្ធិស្តាលីននិយម ។ គាត់បានយល់ស្របទៅនឹងទស្សនៈរបស់ ខឺតជឺស អំពីជាតិសាសន៍និយមរបស់សង្គម ។ គាត់មើលមិនឃើញថាការសម្លាប់មនុស្សរបស់ខ្មែរក្រហមគឺជាលទ្ធផលនៃការទទួលយកឥទ្ធិពលអំពីប្រទេសបារាំងនិងលទ្ធិកុម្មុយនិស្តនៅបារាំងនោះទេ ផ្ទុយទៅវិញ គាត់មើលឃើញថានេះជាទម្រង់របស់ព្រះពុទ្ធសាសនានិងប្រពៃណីដែលបន្សល់ពីសម័យអង្គរមក គឺទស្សនៈជាតិនិយមនិងគំនិតស្អប់បរទេស ។ នេះជាការសងសឹករបស់អ្នកជនបទចំពោះអ្នកទីក្រុង ។ អ្វីដែលបានកើតឡើងនៅកម្ពុជាគឺជាភាពស្មុគស្មាញនៃការមិនចុះសម្រុងគ្នារវាងអ្នកដឹកនាំនិងប្រជាជនដែលពិបាកនឹងរកពាក្យមកពន្យល់ ។ ទស្សនៈរបស់គាត់ស្របគ្នាទៅនឹងការយល់ឃើញរបស់ ភីរូវៀន សេនដឺរ៉ូ លូមីណូសូ របស់ខុទ្ទាមខ្លាតាមីលនៅស្រីលង្កានិងគណបក្សកម្មកររបស់ជនជាតិខឺត ។

ស៊ីហ៊ិន ម៉ូរីស បានពន្យល់អំពីមូលហេតុដែលមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាប្រព្រឹត្តមិនសមហេតុផលចំពោះប្រទេសវៀតណាមដែលមានឧត្តមភាពលើសលប់ផ្នែកយោធា ។ នៅក្នុងវប្បធម៌នយោបាយរបស់មេដឹកនាំទាំងនេះមានបង្កប់តម្លៃនៃវប្បធម៌ប្រពៃណីនិងការតូចចិត្តដែលមើលមកខ្លួនឯងហាក់បីដូចជាទន់ខ្សោយជាងប្រទេសជិតខាង ជាពិសេសប្រទេសវៀតណាម ។ ការដឹកនាំមួយដែលមិនត្រឹមត្រូវអាចបណ្តាលមកពីការយល់ខុសរបស់អ្នកដឹកនាំដែលគិតថាខ្លួនមានអំណាចដ៏អស្ចារ្យ ។ របបខ្មែរក្រហមបានបង្កការភ័យខ្លាចនិងអំពើហិង្សាចំពោះប្រជាជនរបស់ខ្លួននៅគ្រប់ច្រកល្ហក ។ បក្សកុម្មុយនិស្តកម្ពុជាបានធ្វើសកម្មភាពដោយយោងទៅលើទ្រឹស្តីរបស់ម៉ៅអំពីអត្ថិភាពនៃការគ្រប់គ្រងខ្លួនឯងនិងភាពបរិសុទ្ធនៃមនោគមវិជ្ជាជុំវិញកត្តាសម្ភារ ។

អេរិក វើត បាននិយាយថា មនោគមវិជ្ជានិងគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាគឺឈរលើមូលដ្ឋានគោលនយោបាយកុម្មុយនិស្ត ជាពិសេសគឺកុម្មុយនិស្តចិន ។ ក៏ប៉ុន្តែមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាចង់ប្រើប្រាស់គោលនយោបាយទាំងនេះដើម្បីបង្កើតនូវសង្គមកុម្មុយនិស្តមួយដែលពិតប្រាកដស្មើភាពគ្នា ហើយគ្មានការជ្រៀតជ្រែកពីសំណាក់បរទេស ។ មធ្យោបាយនេះរួមផ្សំជាមួយគ្នានឹងគំនិតជាតិនិយមជ្រុលហួសហេតុដែលបានចាក់ឫសយ៉ាងជ្រៅទៅក្នុងវប្បធម៌របស់ខ្មែរ ។ ការស្វែងរកសត្រូវបានផ្តល់ឲ្យខ្មែរក្រហមនូវកម្លាំងចលករពិសេសមួយដូចដែលធ្លាប់មានរួចមកហើយ នៅក្នុងបដិវត្តន៍សូវៀត ណាហ្ស៊ី និងយូហ្គោស្លាវី ។ ដូចជានៅក្នុងសហភាពសូវៀតនិង ដឺ ស៊ឺតរីច (The Third Reich: សម័យកាលមួយនៅក្នុងប្រទេសអាល្លឺម៉ង់ពីឆ្នាំ១៩៣៣ដល់ឆ្នាំ១៩៤៥) ប្រភេទនៃអត្តសញ្ញាណស្ថិតនៅលាយឡំជាមួយនឹងលក្ខណៈវិនិច្ឆ័យនយោបាយសង្គមនិងជាតិពន្ធុ ។ ក៏ប៉ុន្តែមនោគមវិជ្ជាតែឯកឯងមិនអាចពន្យល់ឲ្យបានគ្រប់គ្រាន់ចំពោះទង្វើរបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាទេ ។ កត្តានយោបាយនិងវិបត្តិនៅក្នុងជួរថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជានៅឆ្នាំ១៩៧៦ក៏រួមចំណែកនាំឲ្យឈានទៅដល់បន្សុទ្ធកម្មដែរ ។

### ឃ) ការរៀបចំគម្រោងតាមទ្រឹស្តី

អ្នកប្រាជ្ញជាច្រើននាក់ដែលសិក្សាពីអំពើប្រល័យពូជសាសន៍បានពិភាក្សាអំពីលក្ខខណ្ឌនិងកត្តាដែលជំរុញឲ្យកើតមានអំពើហិង្សា ។ មូលហេតុដ៏បួងបំផុតនោះគឺថា មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាបានបំបាត់ចោលនូវតម្លៃនិងទំនៀមទម្លាប់របស់ជនរងគ្រោះ ។

មនុស្សជាច្រើនបានកត់សម្គាល់ថា សង្គមមួយដែលមានចម្រុះជាតិពន្ធនឹងបង្កគ្រោះថ្នាក់ខ្ពស់ជាទីបំផុត ។ នៅក្នុងអំពើប្រល័យពូជសាសន៍ជនជាតិជ្វីហ្វនិងជនជាតិអាមេនី ក្រុមដែលត្រូវទាត់ចោលឬមិនមាននរណាយកចិត្តទុកដាក់ ត្រូវបានមើលឃើញថាជាសម្ព័ន្ធមិត្តរបស់សត្រូវដែលមកពីខាងក្រៅ ហើយត្រូវបានហៅថាជាជនក្បត់ ។ នេះមានន័យថា មានការសម្លាប់រង្គាលមួយបែបដែលភាគច្រើនបង្កឡើងដោយមនោគមវិជ្ជាមួយដែលគិតថាសេចក្តីសុខក្សេមក្សាន្តត្រូវតែមានលាយឡំនឹងអំពើហិង្សានិងមនោគមវិជ្ជាផ្សេងៗទៀតដែលទាក់ទងទៅនឹងទស្សនៈជាតិនិយមនិងជម្លោះជាតិពន្ធ ។

កម្មវិធី អ៊ុបសាឡា បានប្រៀបធៀបការលើកឡើងរបស់ហ្វេន ទៅនឹងការលើកឡើងរបស់អ្នកប្រាជ្ញពីរនាក់ផ្សេងទៀតអំពីលក្ខខណ្ឌនិងដំណើរការដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍ ហើយបានរកឃើញគំនិតដូចគ្នាខ្លះៗ ។ គំនិតទាំងនេះបានបង្ហាញពីការរៀបចំផែនការតាមទ្រឹស្តីមួយដើម្បីស្វែងរកយន្តការនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ លក្ខខណ្ឌនិងដំណើការទាំងឡាយត្រូវបានដាក់ឲ្យស៊ីសង្វាក់គ្នារហូតនាំទៅដល់អំពើប្រល័យពូជសាសន៍ៈ

*១) មូលហេតុដំបូងៈ* សង្គមកម្ពុជាពោរពេញទៅដោយមនោគមវិជ្ជាប្រកាន់ពូជសាសន៍និងការឃោសនាភូតកុហក ។ ក្រុមដែលមានឥទ្ធិពលបានឲ្យនិយមន័យជនរងគ្រោះថាជាអ្នកដែលមានចរិតមិនល្អ ។ អំណាចរបស់រដ្ឋត្រូវបានកាត់បន្ថយដោយសារបរាជ័យនៅក្នុងសង្គ្រាម (ដូចនៅប្រទេសអាល្លឺម៉ង់និងទួរគី) ការលំបាកផ្លូវចិត្ត វិបត្តិនយោបាយ និងវប្បធម៌ ។

*២) ឱកាសៈ* ការដឹកនាំដែលពោរពេញដោយអំណាចបានបង្កើតជាគណបក្សទោលដែលផ្តល់សិទ្ធិឲ្យទៅតែក្រុមអ្នកដឹកនាំប៉ុណ្ណោះ ។

*៣) ការសម្រេចចិត្តៈ* ការដឹកនាំនោះបង្កើតឲ្យមានអ្នកខាងក្រៅ និងមានមហិច្ឆិតាទឹកដីយ៉ាងខ្លាំង ។

*៤) មធ្យោបាយៈ* ការបំផ្លិចបំផ្លាញត្រូវបានរៀបចំគម្រោងដោយបក្សដែលពឹងផ្អែកទាំងស្រុងទៅលើកងកម្លាំងយោធា ។

*៥) និរទណ្ឌភាពៈ* លទ្ធភាពនៃការសងសឹកដោយអ្នកមិនមានអំណាចនិងជនរងគ្រោះដែលទន់ខ្សោយ ឬក៏ដោយសារការលូកដៃចូលរបស់បរទេសទៅក្នុងអំពើប្រល័យពូជសាសន៍ គឺស្ថិតនៅក្នុងកម្រិតជាអប្បបរមា ហើយដែលប្រហែលជាអាចប្រមូលផ្តុំគ្នាជាសម្ព័ន្ធភាពដើម្បីកាត់បន្ថយនូវការសម្លាប់ផ្តាច់ពូជជនរងគ្រោះ ។

កត្តាទាំងអស់នេះបានបង្ហាញវត្តមាននៅក្នុងប្រទេសកម្ពុជានិងមានខ្លះៗនៅក្នុងប្រទេសវៀតណាម ប៉ុន្តែនៅវៀតណាមកត្តាទាំងនេះមិនបានបណ្តាលឲ្យកើតមានអំពើប្រល័យពូជសាសន៍ទេ ។ បញ្ហានេះនឹងត្រូវបានពិភាក្សានៅក្នុងជំពូកចុងក្រោយ ។

**(នៅមានត)** **ម៉ូង សាន់ឃ្វីស**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM១០២MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជាផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង១៩ៈ៣០ - ១៩ៈ៤៥នាទី វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃ នៅម៉ោង៧ - ៧ៈ៣០នាទីព្រឹក និងម៉ោង៧ - ៧ៈ៣០នាទីល្ងាច និងវិទ្យុ FM៩៩MHz ខេត្តព្រះវិហារ នៅម៉ោង៧ - ៧ៈ៣០នាទីព្រឹក និងម៉ោង៦ៈ៣០ - ៧នាទីល្ងាច ។

នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្សាយកម្មវិធីដូចគ្នានេះនៅវិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបងជារៀងរាល់ថ្ងៃនៅម៉ោង៩ - ៩ៈ៣០នាទីព្រឹក និងម៉ោង៣ - ៣ៈ៣០នាទីល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើងនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**សូ ហ្សារីណា និង លី សុផល**

# ការបង្កើតការទទួលខុសត្រូវសម្រាប់មេដឹកនាំខ្មែរក្រហមចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិ

## ១) សេចក្តីផ្តើម

បន្ទាប់ពីត្រូវបានអូសទាញចូលទៅក្នុងការពិភាក្សាអំពីការទទួលខុសត្រូវរបស់ខ្មែរក្រហម លេខាធិការដ្ឋានអង្គការសហប្រជាជាតិបានចំណាយអស់រយៈពេលប្រាំឆ្នាំចុងក្រោយនេះ ក្នុងការស្វែងរករចនាសម្ព័ន្ធតុលាការមួយដែលអាចទទួលយកបានទាំងសងខាង ដើម្បីកាត់ទោសមេដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យពីបទឧក្រិដ្ឋកម្មអន្តរជាតិដែលបានប្រព្រឹត្តក្នុងរវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ។

ដើម្បីឆ្លើយតបទៅនឹងសំណើសុំជំនួយរបស់រដ្ឋាភិបាលកម្ពុជាកាលពីខែមិថុនា ឆ្នាំ១៩៩៧ អង្គការសហប្រជាជាតិបានសម្រេចចិត្តគាំទ្រឲ្យមានការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិពិសេសលើកទីបី ។ ដោយយកសំណើនោះមកធ្វើជាចំណុចចាប់ផ្តើម អត្ថបទនេះបានចងក្រងទុកជាឯកសារនូវហេតុការណ៍ជាច្រើនដែលនាំឲ្យអង្គការសហប្រជាជាតិឆ្ពោះទៅរកការចូលរួមដែលគ្មានឆន្ទៈនៅក្នុងដំណើរការជំនុំជម្រះក្តីក្នុងស្រុកដែលគ្មានភាពយុត្តិធម៌ ក្រោយពីកម្ពុជាបដិសេធចោលសំណើរបស់អង្គការសហប្រជាជាតិ ។ ស្ទើរតែរាល់ពេល ការចរចាហាក់ដូចជាបរាជ័យ ប៉ុន្តែអង្គការសហប្រជាជាតិនិងកម្ពុជាស្ថិតនៅក្រោមសម្ពាធរបស់រដ្ឋមួយចំនួនជាសមាជិករបស់អង្គការសហប្រជាជាតិឲ្យវិលត្រឡប់ទៅរកតុចរចាវិញ ។ រឹតរួតទៅដោយការទទួលខុសត្រូវរបស់ខ្លួននៅក្នុងការគាំទ្រខ្មែរក្រហមបន្ទាប់ពីការឈ្លានពានរបស់ប្រទេសវៀតណាមនៅឆ្នាំ១៩៧៩ អង្គការសហប្រជាជាតិបានសម្រុះសម្រួលដោយជោគជ័យទាក់ទងទៅនឹងសារជាតិរបស់តុលាការ (ផ្នែកទី៣) និងរចនាសម្ព័ន្ធរបស់តុលាការ (ផ្នែកទី ៤) ។ នៅទីបញ្ចប់ ការមូលមតិគ្នាហាក់ដូចជាបានសម្រេចកាលពីខែកក្កដា ឆ្នាំ២០០០ ខណៈពេលដែលក្រុមចរចារបស់អង្គការសហប្រជាជាតិចាកចេញពីទីក្រុងភ្នំពេញដោយពាំនាំយកទៅជាមួយនូវសេចក្តីព្រាងអនុស្សរណៈយោគយល់ពាក់ព័ន្ធទៅនឹង “កិច្ចសហប្រតិបត្តិការអន្តរជាតិដ៏មានសារសំខាន់” នៅក្នុងដំណើរការជម្រះក្តីក្នុង “អង្គជំនុំជម្រះវិសាមញ្ញ” នៅក្នុងតុលាការកម្ពុជា ។ នៅទីបញ្ចប់ ច្បាប់តុលាការខ្មែរក្រហមត្រូវបានអនុម័តនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដើម្បីបង្កើតអង្គជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ក៏ប៉ុន្តែច្បាប់នេះមិនស្របទាំងស្រុងទៅនឹងសេចក្តីព្រាងអនុស្សរណៈយោគយល់ជាលក្ខន្តិកៈផ្លូវច្បាប់ពិតប្រាកដដែលបន្ទាប់មកបានក្លាយទៅជាឆ្អឹងខ្នងទីឯក (ផ្នែកទី៥) ។ ដោយសារតែគ្មានភាពរីកចម្រើននៅក្នុងដំណើរការនេះ និងដោយសារតែបញ្ហាប្រទាំងប្រទើសផ្សេងៗទៀត លោកអគ្គលេខាធិការបានទាញអង្គការសហប្រជាជាតិចេញពីការចរចានៅខែកុម្ភៈឆ្នាំ២០០២ ។ ទោះជាយ៉ាងណាក៏ដោយ មហាសន្និបាតអង្គការសហប្រជាជាតិបានចាប់ផ្តើមអាណត្តិថ្មីមួយទៀតដើម្បីចរចាដោយឈរលើមូលដ្ឋានច្បាប់តុលាការ ។ នៅខែមីនា ឆ្នាំ២០០៣ កិច្ចព្រមព្រៀងដែលត្រូវបានធ្វើវិសោធនកម្មរួចហើយ បានចូលមកជំនួសសេចក្តីព្រាងអនុស្សរណៈយោគយល់ និងត្រូវបានយកមកចរចាតាមទម្រង់ផ្សេងៗសំដៅដោះស្រាយការព្រួយបារម្ភរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (កិច្ចព្រមព្រៀងឆ្នាំ២០០៣) ។ កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាជាផ្លូវការដោយភាគីទាំងពីរកាលពីខែមិថុនា ឆ្នាំ២០០៣ ក៏ប៉ុន្តែត្រូវបានផ្តល់សច្ចាប័នដោយកម្ពុជា និងត្រូវតែទទួលបានការរួមចំណែកស្ម័គ្រចិត្តគ្រប់គ្រាន់មុនពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្លាយទៅជាការពិត (ផ្នែកទី៦) ។

ការពិនិត្យមើលឡើងវិញនូវដំណើរការនេះក៏បានផ្តល់នូវមូលដ្ឋានសម្រាប់ការអត្ថាធិប្បាយទាក់ទិនទៅនឹងកម្រិតដែលសំណើខុសៗគ្នាអាចផ្តល់យុត្តិធម៌ដ៏មានខ្លឹមសារ និងរួមចំណែកដល់ការផ្សះផ្សាជាតិនៅក្នុងបរិបទប្រទេសកម្ពុជា ។ ដើម្បីសម្រេចគោលបំណងនេះ ជាដំបូង អត្ថបទនេះនឹងគូសបញ្ជាក់អំពីកម្រិតដែលបទពិសោធន៍របស់ប្រជាជនកម្ពុជានឹងត្រូវយកមកវែកញែក (ផ្នែកទី២) ។ អត្ថាធិប្បាយដែលបានផ្តល់មកអំពីដំណើរការតាមការរំពឹងទុកពាក់ព័ន្ធទៅនឹងបទពិសោធន៍បែបនេះនៅក្នុង

យុត្តិធម៌ចម្រុះ តម្រូវឲ្យមានភាពស្ទាត់ជំនាញខាងច្បាប់អន្តរជាតិ ក៏ដូចជាច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ច្បាប់ធម្មនុញ្ញអង្គការសហប្រជាជាតិ ព្រមទាំងច្បាប់និងនីតិវិធីឧក្រិដ្ឋកម្មរបស់កម្ពុជា និងគោលការណ៍រដ្ឋធម្មនុញ្ញផង ។ ជាការច្បាស់ណាស់ថា បើពិនិត្យមើលអត្ថាធិប្បាយនេះ សំណួរមួយចំនួននៅមិនទាន់អាចឆ្លើយបាននៅឡើយ ។ ក្នុងភាពសមសួនជាងមុន អត្ថបទនេះមានគោលបំណងរកឲ្យឃើញនូវសំណួរខ្លះៗដែលនឹងទទួលបានការដោះស្រាយពីតុលាការណាមួយដែលបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម និងវិភាគទៅលើសមត្ថភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការផ្ដល់នូវយុត្តិធម៌ដ៏ប្រាកដប្រជាមួយ ។

## ២) គោលបំណងរបស់យុត្តិធម៌អន្តរជាតិ

ជាទូទៅ គោលបំណងរបស់យុត្តិធម៌អន្តរជាតិមានលក្ខណៈដូចគ្នាទៅនឹងគោលបំណងរបស់យុត្តិធម៌ជាតិ គឺៈ បង្កើតការពិតទាក់ទងទៅនឹងអំពើដែលរំលោភទៅលើកិច្ចសន្យាសង្គម, ដាក់ទោសអ្នកដែលទទួលខុសត្រូវ, ទប់ស្កាត់ការកើតឡើងសាជាថ្មីនៅពេលអនាគត និងផ្ដល់សំណងដល់ជនរងគ្រោះ (ប៉ុន្ដែចំណុចចុងក្រោយនេះមិនសូវទូទៅប៉ុន្មានទេ) ។ ទោះជាយ៉ាងណាក៏ដោយ គោលបំណងទាំងអស់នេះបានទទួលយកខ្នាតថ្មីមួយនៅក្នុងបរិបទអន្តរជាតិ ហើយសារសំខាន់នេះគឺមិនចាំបាច់ដូចគ្នាទេ ។ ជាពិសេសប្រការនេះគឺជាលទ្ធផលនៃការពិតដែលថា បន្ទាប់ពីមានឧក្រិដ្ឋកម្មអន្តរជាតិ នឹងមានបញ្ហានៃការបង្កើតឡើងវិញនូវកិច្ចសន្យាសង្គមច្រើនជាងថែរក្សាកិច្ចសន្យាសង្គម ដែលជារឿយៗជាផ្នែកមួយនៃប្រតិបត្តិការសន្តិភាពក្រោយពីមានជម្លោះធំធេងជាអន្តរជាតិ ។ ជាងនេះទៅទៀត ទស្សនៈនៃឧក្រិដ្ឋកម្មអន្តរជាតិនាំឲ្យមានសណ្ដាប់ធ្នាប់ខាងសីលធម៌ជាអន្តរជាតិដែលត្រូវតែថែរក្សា និងដែលនាំឲ្យមានការផ្លាស់ប្ដូរ “ច្បាប់ទំនាក់ទំនងនិងភាពស្របច្បាប់ជាអន្តរជាតិទូលំទូលាយជាងមុន” ។

### ក) ការបង្កើតការពិត

បើពិនិត្យមើលសារជាតិនៃឧក្រិដ្ឋកម្មអន្តរជាតិ ជារឿយៗ “ការពិត” ប្រែប្រួលទៅតាមនយោបាយ ។ នៅក្នុងប្រទេសកម្ពុជា ប្រកបចូលទៅដល់ការពិតពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហមជានិច្ចកាលស្ថិតនៅក្រោមអត្ថិភាពនយោបាយ ។ បន្ទាប់ពីបានទទួលពត៌មានដ៏ច្រើនសន្ធឹកសន្ធាប់ទាក់ទងទៅនឹងរបបខ្មែរក្រហមនៅក្នុងចន្លោះឆ្នាំ១៩៧៩និង១៩៩១ ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៅក្នុងការកាន់កាប់របស់វៀតណាម ការសិក្សាអំពីចន្លោះពេលនេះត្រូវបានលុបចេញពីកម្មវិធីសិក្សានៅតាមសាលាក្រោយពីមានអន្តរាគមន៍របស់អង្គការសហប្រជាជាតិដែលតាមការអះអាងថាដើម្បីលើកកម្ពស់ការផ្សះផ្សាជាតិនិងចៀសវាងការសងសឹក ។ ទោះជាយ៉ាងណាក៏ដោយ ការពិតទាក់ទងនឹងឧក្រិដ្ឋកម្មបែបនេះមានសារសំខាន់ចំពោះការផ្សះផ្សាជាតិដ៏ជោគជ័យមួយ ជាពិសេសនៅទីណាដែលមានជនរងគ្រោះបាត់ខ្លួន ។

ចេញពីចក្ខុវិស័យនេះ មធ្យោបាយដែលយកមកប្រើមិនសូវសំខាន់ដូចលទ្ធផលទេៈ សិទ្ធិទទួលបាននូវពត៌មានពិត ។ ទោះជាយ៉ាងណាក៏ដោយ ការចូលពាក់ព័ន្ធរបស់អន្តរជាតិអាចរួមចំណែកដល់ទិសដៅនេះ ព្រោះថា បើពិនិត្យមើលទំហំនៃអំពើឧក្រិដ្ឋដែលពាក់ព័ន្ធពិតជាពិបាកប្រសិនបើមិនអាចរកបានបុគ្គលិកក្នុងតំបន់ដែលមានសមត្ថភាពនិងមិនជាប់ពាក់ព័ន្ធជាមួយនឹងជនរងគ្រោះឬជនដៃដល់ទោះជាក្នុងរបៀបណាក៏ដោយ ។

ការលាតត្រដាងការពិតទាក់ទងទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិក៏អាចបម្រើសេចក្ដីត្រូវការរបស់សហគមន៍អន្តរជាតិដើម្បីថ្កោលទោសឧក្រិដ្ឋកម្មដែលហួសពីព្រំដែនជាតិ ។ វាជាការច្បាស់ណាស់ ការចូលពាក់ព័ន្ធរបស់អន្តរជាតិនៅក្នុងដំណើរការរកឲ្យឃើញការពិត នឹងបំពេញបានប្រសើរជាងមុននូវតម្រូវការនេះដើម្បីបង្ហាញឲ្យឃើញអំពើឃោរឃៅនៅលើលោកនេះ ។

គួរកត់សម្គាល់តាំងពីដំបូងមកថា គំនិតបង្កើតគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាក្នុងទម្រង់ស្រដៀងទៅនឹងដំណើរការផ្លូវច្បាប់ មិនត្រូវបានយកមកពិភាក្សាឲ្យបានម៉ត់ចត់ដើម្បីជាមធ្យោបាយសម្រាប់បំពេញតម្រូវការដែលហាក់ដូចជាឆ្គងគ្នាបន្តិចនៅក្នុងប្រទេសកម្ពុជា ដែលចង់បានរកការពិត ការផ្សះផ្សានិងយុត្តិធម៌ ។ កត្តាមួយចំនួនប្រហែលជាអាចជួយពន្យល់ករណីនេះបាន ។ ម្យ៉ាង ខណៈពេលដែលមិនអាចប្រកែកបានដែលថាដំណើរការតុលាការមិនមែនជាមធ្យោបាយប្រសើរបំផុតក្នុងការលាតត្រដាងការពិតជាប្រវត្តិសាស្ត្រទាក់ទងទៅនឹងអំពើឧក្រិដ្ឋកម្មកាលពីអតីតកាល ការសិក្សាដ៏ម៉ត់ចត់ខាងប្រវត្តិសាស្ត្រខ្មែរ

ក្រហមបានបញ្ជាក់រួចហើយអំពីសារជាតិឧក្រិដ្ឋរបស់របបនេះ ។ ព័ត៌មានប្រវត្តិសាស្ត្រទាំងនេះត្រូវបានបំពេញបន្ថែមដោយភ័ស្តុតាងដ៏សម្បូរបែបដែលប្រមូលផ្តុំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ពាក់ព័ន្ធនឹងការទទួលខុសត្រូវជាបុគ្គលរបស់ថ្នាក់ដឹកនាំខ្មែរក្រហម ។ ម្យ៉ាងវិញទៀត បើពិនិត្យមើលទម្ងន់នៃអំពើឧក្រិដ្ឋដែលត្រូវយកមកលាតត្រដាង វាច្បាស់ណាស់ថា ដំណោះស្រាយអាចទទួលយកបានណាមួយត្រូវតែមានការយល់ព្រមពីឧក្រិដ្ឋជន ។ ជាការពិត មិនត្រឹមតែដំណោះស្រាយក្រៅតុលាការទេ ដែលមិនអាចសម្រេចបាននូវសេចក្តីរំពឹងរបស់ជនរងគ្រោះ និងប្រទេសកម្ពុជាព្រមទាំងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ សូម្បីតែប្រព័ន្ធណាមួយដែលស្នើសុំឲ្យមានការលើកលែងទោសដើម្បីជាថ្នូរនឹងការពិត ក៏ទំនងជានឹងរំលោភលើកាតព្វកិច្ចជាអន្តរជាតិរបស់ប្រទេសកម្ពុជាក្នុងការទប់ស្កាត់និងដាក់ទោសឧក្រិដ្ឋកម្មអន្តរជាតិដែរ ។ ក្នុងករណីណាមួយក៏ដោយ ការប្រកាសសម្តងម្កាលរបស់ជនជាប់ចោទដែលមានសក្តានុពលបានបង្ហាញច្បាស់ថា ខណៈពេលដែលមនុស្សមួយចំនួនត្រៀមខ្លួនស្វះស្វែងរកការលើកលែង “ទោសកំហុស” ពីអតីតកាល ជាទូទៅអ្នកទាំងនោះបែរជាបដិសេធមិនទទួលស្គាល់អំពើឧក្រិដ្ឋទៅវិញ ពោលគឺគ្រាន់តែបង្ហាញចេញនូវវិប្បដិសារីដ៏តិចតួច និងអះអាងថាមិនបានដឹងសេចក្តីសម្រេចចិត្តផ្នែកនយោបាយដែលធ្វើឡើងដោយ ប៉ុល ពត នោះទេ ។

ខ្ញុំសូមលើកយកឧទាហរណ៍មួយមកបញ្ជាក់ ។ មានការទទួលស្គាល់ជាទូទៅថា ចាប់ពីឆ្នាំ១៩៧៦ គោលនយោបាយកម្ចាត់ “សមាសភាពប្រតិកិរិយា” បានបណ្តាលឲ្យប្រជាជនស្លាប់កាន់តែច្រើនឡើងៗ ហើយល្បឿននៃការសម្លាប់ក៏កាន់តែកើនឡើងដែរ ។ មានទស្សនៈមួយចំនួនខុសប្លែកពីហេតុផលពិតប្រាកដនៃហេតុការណ៍នេះ នោះគឺការភ័យខ្លាចដ៏ឆ្កួតលេលាប៉ុន្តែមានពិតប្រាកដអំពីការជ្រៀតចូលរបស់កម្លាំងប្រឆាំងបដិវត្តន៍ ឬស្វែងរកអ្នកដទៃមកទទួលកំហុសដើម្បីគេចវេះពីសារភាពអំពីបរាជ័យរបស់បដិវត្តន៍ស្រេចម្ការនិងការប្រឆាំងផ្ទៃក្នុងដ៏ស្ងប់ស្ងាត់ ។ បន្ថែមពីនេះទៀត ភាពមិនច្បាស់លាស់នៅតែមានអំពីថាតើនរណាជាអ្នកទទួលខុសត្រូវពិតប្រាកដចំពោះការផ្លាស់ប្តូរគោលនយោបាយ ។ ការពន្យល់អំពីគោលបំណងនៅពីក្រោយគោលនយោបាយទាំងអស់នេះនឹងមិនគ្រាន់តែជួយទប់ស្កាត់នូវស្នាកស្នាមដែលចេះតែបន្តរបស់អ្នកទទួលកំហុសជាប្រពៃណីរបស់ប្រទេសកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងជះឥទ្ធិពលដល់ចរិតលក្ខណៈនៃអំពើឧក្រិដ្ឋនៅក្នុងច្បាប់អន្តរជាតិ និងការកំណត់ការទទួលខុសត្រូវរបស់បុគ្គលថែមទៀត ។ មានតែតាមរយៈដំណើរការឯករាជ្យយ៉ាងម៉ត់ចត់ទាក់ទិនទៅនឹងចម្លើយកសិណផ្ទាល់ចេញពីអ្នកដែលពាក់ព័ន្ធជាមួយអ្នកថ្នាក់ខ្ពស់ៗស្ថិតក្នុងឋានានុក្រមខ្មែរក្រហមទេ ទើបអាចមានលទ្ធភាពពន្យល់បានច្បាស់ចំពោះសំណួរបែបនេះ ។

### ១) ការដាក់ទោស

ជាទូទៅ ទោះជាការញុះញង់របស់រដ្ឋមិនមែនជាសមាសធាតុរួមផ្សំក្នុងឧក្រិដ្ឋកម្មអន្តរជាតិក៏ដោយ ក៏នៅក្នុងករណីជាច្រើនមានការញុះញង់កើតឡើងដែរ ។ ក៏ប៉ុន្តែ គំនិតបង្កើតឲ្យមានការទទួលខុសត្រូវលើបទឧក្រិដ្ឋកម្មអន្តរជាតិរបស់អ្នកតំណាងរដ្ឋនៅតែខុសប្លែកគ្នាយ៉ាងខ្លាំងទៅនឹងការអនុវត្តន៍ក្នុងវិស័យការទូតកាលពីមុនទសវត្សរ៍ឆ្នាំ១៩៩០ ដែលមេធាវីអន្តរជាតិនៅតែមិនយល់ស្របអំពីថាតើមានច្បាប់ទំនៀមទម្លាប់ដែលបានផ្តល់ភាពគ្មានទោសនៅក្នុងយុត្តាធិការដែរឬទេ ហើយបើមាន តើមានករណីលើកលែងនៅក្នុងករណីបទឧក្រិដ្ឋកម្មអន្តរជាតិដែរឬទេ ។ សេចក្តីសម្រេចចិត្តរបស់តុលាការយុត្តិធម៌អន្តរជាតិ *(ICJ)* នៅក្នុងករណីដីកាចាប់ខ្លួននាពេលថ្មីៗនេះបានធ្វើឡើងថា ភាពគ្មានទោសពៃរ៍នៅក្នុងយុត្តាធិការមិនបានលើកឡើងនៅចំពោះមុខតុលាការអន្តរជាតិសុទ្ធសាធនោះទេ ក៏ប៉ុន្តែបើកចំហចំពោះភាពគ្មានទោសពៃរ៍ក្រោមរដ្ឋធម្មនុញ្ញក្នុងស្រុកស្ថិតនៅក្រោមដំណើរការជម្រះក្តីជាតិ ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ មានគំរូជាច្រើនស្តីអំពីការចោទប្រកាន់ជាលក្ខណៈជាតិនៅក្នុងរឿងក្តីបែបនេះបានជាប់ពាក់ព័ន្ធជាមួយនឹងអតីតមេដឹកនាំដែលជារឿយៗមានរយៈពេលជាច្រើនឆ្នាំបន្ទាប់ ។

ទោះជាយ៉ាងណាក៏ដោយ គោលបំណងមួយរបស់យុត្តិធម៌អន្តរជាតិត្រូវតែជួយសម្រួលដល់ការបណ្តេញចេញពីអំណាចនូវអ្នកទាំងឡាយណាដែលអនុវត្តគោលនយោបាយឧក្រិដ្ឋ ។ ជាងនេះទៅទៀត ការបង្កើតការទទួលខុសត្រូវរបស់បុគ្គលចំពោះទស្សនៈ

និងការអនុវត្តឧក្រិដ្ឋកម្មបែបនេះ នឹងអាចបញ្ចប់នូវ«ភាពព្រឺព្រួច» ជាសមូហភាពរបស់ជាតិសាសន៍ទាំងមូល ក្រុមជនជាតិ ឬ ក្រុមនយោបាយ ។ ដូច្នេះនឹងអាចត្រៀមឲ្យមានការធ្វើសមាហរណកម្មចូលទៅក្នុងសង្គមដែលមានសមាជិកស្មោះត្រង់ ។ ប្រសិនបើមិនធ្វើដូចនេះទេ អតីតមេដឹកនាំដូចជា ស្លូបូដាន មីឡូសឺវិក នឹងនៅតែបង្ហាញថាខ្លួនជាទុក្ករបុគ្គលចំពោះ«ប្រជាជន»របស់ខ្លួនដដែល ។

ទោះជាយ៉ាងណាក៏ដោយ តុលាការអន្តរជាតិយល់ឃើញថាមានការលំបាកក្នុងការដាក់ឲ្យជនដៃដល់ថ្នាក់ក្រោមទទួលខុសត្រូវពីបទឧក្រិដ្ឋកម្មអន្តរជាតិ ដោយសារតែជនដៃដល់ទាំងអស់នោះមានចំនួនច្រើនពេក និងដោយសារតែមានការលំបាកក្នុងការបង្ហាញឲ្យឃើញពីគោលបំណងជាក់លាក់របស់អ្នកទាំងនោះក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានណែនាំដល់តុលាការអន្តរជាតិពិសេសទាំងពីរថា «មេដឹកនាំស៊ីវិល យោធា និងទាហានប៉ារ៉ា គួរតែទទួលការកាត់ទោសនៅចំពោះមុខថ្នាក់ក្រោម» ។ ជម្រើសប្រភេទនេះមិនចាំបាច់ផ្ទុយទៅនឹងគោលការណ៍នៃការដាក់ទោសទណ្ឌ តាមបែបប្រព័ន្ធទេ ដរាបណាការជំនុំជម្រះអន្តរជាតិផ្តល់នូវមូលដ្ឋានសម្រាប់ការចោទប្រកាន់ក្នុងស្រុក ។ នេះហាក់ដូចជាការបែងចែកភារកិច្ចដ៏សមហេតុផលរវាងសហគមន៍អន្តរជាតិនិងប្រជាជនរបស់ប្រទេសដែលមានអំពើឧក្រិដ្ឋកើតឡើងដោយអនុញ្ញាតឲ្យប្រជាជនទទួលខុសត្រូវមួយផ្នែកក្នុងការដោះស្រាយជាមួយអតីតកាលរបស់ខ្លួន ។ ខណៈដែលមធ្យោបាយនេះជាទឡ្ហីករណ៍គាំទ្រឲ្យមានការបង្កើតតុលាការក្នុងស្រុកដែលមានលក្ខណៈអន្តរជាតិ គួរតែប្រុងប្រយ័ត្នដើម្បីចៀសវាងនូវជម្រើសណាដែលនាំឲ្យមានការលើកលែងទោសតាមជាក់ស្តែងឬតាមផ្លូវច្បាប់ចំពោះជនដៃដល់ដែលស្ថិតនៅក្រោយុត្តាធិការរបស់តុលាការអន្តរជាតិ ។

## គ) ការទប់ស្កាត់

បើពិនិត្យមើលការពិតដែលប្រមូលបាន (ជាទូទៅដឹកនាំដោយរដ្ឋ) ភាគច្រើនស្តីអំពីបទឧក្រិដ្ឋកម្មអន្តរជាតិ សំណួរគឺថា តើយុត្តិធម៌អន្តរជាតិអាចទប់ស្កាត់ «អំពើហិង្សាទ្រង់ទ្រាយធំដែលញុះញង់ដោយអ្នកមានអំណាច» បានដែរឬទេ? ឬយ៉ាងហោចណាស់អាចទប់ស្កាត់ការកើតឡើងសាជាថ្មីនូវសភាពការណ៍ក្រោយជម្លោះដែរឬទេ? បើប្រៀបធៀបជាមួយនឹងយុត្តិធម៌ក្នុងស្រុក យុត្តិធម៌អន្តរជាតិមានមធ្យោបាយជាច្រើនដើម្បីទប់ស្កាត់ ។ វិធានការប្រកបដោយប្រសិទ្ធភាពរបស់ប៉ូលិសអាចទទួលបាននូវអត្ថិភាពតិចជាងការអប់រំខាងគោលការណ៍សិទ្ធិមនុស្សសម្រាប់អ្នកដែលប្រើប្រាស់កម្លាំងជាសាធារណៈ និងផ្តល់នូវការត្រួតពិនិត្យដ៏មានប្រសិទ្ធភាពខាងតុលាការទៅលើក្រុមដែលគាំទ្រទស្សនវិជ្ជាឧក្រិដ្ឋកម្ម រាប់បញ្ចូលទាំងភាគីនយោបាយផង ។ គោលដៅគឺត្រូវបញ្ជាក់ឲ្យបានច្បាស់ថា សហគមន៍អន្តរជាតិនឹងលែងចាត់ទុកគំនិតដែលថា «ឧក្រិដ្ឋកម្មអន្តរជាតិជាឧបករណ៍គ្រប់គ្រងរបស់រដ្ឋនិងនយោបាយ» ជាការព្រួយបារម្ភផ្ទៃក្នុងសុទ្ធសាធទៀតហើយ ។ បើតាមការអះអាង ការចាក់គ្រឹះកាន់តែជឿនលឿនឡើងនូវគោលការណ៍បែបនេះ គ្មានប្រសិទ្ធភាពនោះទេ ប្រសិនបើគ្មាន«វិធានការដាក់ទោសទណ្ឌដ៏គួរឲ្យទុកចិត្តបាន» ។ ការបណ្តេញចេញនូវមេដឹកនាំស្រេកឃ្លានអំណាចដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មបែបនេះតាមរយៈដំណើរការតុលាការជាជាងតាមមធ្យោបាយនយោបាយឬយោធា ទំនងជាមិនសូវនាំឲ្យមានការបន្តនូវជម្លោះហិង្សាឬការបន្តគ្រប់គ្រង«នៅពីខាងក្រោយ» ដោយបុគ្គលដដែលឡើយ ។ ការស្វែងរកយុត្តិធម៌ដ៏ប្រញាប់ប្រញាល់មួយគួរតែមានលក្ខណៈអំណោយផលច្រើនចំពោះការអប់រំកសាងឡើងវិញនៅទីបញ្ចប់សម្រាប់ជនប្រព្រឹត្តល្មើសជាពិសេសខណៈពេលដែលជនប្រព្រឹត្តល្មើសទាំងអស់នោះមិនទាន់ចាស់ជ្រេល ។

នៅពេលដែលអវត្តមានតុលាការឧក្រិដ្ឋកម្មអន្តរជាតិអចិន្ត្រៃយ៍ណាមួយ តួនាទីទប់ស្កាត់របស់យុត្តិធម៌អន្តរជាតិនឹងចុះខ្សោយដោយសារតែការក្រុមប្រឹក្សាសន្តិសុខឬភាគីរដ្ឋដែលឈ្នះមានបំណងផ្តល់យុត្តាធិការសកលចំពោះតុលាការជាតិ ។ ច្បាស់ណាស់ថា ការបង្កើតជាបន្ទាន់នូវតុលាការអន្តរជាតិចំនួនពីរសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉្វាន់ដា «មិនអាចរំពឹងថានឹងមានការប្រែក្លាយភ្លាមៗពីវប្បធម៌រួចទោសដែលចាក់គ្រឹះយ៉ាងមាំទៅរកការគោរពច្បាប់ដ៏ជាប់លាប់មួយនោះទេ» ។ បើពិនិត្យមើលឧក្រិដ្ឋកម្មអន្តរជាតិនៅកន្លែងផ្សេងៗក្នុងអំឡុងពេលដូចគ្នាដែលមិនមានការកាត់សេចក្តី ទស្សនៈយុត្តិធម៌ដែលបាន

ជ្រើសរើសយកនេះហាក់ធ្វើឲ្យចុះខ្សោយដល់ការគោរពច្បាប់ ។ បញ្ហាមួយទៀតដែលប៉ះពាល់ដល់កម្លាំងទប់ស្កាត់របស់តុលាការអន្តរជាតិគឺថា "តុលាការនេះមានចេតនាស្ថិតនៅក្នុងទីតាំងតែមួយដែលប្រហែលជានៅក្នុងប្រទេសមួយដែលឆ្ងាយពីចុងចោទ សាក្សីនិងសាធារណជនដែលទទួលផលប៉ះពាល់ផ្ទាល់ ។ ធ្វើដូច្នេះនាំឲ្យការផ្សព្វផ្សាយជាសាធារណៈនៅតាមមូលដ្ឋានប្រព្រឹត្តទៅបានតិច ហើយការចូលរួមនៅក្នុងដំណើរការជំនុំជម្រះក្តីក៏មានកម្រិតតិចតួច ។ សេចក្តីសម្រេចចិត្តជាអន្តរជាតិទំនងជាអាចបង្កើតបានច្រើននូវគោលការណ៍សម្រាប់មនុស្សជំនាន់ក្រោយ ដាក់ស្តែងដូចជានៅតុលាការនូរីមប៊ឺក ក៏ប៉ុន្តែដំណើរការជំនុំជម្រះជាលក្ខណៈជាតិទំនងជាជួយពង្រឹងបានច្រើននូវវប្បធម៌យុត្តិធម៌ក្រោយជម្លោះសម្រាប់ឧក្រិដ្ឋកម្មធម្មតា ជាពិសេសប្រសិនបើនីតិវិធីដែលប្រកាន់យកអាចត្រូវបានផ្លាស់ប្តូរទៅវិញទៅមកតាមប្រព័ន្ធតុលាការក្នុងស្រុកក្នុងពេលក្រោយៗមកទៀត ។

ភាពខុសគ្នាមួយរវាងការទទួលខុសត្រូវជាអន្តរជាតិនិងការទទួលខុសត្រូវជាលក្ខណៈជាតិគឺថា ជារឿយៗការជំនុំជម្រះក្នុងស្រុកត្រូវបានធ្វើឡើងបន្ទាប់ពីមានអំពើឧក្រិដ្ឋកម្ម លើកលែងតែករណីយុត្តិធម៌របស់អ្នកឈ្នះ (ដែលមិនគោរពគោលការណ៍អន្តរជាតិ) ។ម្យ៉ាងវិញទៀត ការអនុវត្តនៅក្នុងប្រព័ន្ធយុត្តិធម៌អន្តរជាតិក្នុងពេលថ្មីៗនេះបានឆ្លើយតបទៅនឹងតម្រូវការបន្ទាន់របស់សាធារណជន ។ អត្ថិភាពនៃការគំរាមកំហែងចំពោះសន្តិភាពនិងសន្តិសុខអន្តរជាតិក្នុងពេលបច្ចុប្បន្ននេះគឺជាវិធានការចម្បងរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ ទោះជាយ៉ាងណាក៏ដោយ តុលាការមិនគួរយកសកម្មភាពបន្ទាន់បែបនេះមកប្រើជំនួសឲ្យវិធានការដាក់ស្តែងដើម្បីបញ្ចប់អំពើហិង្សានោះទេ ។

សភាពការណ៍នៅក្នុងប្រទេសកម្ពុជាមានចំណុចសំខាន់មួយខុសប្លែកពីតុលាការអន្តរជាតិពិសេស (នៅអតីតយូហ្គោស្លាវីនិងរ៉ាន់ដា) និងខុសប្លែកពីតុលាការក្នុងស្រុកដទៃៗទៀតដែលមានលក្ខណៈអន្តរជាតិ (នៅទីម័រខាងកើតនិងសៀរ៉ាឡេអូន ឬប្រហែលជានឹងកើតមាននៅកូសូវ៉ូ) ។ ចំណុចខុសប្លែកនោះគឺ អំពើឧក្រិដ្ឋកម្មបានបញ្ចប់អស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ចាប់តាំងពីពេលនោះមក អង្គការសហប្រជាជាតិបានខិតខំប្រឹងប្រែងជាពិសេសដើម្បីពង្រឹងការគោរពច្បាប់នៅក្នុងប្រទេសកម្ពុជាតាមរយៈប្រតិបត្តិការថែរក្សាសន្តិភាពដែលមិនធ្លាប់មានពីមុនមក ហើយក្រោយមកបានបង្កើតឲ្យមានក្រុមអចិន្ត្រៃយ៍ដំបូងបង្អស់សម្រាប់ឃ្លាំមើលសិទ្ធិមនុស្ស ដែលមានឈ្មោះថា "មជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា" ។ ការបង្កើតមជ្ឈមណ្ឌលនេះបានទទួលការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ។ ជាពិសេសអង្គការក្រៅរដ្ឋាភិបាលបានដាក់សម្ពាធទៅលើរដ្ឋជាម្ចាស់ជំនួយដែលចងគ្នាជាក្រុម ដើម្បីឲ្យមានការគោរពសិទ្ធិមនុស្សជាទូទៅ និងដាក់ឲ្យមានការទទួលខុសត្រូវរបស់ខ្មែរក្រហមនៅលើរបៀបវារៈកំណែទម្រង់ខ្ពស់បំផុត ។ ភ័ស្តុតាងជាក់ស្តែងបានបង្ហាញថា ការរួចទោសរបស់ខ្មែរក្រហមបានបណ្តាលឲ្យកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះមិនបានទទួលលទ្ធផលល្អ ហើយជះឥទ្ធិពលទៅលើបរិយាកាសរាលដាលនៃភាពរួចទោស ។ ជាការពិតគឺលំបាកក្នុងការបង្ហាញឲ្យឃើញពីភាពត្រឹមត្រូវក្នុងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរួម ប្រសិនបើគ្មានការតាំងចិត្តណាមួយក្នុងការដាក់ទោសទណ្ឌដល់អ្នកដែលទទួលខុសត្រូវចំពោះភាពធ្ងន់ធ្ងរបំផុតនៃអំពើឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងកាលពីអតីតកាល ។

បញ្ហាក៏នឹងកើតឡើងដែរនៅពេលដែលការផ្សះផ្សាជាតិមិនត្រូវបានមើលឃើញថាជាគុណប្រយោជន៍ ប៉ុន្តែបែរជាមើលឃើញថាជាគោលបំណងចម្បងនៃដំណើរការតុលាការ ។ ការចោទប្រកាន់ដែលត្រូវបានដាក់កម្រិតនៅក្នុងលក្ខខណ្ឌបែបនេះនឹងគ្រាន់តែទទួលបានមកវិញនូវ"ការបិទរឿងក្តីបែបបំភ័ន្តភ្នែក" តាមរយៈ "ដំណើរការផ្លូវច្បាប់" ។ ការព្យាយាមពីមុនៗមកដើម្បីនាំខ្មែរក្រហមឡើងតុលាការនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៩និងឆ្នាំ១៩៩៨ បានទទួលជោគជ័យខ្លះៗក្នុងការបញ្ចប់នូវជម្លោះប្រដាប់អាវុធពេញបន្ទុក តាមរយៈការនាំយកអតីតអ្នកប្រយុទ្ធខ្មែរក្រហម"ចូលមកក្នុងសង្គមជាតិ" ដែលធ្វើឲ្យខូចប្រយោជន៍ដល់ទិសដៅយុត្តិធម៌ផ្សេងៗទៀត និងខកខានមិនអាចសម្រេចបាននូវការផ្សះផ្សាជាតិ ។ បរាជ័យរបស់រាជរដ្ឋា-ភិបាលក្នុងការផ្សះផ្សាតាមរយៈការលើកលែងទោសនិងលើកកម្ពស់ការគោរពសិទ្ធិមនុស្ស បានពង្រឹងកណ្តាប់ដៃរបស់អ្នកដែលទទួច

សុំឲ្យមានយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា ។

### ឃ) ការផ្តល់សំណង

តាមទម្លាប់ នៅក្នុងការចោទប្រកាន់ជាសាធារណៈចំពោះអំពើឧក្រិដ្ឋជារួម ការផ្តល់សំណងដល់ជនរងគ្រោះមិនមែនជាអត្ថិភាពចម្បងនោះទេ ។ ប្រសិនបើការដាក់ទោសជនប្រព្រឹត្តបទល្មើសមិនគ្រប់គ្រាន់សម្រាប់ជនរងគ្រោះ បណ្តឹងផ្លូវច្បាប់ជាលក្ខណៈឯកជនអាចនឹងត្រូវធ្វើឡើងដើម្បីស្វែងរកការសងជំងឺចិត្ត ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងប្រទេសដែលមានច្បាប់ស៊ីវិលដែលមើលឃើញសារសំខាន់របស់ជនរងគ្រោះនៅក្នុងប្រព័ន្ធច្បាប់មួយចំនួន ប្រហែលជាមានការប្រាប់បញ្ចូលគ្នានូវដំណើរការទាំងពីរនេះ មិនមែនមើលឃើញតែលុយសុទ្ធសាធនោះទេ ។ ឥឡូវនេះមានការទទួលស្គាល់ជាទូទៅថា ជនរងគ្រោះបានស្គាល់អំពើឧក្រិដ្ឋថាជាការរំលោភទៅលើភាពស្មើគ្នាក្រោមកិច្ចសន្យាសង្គម ដែលរាំងខ្ទប់សមត្ថភាពរបស់ជនរងគ្រោះក្នុងការចូលរួមឲ្យបានពេញទំហឹងនៅក្នុងសង្គម ។ នៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដំណើរការតុលាការអាចផ្តល់ដល់ជនរងគ្រោះនូវ "និមិត្តរូបនៃការរស់ឡើងវិញ" ដែលជនរងគ្រោះសង្ឃឹមថាយុត្តិធម៌នឹងធ្វើឲ្យគាត់"ក្លាយជាមនុស្សឡើងវិញ" ។ មធ្យោបាយមួយដ៏មានសារសំខាន់នៅក្នុងការបំពេញសេចក្តីប៉ងប្រាថ្នានេះគឺត្រូវ "បញ្ជូនជនរងគ្រោះឲ្យទៅតតាំងគ្នាទៅវិញទៅមកតាមផ្លូវច្បាប់" តាមរយៈ "ការប្រគល់មកវិញនូវអំណាចដើម្បីចាត់វិធានការ" ។ វាហាក់ដូចជាថា ការចូលរួមបង្កើតឲ្យមានការទទួលខុសត្រូវជាលក្ខណៈបុគ្គលសម្រាប់បទឧក្រិដ្ឋកម្មទ្រង់ទ្រាយធំអាចជួយជនរងគ្រោះឲ្យទាត់ចោលនូវទម្ងន់ភារកិច្ចដែលបានទទួលដើម្បីចូលខ្លួនមកធ្វើជាសាក្សីជំនួសអ្នកស្លាប់ ។

ទោះបីជាមានការវិវត្តខាងប្រព័ន្ធច្បាប់ក្នុងស្រុកក៏ដោយក៏តុលាការអន្តរជាតិពិសេសចំនួនពីរបានផ្តល់សំណងបន្តិចបន្តួច ។ ក្រៅពីរយៈពេលនៃការដាក់ពន្ធនាគារ តុលាការទាំងពីរនេះបានប្រមើលអំពី "ការប្រគល់ទ្រព្យសម្បត្តិនិងប្រាក់ចំណេញទាំងពួងដែលឧក្រិដ្ឋជនទទួលបានមកពីការប្រព្រឹត្តឧក្រិដ្ឋកម្មនិងពីការគំរាមកំហែងមិនស្របច្បាប់ឲ្យទៅម្ចាស់ទ្រព្យស្របច្បាប់វិញ ។ ទោះជាយ៉ាងណាក៏ដោយ ទាក់ទងទៅនឹងទម្រង់នៃការសងជំងឺចិត្តចំពោះជនរងគ្រោះ បទបញ្ញត្តិរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICT) គ្រាន់តែបានអះអាងថា "ជនរងគ្រោះណាម្នាក់ដែលធ្វើបណ្តឹងតាមរយៈតុលាការនេះ អាចដាក់ពាក្យបណ្តឹងទៅតុលាការជាតិឬអង្គការមានសមត្ថកិច្ចផ្សេងៗទៀត ដើម្បីទាមទារសំណងជំងឺចិត្ត" ទាក់ទងទៅនឹងនីតិកម្មជាតិដែលពាក់ព័ន្ធ ។

នៅក្នុងឆ្នាំ១៩៩៦ អនុគណៈកម្មការអង្គការសហប្រជាជាតិស្តីអំពីការទប់ស្កាត់ ការរើសអើង និងការការពារជនជាតិភាគតិចបានចេញផ្សាយរបាយការណ៍អំពីសិទ្ធិទទួលបានសំណងជំងឺចិត្តសម្រាប់ជនរងគ្រោះនៃអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដែលរដ្ឋត្រូវតែធានាឲ្យមាន"សិទ្ធិទទួលការបង្ការមិនឲ្យមានអំពើរំលោភលើបទដ្ឋានសិទ្ធិមនុស្សនិងមនុស្សធម៌" ។ វិធានការដែលមាននោះរួមមានសំណងជាទ្រព្យសម្បត្តិ សំណងជំងឺចិត្ត ការស្តារនីតិសម្បទាឡើងវិញ ការបំពេញតាមតម្រូវការ និងការធានាមិនឲ្យអំពើឧក្រិដ្ឋវិលត្រឡប់មកវិញ ។ របាយការណ៍ក៏បានបញ្ជាក់ថា "សំណងគួរតែផ្តល់យុត្តិធម៌តាមរយៈការលុបបំបាត់ចោលឬកែតម្រូវផលវិបាកនៃអំពើខុសឆ្គង និងតាមរយៈការការពារនិងទប់ស្កាត់អំពើហិង្សា" ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានឆ្លើយតបទៅតាមការវិវត្តន៍នេះដោយប្រែក្លាយខ្លួនទៅជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិដំបូងបង្អស់ដែលបានផ្តល់ហិរញ្ញវត្ថុមួយចំនួនឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ជនរងគ្រោះ ។

ខណៈដែលយុត្តិធម៌អន្តរជាតិត្រូវបានចាត់ទុកជាមធ្យោបាយដាក់ទណ្ឌកម្មមេដឹកនាំឧក្រិដ្ឋ ឬបណ្តេញមេដឹកនាំទាំងនេះចេញពីឆាកនយោបាយ ក៏ប្រហែលជានៅតែមានទឡ្ហីករណ៍ថា យុត្តិធម៌នេះមិនស្របទៅតាមកិច្ចខិតខំប្រឹងប្រែងខាងការទូតឬយោធាដើម្បីបញ្ចប់ជម្លោះដែលចេះតែបន្តទេ ។ ទោះជាយ៉ាងណាក៏ដោយ ដោយគោរពទៅតាមគោលការណ៍ខាងលើ យុត្តិធម៌អន្តរជាតិអាចជំរុញឲ្យមានការស្តាបនាយុត្តិធម៌ឡើងវិញ និងភ្ជាប់ទំនាក់ទំនងសង្គមដែលត្រូវបំផ្លិចបំផ្លាញដោយសារឧក្រិដ្ឋកម្មអន្តរជាតិ ។ ដោយមើលឃើញបែបនេះ យុត្តិធម៌អន្តរជាតិមិនគ្រាន់តែបំពេញបន្ថែមដល់ការកសាងសន្តិភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនអាចខ្វះបានទៀតផង ។ នៅក្នុងករណីណាក៏ដោយ មានតែយុត្តិធម៌និងការអនុវត្តដោយឯករាជ្យទេទើបអាចសម្រេចបាននូវគោលដៅទាំងអស់នេះ ។

### ៣) សារជាតិនៃយន្តការប្រព័ន្ធតុលាការៈ ការប្រកួតប្រជែងគ្នានាំឲ្យមានតុលាការចម្រុះជាតិនិងអន្តរជាតិ

ពីមុនៗមក មានទាំងគំរូតុលាការជាតិនិងអន្តរជាតិសម្រាប់ប្រទេសកម្ពុជាក្នុងការសុំជំនួយពីអង្គការសហប្រជាជាតិ ។ បន្ទាប់ពីបានគាំទ្រកងកម្លាំងខ្មែរក្រហមអស់រយៈពេលជាច្រើនឆ្នាំ ទោះជាតាមរយៈសកម្មភាពបើកចំហឬតាមរយៈ"ការធ្វើមិនដឹងមិនឮ" ក៏ដោយ ក៏នៅក្នុងឆ្នាំ១៩៩៧ អង្គការសហប្រជាជាតិបានទទួលស្គាល់ជាផ្លូវការនូវទំនាក់ទំនងជាសារវ័ន្តរវាងការផ្សះផ្សាជាតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងដំណោះស្រាយបញ្ហាការទទួលខុសត្រូវលើបទឧក្រិដ្ឋកម្មជាបុគ្គលនៅក្នុងប្រទេសកម្ពុជា ។ ការទទួលខុសត្រូវខាងផ្នែកសីលធម៌នាំឲ្យគណៈកម្មាធិការសិទ្ធិមនុស្សប្រកាសថា អង្គការសហប្រជាជាតិនឹងទទួលយកសំណើរបស់ប្រទេសកម្ពុជាដើម្បីជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ ម្យ៉ាងវិញទៀត គួរចាំថា សំបុត្រកាលពីខែមិថុនា ឆ្នាំ១៩៩៧ ដែលស្នើសុំឲ្យចាប់ផ្តើមដំណើរការទាំងស្រុង ជាសំណើរួមគ្នាមួយដែលធ្វើឡើងដោយសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន (ដែលជាសហនាយករដ្ឋមន្ត្រី) ។ ក្រោយមក ទំនាស់រវាងដៃគូចម្រុះទាំងពីរនេះកាន់តែដុនដាបទៅៗ ដោយសារភាគីទាំងសងខាងប៉ុនប៉ងយកជ័យជម្នះទៅលើក្រុមខ្មែរក្រហមដែលព្យាយាមផ្តាច់ខ្លួនពីចលនាទាំងមូលបន្ទាប់ពីការផ្តាច់ខ្លួនរបស់សមាជិកដ៏មានឥទ្ធិពលនៃគណៈកម្មាធិការមជ្ឈិមគឺ អៀង សារី នៅក្នុងឆ្នាំ១៩៩៦ និងបន្ទាប់ពីមានការកម្ចាត់ ប៉ុល ពត នៅក្នុងខែមិថុនា ឆ្នាំ១៩៩៧ ។ អាស្រ័យហេតុនេះ អំណាចនយោបាយផ្ទៃក្នុងជាកម្លាំងដ៏សំខាន់សម្រាប់ដំណើរការនេះតាំងតែពីដើមដំបូងមក ។ ផលប្រយោជន៍ខាងសីលធម៌និងនយោបាយទាំងអស់នេះត្រូវតែរក្សាទុកក្នុងចិត្តនៅពេលវិភាគទៅលើការបដិសេធចោលនូវតុលាការឧក្រិដ្ឋកម្មអន្តរជាតិពិសេសលើកទី៣ និងការចរចាបន្តបន្ទាប់អំពីការចូលរួមពីអន្តរជាតិនៅក្នុងការជំនុំជម្រះក្តី ។

**ក) ការបដិសេធតុលាការឧក្រិដ្ឋកម្មអន្តរជាតិពិសេសលើកទី៣**

សំបុត្ររបស់រាជរដ្ឋាភិបាលកម្ពុជានាឆ្នាំ១៩៩៧បានស្នើ



សុំឲ្យអង្គការសហប្រជាជាតិផ្តល់“ជំនួយស្រដៀងគ្នា” ទៅនឹងជំនួយដែលផ្តល់ទៅឲ្យប្រទេសរ៉្វាន់ដានិងអតីតយូហ្គោស្លាវី ដើម្បី “ស្វែងរកការពិតនៅក្នុងចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ និងនាំយកអ្នកដែលទទួលខុសត្រូវទៅតុលាការ” ។ អង្គការសហប្រជាជាតិបានទទួលស្គាល់ហើយថា “ប្រទេសកម្ពុជាគ្មានប្រភពធនធានឬជំនាញដើម្បីអនុវត្តនីតិវិធីដ៏មានសារសំខាន់នេះទេ” ។

ទោះបីជាបានចុះហត្ថលេខារួមគ្នាលើសំណើសុំជំនួយពីអង្គការសហប្រជាជាតិក៏ដោយ ក៏នៅពេលក្រោយមក សម្តេច ហ៊ុន សែន បានជំទាស់រាល់សំណើដែលនាំឲ្យមានការបង្កើតឡើងនូវតុលាការពិសេសអន្តរជាតិលើកទីបី ។ ជាងនេះទៅទៀត កត្តាអន្តរជាតិមួយចំនួនក៏បានដាក់ទម្ងន់ទៅលើដំណោះស្រាយនេះដែរ ។

### ក-១) ការជំទាស់របស់សម្តេច ហ៊ុន សែន

សំណើសុំការជួយឧបត្ថមគាំទ្ររបស់ប្រទេសកម្ពុជាស្ថិតនៅក្នុងបរិបទនៃភាពតានតឹងខាងនយោបាយរវាងសហនាយករដ្ឋមន្ត្រីទាំងពីរមុនពេលមានព្រឹត្តិការណ៍ខែកក្កដា ឆ្នាំ១៩៩៧ ។ មុនពេលនោះ អង្គការសហប្រជាជាតិគ្មានសូម្បីតែពេលវេលាឆ្លើយតបតាមការអញ្ជើញរបស់កម្ពុជាផង ។ ភាពឯកោរបស់កម្ពុជានៅពេលនោះ និងការដ្ឋីបចោលអាសនៈរបស់កម្ពុជានៅក្នុងអង្គការសហប្រជាជាតិបានបញ្ចប់នូវការពិភាក្សាអំពីបញ្ហាតុលាការ ។

ដើម្បីភ្ជាប់ទំនាក់ទំនងសាជាថ្មី សហគមន៍អន្តរជាតិបានដាក់លក្ខខណ្ឌឲ្យកម្ពុជាការរៀបចំការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ថូម៉ាស់ ហាម៉ាបើក ធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា បញ្ហាតុលាការខ្មែរក្រហមកាន់តែមានសារសំខាន់ក្នុងការវាយតម្លៃការតាំងចិត្តរបស់សម្តេច ហ៊ុន សែន ក្នុងការជំរុញវិធាននៃច្បាប់នៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងខែតុលា ឆ្នាំ១៩៩៧ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានជូនដំណឹងដល់មហាសន្និបាតថា “អ្នករំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតនៅប្រទេសកម្ពុជានៅក្នុងប្រវត្តិសាស្ត្រថ្មីៗគឺខ្មែរក្រហម” និងថា “អាជ្ញាធរកម្ពុជាមិនបានចាប់ខ្លួនឬចោទប្រកាន់មេដឹកនាំខ្មែរក្រហមណាមួយឡើយ” ។ លោកអគ្គលេខាធិការបានសម្តែងនូវការព្រួយបារម្ភថា មេដឹកនាំខ្មែរក្រហមអាចនឹងឈានចូលទៅក្នុងជីវិតនយោបាយនៅកម្ពុជាសាជាថ្មីដោយគ្មានការទទួលខុសត្រូវលើបទឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គលឡើយ ដែលនាំឲ្យវប្បធម៌នៃភាពគ្មានទោសនៅតែបន្តនៅក្នុងប្រទេសកម្ពុជា ។ អាស្រ័យហេតុនេះហើយ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានគាំទ្រសំណើរបស់លោក ថូម៉ាស ហាម៉ាបើក ដែលថា “អង្គការសហប្រជាជាតិនិងរដ្ឋជាសមាជិកទាំងឡាយគួរតែឆ្លើយតបជាវិជ្ជមាននិងប្រកបដោយចិត្តសប្បុរសទៅនឹងសំណើសុំខាងលើ” ។ ដូច្នេះហើយ នៅខែធ្នូ ឆ្នាំ១៩៩៧ មហាសន្និបាតអង្គការសហប្រជាជាតិបានស្នើឲ្យលោកអគ្គលេខា “ពិនិត្យមើលសំណើរបស់អាជ្ញាធរកម្ពុជាដើម្បីឆ្លើយតបទៅនឹងអំពើរំលោភដ៏ធ្ងន់ធ្ងរកាលពីអតីតកាលទៅលើច្បាប់កម្ពុជានិងច្បាប់អន្តរជាតិដោយរាប់បញ្ចូលទាំងលទ្ធភាពនៃការណាត់ជួបរវាងលោកអគ្គលេខាធិការជាមួយក្រុមអ្នកជំនាញការដើម្បីវាយតម្លៃភ័ស្តុតាងដែលមានស្រាប់ និងស្នើសុំវិធានការបន្ថែមទៀតដើម្បីធ្វើជាមធ្យោបាយនាំមកនូវការផ្សះផ្សាជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យនិងដោះស្រាយការទទួលខុសត្រូវរបស់បុគ្គល” ។

នៅពេលដែលអតីតឧត្តមស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកខាងសិទ្ធិមនុស្ស ម៉ារី រ៉ូប៊ីនសុន បានបញ្ជាក់ច្បាស់នៅក្នុងអំឡុងពេលទស្សនកិច្ចរបស់គាត់នៅប្រទេសកម្ពុជាកាលពីខែមករា ឆ្នាំ១៩៩៨ ថា ការទទួលស្គាល់រដ្ឋាភិបាល ហ៊ុន សែន យូរឬឆាប់គឺអាស្រ័យទៅលើកិច្ចការនេះ ។ ដូច្នេះ សម្តេច ហ៊ុន សែន យល់ព្រមបង្កើតក្រុមអ្នកជំនាញការមួយដើម្បីធ្វើកិច្ចការនេះ ។ ការស្លាប់របស់ប៉ុលពត កាលពីខែមេសា ឆ្នាំ១៩៩៨ នាំឲ្យមានការគិតថា សម្ពាធអន្តរជាតិបានសាបរលាបហើយ ។ ផ្ទុយទៅវិញ ចំណាប់អារម្មណ៍ក្នុងការជំនុំជម្រះមេដឹកនាំខ្មែរក្រហមដែលនៅសេសសល់បានកើនឡើងពីរដង ហើយនៅទីបញ្ចប់ លោកអគ្គលេខាធិការបានបង្កើតក្រុមអ្នកជំនាញការនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៨ តែពីរថ្ងៃមុនការបោះឆ្នោតសភានៅក្នុងប្រទេសកម្ពុជា ។

គណបក្សប្រជាជនកម្ពុជាដឹកនាំដោយសម្តេច ហ៊ុន សែន បានទទួលសំឡេងភាគច្រើនដាច់ខាតនៅក្នុងការបោះឆ្នោត ប៉ុន្តែមិនដល់ពីរភាគបីដែលជាចំនួនចាំបាច់សម្រាប់បង្កើតរដ្ឋាភិបាលអនុលោម

ទៅតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣បាន ។ បន្ទាប់ពីមានការបោះឆ្នោតនយោបាយនៅកម្ពុជាមានភាពតានតឹងយ៉ាងខ្លាំង ។ ទោះបីជាក្រុមអ្នកសង្កេតការណ៍អន្តរជាតិបានបញ្ជាក់ទាំងស្ទាក់ស្ទើរថា “អ្វីទាំងអស់មានតម្លាភាព”ក៏ដោយ ក៏គណបក្សដទៃៗទៀតបានបដិសេធជ័យជម្នះរបស់ ហ៊ុន សែន ក្នុងបរិយាកាសហិង្សាខាងនយោបាយ ។ ម្យ៉ាងវិញទៀត ភាពមិនចុះសម្រុងគ្នាអំពីតួនាទីរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ដែលជាអ្នកទីពីរនៅក្នុងការរៀបចំក្រុមចម្រុះថ្មីមួយនាំឲ្យមានភាពទាល់ច្រកខាងរដ្ឋធម្មនុញ្ញ ។ ទីបញ្ចប់ ក្រោយពីសហគមន៍អន្តរជាតិដាក់សម្ពាធយ៉ាងខ្លាំងទៅលើគណបក្សទាំងអស់នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៨ គណបក្សទាំងពីរក៏ឈានដល់ការសម្រុះសម្រួលមួយ គឺ សម្តេច ហ៊ុន សែន ក្លាយជានាយករដ្ឋមន្ត្រី ហើយសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជាប្រធានរដ្ឋសភាជាតិ ។ យ៉ាងហោចណាស់អ្វីដែលអាចនិយាយបាននៅពេលនោះគឺថា ការទទួលខុសត្រូវរបស់មេដឹកនាំខ្មែរក្រហមមិនមែនជាអត្ថិភាពខ្ពស់ទេ ។ គិតត្រឹមពេលដែលសមាជិកបីនាក់ក្នុងក្រុមអ្នកជំនាញការរបស់អង្គការសហប្រជាជាតិមកធ្វើទស្សនកិច្ចរយៈពេលពីរសប្តាហ៍នៅក្នុងប្រទេសកម្ពុជានៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៨ សភាពការណ៍នយោបាយបានផ្អៀងទៅខាងសម្តេច ហ៊ុន សែន កាន់តែខ្លាំង ។ កម្ពុជាមិនត្រឹមតែបានបង្កើតរដ្ឋាភិបាលចម្រុះថ្មីមួយតាមការសន្យាដើម្បីបានធ្វើសមាហរណកម្មចូលទៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិប៉ុណ្ណោះទេ ថែមទាំងមានប្រៀបលើខ្មែរក្រហមដែលកំពុងតែបះបោរ ។ សម្តេច ហ៊ុន សែន បានប្រើការគំរាមកំហែងអំពីតុលាការខ្មែរក្រហម ធ្វើជាការតថ្លៃនៅក្នុងការចរចាសុំឲ្យមេដឹកនាំខ្មែរក្រហមដែលនៅសេសសល់ចុះចូលមកក្នុងសង្គមជាតិ ។ គាត់បានជម្រាបជូនក្រុមអ្នកជំនាញការថា ឥឡូវនេះគាត់ចង់ឲ្យមានការកាត់សេចក្តីនៅក្នុងស្រុកច្រើនជាង ។ មួយខែក្រោយមក គឺនៅដើមខែធ្នូ ឆ្នាំ១៩៩៨ មេដឹកនាំខ្មែរក្រហមសំខាន់ៗចុងក្រោយ គឺ ខៀវ សំផន និង នួន ជា បានចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា ហើយត្រូវបានស្វាគមន៍នៅក្នុងទីក្រុងភ្នំពេញដោយគ្មានការចាប់ខ្លួន ។ មានតែមេដឹកនាំយោធាក្បាលរឹងមួយរូបគត់ឈ្មោះ តាម៉ុក និងអ្នកស្មោះត្រង់របស់គាត់មួយក្តាប់តូច បន្តប្រយុទ្ធនៅតាមបណ្តោយព្រំដែនថៃ ។ នៅទីបញ្ចប់ តាម៉ុក ត្រូវកងទ័ពរដ្ឋាភិបាលចាប់ខ្លួននៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩ ។ បន្ទាប់ពីសម្រេចបាននូវទិសដៅនយោបាយទាំងពីររបស់គាត់ (ភាពស្របច្បាប់និងសមាហរណកម្មកងកម្លាំងខ្មែរក្រហម) សម្តេច ហ៊ុន សែន បានបញ្ជាក់វិញថា បញ្ហានៃការទទួលខុសត្រូវគួរតែ“កប់ចោល” ដើម្បីចៀសវាងកុំឲ្យកើតមានជម្លោះសាជាថ្មីទៀត ។

តែទោះជាយ៉ាងណាក៏ដោយ ដោយប្រឈមមុខទៅនឹងការរិះគន់របស់សាធារណនិងការខឹងសម្បាររបស់សហគមន៍អន្តរជាតិ សម្តេច ហ៊ុន សែន បានត្រឡប់មកផ្លូវចាស់វិញ ។ ព្រះមហាក្សត្រ សម្តេចព្រះ នរោត្តម សីហនុ បាន បញ្ជាក់ច្បាស់ថា ព្រះអង្គនឹងមិនផ្តល់ការលើកលែងទោសដល់មេដឹកនាំខ្មែរក្រហមណាម្នាក់ទេ លុះត្រាតែមានសំណើសុំពីសំណាក់រដ្ឋាភិបាល ។

អាស្រ័យហេតុនេះហើយ នៅខែមករា ឆ្នាំ១៩៩៩ សម្តេច ហ៊ុន សែន បានផ្តល់ទៅឲ្យអង្គការសហប្រជាជាតិនូវឯកសារជំនួយស្មារតីស្តីអំពីការទទួលខុសត្រូវរបស់ខ្មែរក្រហមទទួលស្គាល់ភាពចាំបាច់នៃអង្គជំនុំជម្រះក្តី ក៏ប៉ុន្តែបានទទូចថា “យុត្តិធម៌និងការផ្សះផ្សាជាតិត្រូវតែពិនិត្យពិចារណាទន្ទឹមគ្នា មិនអាចដាក់បញ្ហាណាមួយជាអត្ថិភាពទេ” ។ ខណៈពេលដែលឯកសារជំនួយស្មារតីជាផ្លូវការបានទុកចំហចោលនូវបញ្ហាតុលាការ “អន្តរជាតិ” ឬ“ចម្រុះ” ឯកសារទាំងនោះបានពិនិត្យទៅលើដំណោះស្រាយចម្រុះមួយដើម្បីធ្វើជាមធ្យោបាយដ៏សមស្របជាងមុនក្នុងការសម្រេចបាននូវគោលបំណងទាំងពីរនៃដំណើរការជំនុំជម្រះក្តី ។ ជាងនេះទៅទៀត សម្តេចនាយករដ្ឋមន្ត្រីបានប្រានចោលដំណោះស្រាយអន្តរជាតិដោយសំអាងទៅលើការគោរពអធិបតេយ្យភាពរបស់កម្ពុជា និងបំណងប្រាថ្នាចៀសវាងជម្លោះផ្ទៃក្នុងសាជាថ្មី ។

ប្រហែលជាដោយសារការជំទាស់ខ្លាំងរបស់សម្តេច ហ៊ុន សែន ទើបរបាយការណ៍ឆ្នាំ១៩៩៩របស់ក្រុមអ្នកជំនាញការអង្គការសហប្រជាជាតិបានសម្រេចចិត្តគាំទ្រដល់តុលាការពិសេសលើកទី៣ ។ ទោះជាយ៉ាងណាក៏ដោយ ឯកសារជំនួយស្មារតីដែលរាជរដ្ឋាភិបាលកម្ពុជាផ្ញើទៅអង្គការសហប្រជាជាតិជាលើកទីពីរបានប្រកាន់យកនូវមាគ៌ាកាន់តែតឹងតែងជាមុន ដោយបានបញ្ជាក់ថា ដើម្បីលើកកម្ពស់ “សន្តិភាពនិងស្ថិរភាព ព្រមទាំងការផ្សះផ្សា

ជាតិ ត្រូវតែជំនុំជម្រះទោស តាម៉ុក ដោយប្រព័ន្ធយុត្តិធម៌ជាតិ “អនុលោមទៅតាមច្បាប់កម្ពុជាដែលកំពុងនៅជាធរមាន” ។ សំណើនេះគឺថា មេដឹកនាំខ្មែរក្រហមផ្សេងៗទៀតដែលបានចុះចូលរួចហើយនឹងមិនត្រូវបានចោទប្រកាន់ទាល់តែសោះ ហើយថាគ្មានការចាំបាច់ឲ្យមានការចូលរួមពីអន្តរជាតិទេ ។

### ក-២) ឧបសគ្គរបស់អន្តរជាតិ

ក្រៅពីការជំទាស់របស់កម្ពុជាចំពោះការបង្កើតសាលាក្តីអន្តរជាតិសុទ្ធសាធ កត្តាច្បាប់អន្តរជាតិ នយោបាយ និងហិរញ្ញវត្ថុបានបង្កជាឧបសគ្គធ្ងន់ធ្ងរចំពោះដំណោះស្រាយបែបនេះ ។

ឈរលើមូលដ្ឋានផ្លូវច្បាប់ ឯកសារជំនួយស្មារតីដំបូងរបស់កម្ពុជាបានចោទសួរពីបញ្ហាអំណាចរបស់ក្រុមប្រឹក្សាសន្តិសុខក្នុងការបង្កើតសាលាក្តីពិសេសមួយសម្រាប់កម្ពុជា ។ សម្តេច ហ៊ុន សែន បានអះអាងថា សាលាក្តីអន្តរជាតិពិសេសគ្មានយុត្តាធិការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមដោយកំបាំងមុខទេ ។ ដោយគិតដល់ការលំបាកក្នុងការបានដណ្តើមកាន់កាប់ទីតាំងតស៊ូដ៏រឹងមាំរបស់ខ្មែរក្រហមនៅតាមបណ្តោយព្រំដែនថៃ សម្តេច ហ៊ុន សែន បានស្នើសុំថា ត្រូវតែយកមេខ្មែរក្រហមក្បាលរឹងមកកាត់សេចក្តីដោយសារតែ“ភាពរឹងរូស” តាមនីតិវិធីក្នុងស្រុកចម្លងមកពីបារាំង ។ ទោះជាតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវក៏ដោយ ទឡ្ហីករណ៍នេះមានភាពទន់ខ្សោយ ដោយសារថា ដំណើរការជំនុំជម្រះច្បាប់ទី៦១ នៅសាលាជំនុំជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិពិសេសបានអនុញ្ញាតឲ្យដើមចោទបង្ហាញសំណុំឯកសាររបស់ខ្លួនក្នុងពេលអវត្តមានជនជាប់ចោទ បន្ទាប់មកចេញដីកាអន្តរជាតិចាប់ខ្លួនជនជាប់ចោទហើយអំណាចរបស់ដីកានេះបានមកពីសាលាជំនុំជម្រះក្តីបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខអនុលោមទៅតាមជំពូកទី៧របស់ធម្មនុញ្ញសហប្រជាជាតិ ។ បន្ថែមពីនេះទៀត ប្រទេសថៃបានបញ្ជាក់ថាខ្លួននឹងគោរពតាមការទទួលខុសត្រូវជាអន្តរជាតិរបស់ខ្លួនក្នុងការចាប់ជនជាប់ចោទណាម្នាក់ដែលប្រទះឃើញនៅលើទឹកដីថៃ ។

ទោះជាយ៉ាងណាក៏ដោយ ករណីខ្មែរក្រហមពិតជាទាក់ទងទៅនឹងកម្រិតនៃអំណាចទូទៅរបស់ក្រុមប្រឹក្សាសន្តិសុខក្នុងការថែរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ ។ ការវិនិច្ឆ័យរបស់សាលាជំនុំជម្រះក្តីបានបញ្ជាក់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាសន្តិសុខក្នុងការបង្កើតសាលាជំនុំជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិពិសេសមួយអនុលោមទៅតាមជំពូកទី៧ ។ ដើម្បីបញ្ជាក់បែបនេះបាន ក្រុមប្រឹក្សាសន្តិសុខមិនត្រឹមតែទទួលស្គាល់ថាសភាពការណ៍នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នបានគំរាមកំហែងដល់សន្តិភាពនិងសន្តិសុខអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលស្គាល់ថា ការបង្កើតសាលាជំនុំជម្រះក្តីមួយនឹងរួមចំណែកដល់ការថែរក្សាសន្តិភាពអន្តរជាតិ ។ ទោះជាការបះបោររបស់ខ្មែរក្រហមចេះតែបន្តជះឥទ្ធិពលមិនល្អទៅលើរដ្ឋាភិបាលក្តី ភាពប្រថុយប្រថាននេះមិនអាចយកមកប្រៀបធៀបជាមួយនឹងជម្លោះនៅប្រទេសរ៉្វាន់ដា និងអតីតយូហ្គោស្លាវីខណៈដែលក្រុមប្រឹក្សាសន្តិសុខសម្រេចចិត្តបង្កើតសាលាជំនុំជម្រះក្តីសម្រាប់ប្រទេសទាំងពីរនេះទេ ។

នៅខែមិថុនា ឆ្នាំ១៩៩៨ តំណាងរបស់សហរដ្ឋអាមេរិកប្រចាំនៅអង្គការសហប្រជាជាតិបានផ្តល់ជូនសមាជិកក្រុមប្រឹក្សាសន្តិសុខនូវគំរូព្រាងសេចក្តីសម្រេចចិត្តដែលគាំទ្រឲ្យមានការបង្កើតសាលាជំនុំជម្រះក្តី ពិសេសមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បុព្វកថានៃសេចក្តីព្រាងបានសរសេរដូចតទៅ ÷ “សម្រេចថាការខកខានមិនបាន កាត់ទោសបុគ្គលទាំងនោះទាក់ទងទៅនឹងសភាពការណ៍ដែលកំពុងបន្តនៅក្នុងប្រទេសកម្ពុជា នឹងបង្កការគំរាមកំហែងដល់សន្តិភាពនិងសន្តិសុខអន្តរជាតិ” ។ សេចក្តីសម្រេចចិត្តបែបនេះតម្រូវឲ្យក្រុមប្រឹក្សាសន្តិសុខទទួលស្គាល់ភាពទូលំទូលាយនៃអំណាចរបស់ខ្លួន (ដែលពិតជាមាននៅក្នុងការរំពឹងទុករបស់ស្ថាបនិកអង្គការសហប្រជាជាតិ) និងផ្តល់ភាពត្រឹមត្រូវដល់អន្តរាគមន៍របស់ក្រុមប្រឹក្សាសន្តិសុខ ។

ទោះជាការបកស្រាយអំណាចនេះអាចយល់បានតាមផ្លូវច្បាប់ក៏ដោយ ក៏ក្រុមប្រឹក្សាសន្តិសុខទំនងជាមិនចាត់ទុកគ្រោះថ្នាក់នៃការកំណត់ប្រភេទឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងកាលពីជាង២០ឆ្នាំទៅហើយថាជាការគំរាមកំហែងដល់សន្តិភាពអន្តរជាតិនាពេលបច្ចុប្បន្ននេះទេបើពិនិត្យមើលអំពីចំនួនជម្លោះនៅក្នុងសង្គ្រាមត្រជាក់នៅទូទាំងពិភពលោកដែលមិនទាន់បានដោះស្រាយ ។ ក្រុមប្រឹក្សាសន្តិសុខជាអង្គការនយោបាយមួយដែលរួមមានរដ្ឋជាច្រើន ព្រមទាំងមានសមាជិកអចិន្ត្រៃយ៍ចំនួនប្រាំដែលមាន

សិទ្ធិជំទាស់ ។ ចក្រភពអង់គ្លេស បារាំង និងរុស្ស៊ី ទំនងជាត្រៀមខ្លួនគាំទ្រសេចក្តីព្រាងនៃសេចក្តីសម្រេចចិត្តរបស់អាមេរិកនៅឆ្នាំ ១៩៩៨ ។ ប្រទេសចិនដែលជាសមាជិកអចិន្ត្រៃយ៍ទី៥ (ដែលពីមុនជាអ្នកគាំទ្រដ៏សំខាន់របស់ខ្មែរក្រហម) ទំនងជាជំទាស់ទៅនឹងការបង្កើតសាលាជំនុំជម្រះក្តីអន្តរជាតិ ហើយរដ្ឋាភិបាលកម្ពុជាក៏ជំទាស់ទៅនឹងសាលាជំនុំជម្រះក្តីនេះដែរ ។ បើពិនិត្យមើលល្បឿននៃការចរចាដែលហាក់ដូចជាដើរតែពីក្រោយដំណើរទស្សនកិច្ចជាផ្លូវការរបស់ចិននៅប្រទេសកម្ពុជារៀងរាល់ពេល ប្រទេសកម្ពុជាហាក់ដូចជាមិនធ្វើសំណើណាមួយទេប្រសិនបើប្រទេសចិនជំទាស់ ។

ជាចុងក្រោយ យើងមិនគួរភ្លេចទេថា សហគមន៍អន្តរជាតិកំពុងតែប្រយ័ត្នប្រយែងកាន់តែខ្លាំងឡើងៗក្នុងការរួមចំណែកប្រភពធនធានហិរញ្ញវត្ថុដល់តុលាការខ្មែរក្រហម ដោយផ្តល់អត្ថិភាពដល់ដំណោះស្រាយជាតិដែលមិនសូវអស់ថវិកាច្រើន ឬដំណោះស្រាយចម្រុះ ។

ទាក់ទងទៅនឹងគុណវិបត្តិទាំងអស់នេះ ក្រុមអ្នកជំនាញការត្រូវតែមាន"ខ"រក្សាសិទ្ធិឲ្យបានរឹងមាំពាក់ព័ន្ធនឹងជម្រើសផ្សេងៗទៀត បើចង់បានប្រព័ន្ធយុត្តិធម៌អន្តរជាតិសុទ្ធសាធមួយដែលហាក់ដូចជាមិនអាចឈោងចាប់បាន ។

### ១) ការស្វែងរកការចូលរួមពីអន្តរជាតិនៅក្នុងសាលាក្តីជាតិ

ការចរចារវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមឡើងដោយភាគីទាំងពីរឃ្លាំមើលគោលជំហររបស់គ្នាទៅវិញទៅមក ដោយសារតែគំនិតផ្ទុយគ្នា ។ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៩៩ លោក កូហ្វី អាណាន់ បានទទួលស្គាល់ការសន្និដ្ឋានរបស់ក្រុមអ្នកជំនាញការ ដែលបានផ្តល់ទៅឲ្យគាត់និងរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩ និងបានផ្តល់អនុសាសន៍ឲ្យបង្កើតសាលាជំនុំជម្រះក្តីពិសេសអន្តរជាតិលើកទី៣ ។ ការជំទាស់របស់ប្រទេសចិនប្រហែលជាមានហេតុផលចំនួនបី ។ ប្រហែលជាថាខណៈពេលដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិបញ្ចប់លក្ខន្តិកៈរបស់ខ្លួនហើយ អង្គការសហប្រជាជាតិដែលមានអំណាចគ្រប់គ្រាន់អាចនាំយកសម្ពាធអន្តរជាតិមកដាក់លើប្រទេសកម្ពុជាដើម្បីឲ្យទទួលយកលក្ខន្តិកៈនេះ ។ ជម្រើសផ្សេងៗទៀត ប្រហែលជាមានការសង្ស័យថា សម្ពាធនេះនឹងត្រូវធ្វើឡើង ហើយក៏នឹងអាចត្រូវបោះបង់ចោលវិញដែរ ឬគ្រាន់តែថាសម្ពាធនេះត្រូវបានជ្រើសរើសដើម្បីបង្កើតនូវតួនាទីចរចាដ៏រឹងមាំមួយសម្រាប់ការសម្រុះសម្រួលគ្នាមួយដែលមិនអាចចៀសផុតនៅពេលខាងមុខ ។

ដូចការទាយទុក សម្តេច ហ៊ុន សែន បានបដិសេធដំណោះស្រាយរបស់អង្គការសហប្រជាជាតិ ហើយដំណោះស្រាយជាឯកច្ឆ័ន្ទដែលខុសពីវិធានការរបស់ក្រុមប្រឹក្សាសន្តិសុខបានក្លាយទៅជាជម្រើសពិតប្រាកដតែមួយគត់សម្រាប់ភាពរួចទោសទណ្ឌ ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមអ្នកជំនាញការរបស់អង្គការសហប្រជាជាតិបានពិនិត្យពិច័យនិងច្រានចោលនូវជម្រើសផ្សេងៗទៀត ។ ទោះជាអាចធ្វើទៅបានតាមលក្ខណៈបច្ចេកទេសក៏ដោយ ក៏ដំណោះស្រាយទាំងអស់នេះនឹងមិនទទួលប្រយោជន៍ពីឥទ្ធិពលបន្ទំនៃសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខដែរ ។ ខណៈពេលដែលក្រុមអ្នកជំនាញការកត់សម្គាល់ឃើញថា កិច្ចសហប្រតិបត្តិការប្រកបដោយជំនឿចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជានឹងមានសារសំខាន់ជាងសេចក្តីសម្រេចចិត្តដោយបង្ខំតាមលក្ខណៈទ្រឹស្តី ក្រុមនេះបានសន្និដ្ឋានថា ឱកាសទទួលបានការគាំទ្រផ្ទៃក្នុងចំពោះដំណើរការនេះនៅមានកម្រិតនៅឡើយ ។ ជាងនេះទៅទៀត ដូចដែលសម្តេច ហ៊ុន សែន បានអះអាងកាលពីពេលថ្មីៗនេះ ប្រទេសកម្ពុជាមិនដែលស្នើសុំជំនួយជាផ្លូវការពីអង្គការសហ-ប្រជាជាតិដើម្បីបង្កើតសាលាជំនុំជម្រះក្តីចម្រុះនោះទេ ។ ដូច្នេះ ក្នុងកម្រិតណាមួយនោះ សហគមន៍អន្តរជាតិបានដាក់សម្ពាធមកលើភាគីទាំងពីរឲ្យបន្តការចរចា ។

តាមការពិត នៅពីខាងក្រោយគោលជំហរដែលហាក់ដូចជាប្រឆាំងគ្នា ភាគីទាំងពីរបានត្រៀមខ្លួនដើម្បីសម្រុះសម្រួលគ្នារួចទៅហើយ ។ ទោះជាយ៉ាងណាក៏ដោយ ការចរចាដ៏ស្មុគស្មាញបានចំណាយអស់រយៈពេលមួយឆ្នាំមុនពេលកិច្ចព្រមព្រៀងពិតប្រាកដមួយសម្រេចបាននៅក្នុងខែកក្កដាឆ្នាំ២០០០ ។ មួយឆ្នាំទៀតបានកន្លងផុតទៅមុនពេលដែលប្រទេសកម្ពុជាអនុម័តច្បាប់ដែលចាំបាច់ដើម្បីផ្តល់ប្រសិទ្ធភាពដល់កិច្ចព្រមព្រៀងនេះ ។

**(នៅមានត)**

**ដាវីដ ឆ័យ**

# មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងស្វែងរករូបថតជនរងគ្រោះ ដែលបានថតនៅរវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្ដាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ FM102MHz ទីក្រុងភ្នំពេញ វិទ្យុ FM93.25MHz ខេត្តកំពត វិទ្យុ FM99MHz ខេត្តព្រះវិហារ និងវិទ្យុFM ១០៣.២៥MHz ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានផ្ញើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃជាច្រើនទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួន ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់ជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះ យើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅយើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួន ។ រូបថតទាំងនោះចាំបាច់ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នក បន្ទាប់មកនឹងប្រគល់រូបថតដើមជូនទៅលោកអ្នកវិញ ។

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬទាក់ទងតាមអ៊ីមែល Email: truthwynne@dccam.org ឬ truthpivoine@dccam.org ។ សូមអរគុណ ។

# តើសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមបង្កើតសម្រាប់អ្នកណា? ហើយមានអត្ថប្រយោជន៍ឬទេ?

*(ការពិភាក្សាតុមូលជាសាធារណៈ នៅទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៤)*

**ម៉ៃឃើល វេឆុនៈ** ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកអ្នកដែលបានមកចូលរួមក្នុងកម្មវិធីនេះ ។ ខ្ញុំឈ្មោះ ម៉ៃឃើល វេឆុន ។ អ្នកសម្របសម្រួលកម្មវិធីនេះគឺ វ៉ាឈល ស្នាយដឺ ដែលជាអ្នកនិពន្ធអស់រយៈពេល១០ឆ្នាំមកហើយ ។ គាត់ក៏ជាអ្នកកែសម្រួលសៀវភៅ «មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ» ។ គាត់បានមកដល់ប្រទេសកម្ពុជាប្រមាណជិតមួយឆ្នាំ ហើយកំពុងតែនិពន្ធសៀវភៅមួយក្បាលទៀតស្តីអំពីឧស្សាហកម្មកាត់ដេរនៅប្រទេសកម្ពុជា ដែលមានចំណងជើងថា “Weft and Warped: A Journey through the Heart of Denim” ។ វ៉ាឈល ស្នាយដឺ ក៏ជាអ្នកនិពន្ធរបស់ទស្សនាវដ្តី “ណេសិនណល ជីអូក្រាហ្វិក” “អាមេរិកាំង ហេរីធីជ” និង «រ៉ូលីងស្តូន»ដែរ ។

**វ៉ាឈល ស្នាយដឺៈ** ប្រធានបទសម្រាប់ការពិភាក្សានៅយប់នេះគឺ “តើសាលាជំនុំជម្រះក្តីខ្មែរក្រហមបង្កើតសម្រាប់អ្នកណា ហើយមានអត្ថប្រយោជន៍ដែរឬទេ?” ។ បញ្ហាជវិកាចំណាយបានក្លាយទៅជាបញ្ហាវិវាទអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ នៅពេលដែលសាលាជំនុំជម្រះក្តីនេះកាន់តែខិតជិតមកដល់ ក្រុមអ្នកកាសែតបរទេសគិតថាចាំបាច់ត្រូវបង្កើតឲ្យមានការពិភាក្សាមួយ ដើម្បីជជែកអំពីមូលហេតុដែលយើងចាំបាច់ត្រូវបង្កើតឲ្យមានសាលាជំនុំជម្រះក្តីនេះ នរណាខ្លះដែលអាចទទួលបានអត្ថ-ប្រយោជន៍ និងថាតើការចំណាយទៅលើការបង្កើតសាលាក្តីនេះសមស្របទៅនឹងអត្ថប្រយោជន៍របស់វាដែរឬទេ ។ យើងមានវាគ្មិនចំនួនបីរូបនិងអ្នកបកប្រែមួយរូប ។ ម្នាក់ៗនឹងនិយាយពី១០ទៅ១៥នាទី បន្ទាប់មកយើងនឹងមានការពិភាក្សាជាចំហមួយមុននឹងចូលដល់កម្មវិធីបញ្ចប់គឺកម្មវិធីសំណួរនិងចម្លើយ ។

យើងនឹងចាប់ផ្តើមពីលោក ស៊ីវ ហេដ័រ ។ ខ្ញុំជឿជាក់ថាភាគច្រើននៃអ្នកទាំងអស់គ្នាពិតជាធ្លាប់បានឮឈ្មោះរបស់គាត់ពីមុនមកហើយ ។ គាត់ចូលមកប្រទេសកម្ពុជាមុនដំបូងក្នុងឆ្នាំ១៩៧៣ ក្នុងនាមជាអ្នកកាសែតរបស់កាសែត«ថៃមស៍» ។ ចាប់ពីពេលនោះមក លោកស៊ីវចាប់ផ្តើមស្រាវជ្រាវពីបញ្ហានយោបាយនិងសិទ្ធិមនុស្សនៅកម្ពុជា ដោយធ្វើការឲ្យអង្គការជាច្រើន រួមមានអង្គការសហប្រជាជាតិ ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិក អង្គការលើកលែងទោសអន្តរជាតិ និងសារមន្ទីរ«ហូឡូខស» ។ គាត់ក៏បានបោះពុម្ពផ្សាយសៀវភៅជាច្រើនដែរ ដែលក្នុងនោះសៀវភៅ «បេក្ខជន៧រូបសម្រាប់ការកាត់សេចក្តី» ជាសៀវភៅដែលនិពន្ធចុងក្រោយបង្អស់ ។ លោកស៊ីវ ក៏បានសរសេរសៀវភៅ «ការឃោសនា នយោបាយ និងអំពីហិង្សានៅកម្ពុជា» និង «កម្ពុជាៈ ការគ្រប់គ្រងនិងការរើបម្រះ» ។ គាត់មានសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែកនយោបាយពីសាកលវិទ្យាល័យទីក្រុងឡុងដ៍ ។ ថ្មីៗនេះ គាត់បានផ្អាកការបង្រៀនរបស់គាត់មួយរយៈពី “សាលាសិក្សាអំពីអាហ្វ្រិកនិងលោកខាងកើត» នៅប្រទេសអង់គ្លេស ។

ហេឡែន ហ្សារីស បានមកប្រទេសកម្ពុជាមុនដំបូងកាលពីឆ្នាំ១៩៦៧ ។ ម្ភៃឆ្នាំក្រោយមក ហ្សារីស ត្រឡប់មកកម្ពុជាម្តងទៀតដើម្បីជួយកម្ពុជាក្នុងការកសាងបណ្ណាល័យជាតិ ។ ចាប់ពីឆ្នាំ១៩៩៥ដល់ឆ្នាំ២០០១ លោកស្រីធ្វើការជាអ្នកពិគ្រោះយោបល់ក្នុងការចងក្រងឯកសារសម្រាប់ “កម្មវិធីឧក្រិដ្ឋកម្មនៅកម្ពុជា» ។ នៅក្នុងឆ្នាំ១៩៩៩ លោកស្រីក្លាយទីប្រឹក្សារបស់ឯកឧត្តម សុខ អាន ដែលជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលសម្រាប់រៀបចំការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។ លោកស្រីមានសញ្ញាប័ត្រថ្នាក់បណ្ឌិតលើការសិក្សាអំពីប្រទេសឥណ្ឌូនេស៊ី ហើយជាសហអ្នកនិពន្ធសៀវភៅមួយដែលនឹងបោះពុម្ពផ្សាយក្នុងពេលឆាប់ៗនេះ មានចំណងជើងថា «ការគេចចេញពីបទល្មើសប្រល័យពូជសាសន៍» ។ សៀវភៅនោះនឹងសិក្សាអំពីបញ្ហាយុត្តិធម៌និងសាលាជំនុំជម្រះក្តីខ្មែរក្រហម ។ លោកស្រី ហេឡែន ក៏បានទទួលកិត្តិយសជាសញ្ជាតិខ្មែរ-អូស្ត្រាលីមួយរូប

ដែរ ។ ដូច្នេះលោកស្រីនៅទីនេះមិនមែនគ្រាន់តែជាអ្នកជំនាញការមួយរូបទេ ប៉ុន្តែក្នុងនាមជាពលរដ្ឋនៃប្រទេសនេះ ។

ជាចុងក្រោយ យើងមានឯកឧត្តម កែវ រ៉េមី ជាសមាជិកសភារបស់គណបក្សប្រឆាំង ។ ឯកឧត្តម រ៉េមី ក៏ជាជនរងគ្រោះនៃរបបខ្មែរក្រហមដែរ ។ លោកបានបាត់បង់សមាជិកគ្រួសារចំនួន៧រូប ។ នៅក្នុងឆ្នាំ១៩៨៦លោកបានទៅរស់នៅឯជំរំជនភៀសខ្លួននៅតាមព្រំដែនកម្ពុជា-ថៃ ហើយបានក្លាយជាសមាជិកគណបក្សហ៊្វុនស៊ិនប៉ិច ។ ក្នុងរយៈពេលដ៏ខ្លីបន្ទាប់ពីមករស់នៅក្នុងជំរំជនភៀសខ្លួន ឯកឧត្តម រ៉េមី ក៏បានទៅរស់នៅសហរដ្ឋអាមេរិក ហើយត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៩១ ។ ចាប់ពីឆ្នាំ១៩៩៨ដល់ឆ្នាំ២០០៣ លោកជាសមាជិកក្នុងគណៈកម្មាធិការដឹកនាំរបស់បក្សហ៊្វុនស៊ិនប៉ិច ដែលមានទំនាក់ទំនងជាមួយនឹងគណបក្សសមរង្ស៊ី ។ ការពិភាក្សានឹងចាប់ផ្តើមដោយលោក ស៊ីវ ។

**ស៊ីវ ហេង័រៈ** ខ្ញុំនឹងព្យាយាមដោះស្រាយសំណួរដែលទាក់ទង ប៉ុន្តែមិនមែនឆ្លើយទៅនឹងសំណួរទាំងនោះទេ ហើយខ្ញុំគិតថាដើម្បីដោះស្រាយសំណួរទាំងនេះ យើងត្រូវចាប់ផ្តើមជាមួយនឹងចំណុចចាប់ផ្តើមចំនួនពីរ ។ ចំណុចទីមួយៈ មានអំណះអំណាងដែលគ្មានមតិជំទាស់មួយថា សាលាជំនុំជម្រះក្តីគឺមានសារសំខាន់ ហើយប្រាកដណាស់គឺប្រសើរជាងមិនធ្វើអ្វីទាល់តែសោះ ។ បើមិនដូច្នោះទេ ជនទាំងឡាយដែលនៅរស់រានមានជីវិតហើយដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយបក្សកុម្មុយនិស្តកម្ពុជា ប្រាកដជានឹងអាចរួចផុតពីការដាក់ទណ្ឌកម្ម ឬក៏អាចនៅជាប់ឃុំឃាំងមិនមានរយៈពេលកំណត់ដោយមិនបានទទួលការកាត់សេចក្តី ហើយនេះជាលទ្ធផលដែលមិនអាចទទួលយកបាន ។ ចំណុចទីពីរៈ បើទោះបីជាយើងបាត់បង់ឱកាសក្នុងការធ្វើឲ្យច្បាប់និងកិច្ចព្រមព្រៀងមានភាពប្រសើរជាងមុនក៏ដោយ ក៏មិនមានកំហុសច្រើនប៉ុន្មានដែរចំពោះអត្ថបទច្បាប់ទាំងពីរនេះ ទាំងខាងផ្នែកសិទ្ធិមនុស្សនិងផ្នែកស្វែងរកការពិត ។ ទន្ទឹមនឹងនោះ យើងត្រូវតែទទួលស្គាល់ថាមានបញ្ហាធំៗចំនួន៥ ។

បញ្ហាទីមួយគឺ សាលាជំនុំជម្រះក្តីនេះប្រហែលជាអាចកាត់សេចក្តីដោយយុត្តិធម៌ ប៉ុន្តែមិនសូវជាពេញលេញប៉ុន្មានទេ ដោយសារតែការធ្វើអន្តរាគមន៍មិនត្រឹមត្រូវតាមច្បាប់ពីសំណាក់អ្នកនយោបាយ មន្ត្រីរដ្ឋាភិបាល និងតំណាងរដ្ឋាភិបាលប្រទេសផ្សេងៗ ។ ខ្ញុំនិយាយដូច្នេះគឺសំអាងទៅលើការព្យាករណ៍ទុកជាមុនដោយយោងលើបទពិសោធន៍ពីអតីតកាលដែលក្នុងនោះប្រព័ន្ធយុត្តិធម៌កម្ពុជាខ្វះខាតភាពយុត្តិធម៌និងភាពឯករាជ្យដែលករណីនយោបាយមិនដែលត្រូវបានដោះស្រាយដោយយុត្តិធម៌ម្តងណាឡើយ ។ ខ្ញុំនឹកឃើញតែឧទាហរណ៍មួយគត់គឺកាលពីទសវត្សរ៍កន្លងទៅដែលតុលាការកម្ពុជាកាត់សេចក្តីករណីនយោបាយមួយដោយវាយតម្លៃទៅលើភស្តុតាង ហើយចេញសាលក្រមសម្រេចសេចក្តីដោយមិនទទួលឥទ្ធិពលនយោបាយ ។ ការព្រួយបារម្ភដោយផ្អែកលើបទពិសោធន៍កន្លងមកអំពីភាពមិនយុត្តិធម៌នៅក្នុងការកាត់សេចក្តីករណីនយោបាយគឺកើតចេញពីបទពិសោធន៍ដ៏ជូរចត់ដែលក្នុងនោះឥទ្ធិពលរបស់អ្នកនយោបាយគ្របដណ្តប់លើតុលាការមិនអាចកែប្រែភ្លាមៗដោយកម្មវិធីបង្កើនសមត្ថភាពឬក៏កែប្រែក្នុងរយៈពេលខ្លីបានទេ ។ កម្មវិធីនេះត្រូវបានអនុវត្តនៅកម្ពុជាជាងមួយទសវត្សរ៍មកហើយ ប៉ុន្តែលទ្ធផលដែលទទួលបានកន្លងមកគឺតិចតួចបំផុត ហើយប្រទេសផ្តល់ជំនួយភាគច្រើនយល់កាន់តែច្បាស់អំពីស្ថានភាពនេះ និងមានថ្លែងជាសាធារណៈទៀតផង ។ ទាក់ទងនឹងបញ្ហានេះ ខ្ញុំសូមសង្កត់ធ្ងន់ថា បញ្ហាជាសារវ័ន្តគឺមិនមែនកង្វះខាតចំណេះដឹង ឬក៏ការហ្វឹកហ្វឺនចំណេះដឹងនៅក្នុងប្រព័ន្ធយុត្តិធម៌នោះទេ បើទោះបីជាចំណុចទាំងពីរនេះពិតជាត្រូវការយ៉ាងខ្លាំងក៏ដោយ ។ បញ្ហានោះគឺជាការប្តេជ្ញាចិត្តរបស់អ្នកនយោបាយសំខាន់ៗក្នុងការធានាថា អ្នកបម្រើការនៅក្នុងតុលាការនឹងយកចំណេះដឹងរបស់ខ្លួនទៅប្រើប្រាស់ឲ្យបានត្រឹមត្រូវ ។ ខ្ញុំមិនបន្ទោសលើចំណុចនេះទេ ប៉ុន្តែគ្រាន់តែចង់លើកឡើងថា សកម្មភាពមិនស្មោះត្រង់ដែលបានអនុវត្តទាក់ទងនឹងករណីសម្លាប់មេដឹកនាំសហជីពកម្មករ លោក ជា វិជ្ជា និងការបោះឆ្នោតរបស់គណៈមេធាវីនាពេលថ្មីៗនេះ បានបង្ហាញឲ្យឃើញថា តុលាការកម្ពុជាមិនមានការផ្លាស់ប្តូរទេជុំវិញបញ្ហាទទួលឥទ្ធិពលនយោបាយ ។ ទោះជាយ៉ាងណាក្តី ករណីទាំងពីរខាងលើនេះបង្ហាញថា ប្រសិនបើទុកលទ្ធភាពឲ្យចៅក្រមនិងមេធាវីកម្ពុជាធ្វើការងារតាមសមត្ថភាពរៀងៗខ្លួនដោយឥត

មានការលូកដៃពីសំណាក់អ្នកនយោបាយ ចៅក្រមនិងមេធាវីទាំងនេះប្រាកដជាអាចវាយតម្លៃភ័ស្តុតាងនិងអនុវត្តឯករាជ្យភាពរបស់ខ្លួនជាមិនខាន ។ ជាការពិត ចៅក្រមនិងមេធាវីកម្ពុជាពិតជាចង់ធ្វើយ៉ាងនេះប្រសិនបើមានឱកាស ។ នេះជាបញ្ហាធំទីមួយ ។

បញ្ហាទីពីរគឺថា មានហេតុផលសមរម្យមួយក្នុងការជឿជាក់ថាពិតជាមានចេតនាក្នុងការធានាថា បញ្ជីឈ្មោះជនសង្ស័យដែលនឹងត្រូវកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញគឺត្រូវបានកំណត់ទុកជាមុនដើម្បីការពារជនល្មើសជាច្រើននាក់ (មួយចំនួនកំពុងតែកាន់តំណែងនៅក្នុងរដ្ឋាភិបាល) ពីការប្រឈមមុខនឹងសាលាកាត់ក្តីនិងពីភាពអាម៉ាស់ ។ អត្ថបទច្បាប់និងកិច្ចព្រមព្រៀងអាចនិយាយបានថាអាចទទួលយកបានប្រសិនបើមិនមានបញ្ហា ។ បើទោះបីជាមានបញ្ហាជាមួយនឹងការកំណត់ទុកជាមុននូវមេដឹកនាំជាន់ខ្ពស់របស់របបខ្មែរក្រហម នៅក្នុងច្បាប់និងកិច្ចព្រមព្រៀងក៏ដោយ ក៏បញ្ហានេះអាចការពារបានជាពិសេសដោយសារតែច្បាប់នេះបានចែងអំពីលំដាប់ទីពីរនៃជនសង្ស័យដែរ គឺអ្នកទាំងឡាយដែលមិនមែនជាអ្នកដឹកនាំជាន់ខ្ពស់ប៉ុន្តែស្ថិតនៅក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនិស្តកម្ពុជា ។ បញ្ហាគឺចេតនាដែលមានសរសេរនិងមិនមានសរសេរនៅក្នុងអត្ថបទច្បាប់ ដើម្បីកម្រិតការចោទប្រកាន់ឲ្យនៅត្រឹមមួយក្តាប់តូចនៃមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនិស្តកម្ពុជានិងជនដៃដល់ដែលមានកេរ្តិ៍ឈ្មោះអសោចពីរបីនាក់ទៀតដែលគួរឲ្យកត់សម្គាល់នោះគឺកម្មាភិបាលនៃមន្ទីរសន្តិសុខមជ្ឈិម ស-២១ (ឬទួលស្លែង) ។ នេះគឺជាបញ្ហា ពីព្រោះភ័ស្តុតាងបង្ហាញថា អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតរួមមានទាំងកម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាផង នឹងអាចជាបេក្ខជនសម្រាប់ការកាត់សេចក្តី ។

អ្នកទាំងអស់គ្នាពិតជាឆ្ងល់អំពីចំនួនអ្នកដែលសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនឹងចោទប្រកាន់ ។ ខ្ញុំសូមបង្ហាញនូវតួលេខស្មានរបស់ខ្ញុំ ។ នៅពេលដែលបក្សកុម្មុយនិស្តកម្ពុជាកំពុងកាន់អំណាច ក្បាលម៉ាស៊ីនដឹកនាំជាន់ខ្ពស់មានសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ពី២០ទៅ៣០នាក់ និងកម្មាភិបាលដែលមានអំណាចពីថ្នាក់មជ្ឈិមទៅថ្នាក់មូលដ្ឋានមានចំនួនប្រហែល១ពាន់នាក់ ។ ក្នុងចំណោមនោះ មានតែប្រហែលជាងពាក់កណ្តាលប៉ុណ្ណោះដែលនៅរស់រានមានជីវិតពីការបោសសម្អាតដែលចាប់ផ្តើមធ្វើនៅក្នុងជួរបក្សនៅឆ្នាំ១៩៧៦ និងបន្តបោសសម្អាតកាន់ខ្លាំងនៅឆ្នាំ១៩៧៧និង១៩៧៨ ។ ចាប់តាំងពីពេលនោះមក អ្នកដែលនៅសល់ជីវិតពីរបបនោះមានចំនួនកាន់តែតិចទៅៗ ។ ប្រសិនបើយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញអាចចោទប្រកាន់ទៅដល់ថ្នាក់ស្រុក ខ្ញុំគិតថាមានមិនលើសពីពីរ-បីរយនាក់ទេដែលនៅមានជីវិត ។ និយមន័យរបស់ “មេដឹកនាំជាន់ខ្ពស់” និង “អ្នកទទួលខុសត្រូវខ្ពស់បំផុត” និងភ័ស្តុតាងដែលមាន នឹងកំណត់ថាតើប៉ុន្មាននាក់នៃចំនួននេះអាចជាមុខសញ្ញានៃការស៊ើបអង្កេត ។ តាមការសន្និដ្ឋានរបស់ខ្ញុំគឺថាមិនច្រើនជាង៦០ករណីទេដែលត្រូវជាមួយនឹងប្រភេទពីរនេះ ដែលក្នុងនោះប្រហែលជាមេដឹកនាំជាន់ខ្ពស់១០នាក់និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំនួន៥០នាក់ ។

ខ្ញុំដឹងច្បាស់ថាសំណួរបន្ទាប់មកទៀតដែលអ្នកទាំងឡាយចាប់អារម្មណ៍នោះគឺ “អ្នកទាំងនោះជានរណា?” ។ ខ្ញុំតែងតែលើកឡើងពីបញ្ហានេះ ប៉ុន្តែខ្ញុំសូមនិយាយសាជាថ្មីម្តងទៀតនូវអ្វីដែលខ្ញុំតែងតែលើកឡើងទាំងក្នុងការសរសេរនិងក្នុងបទសម្ភាសន៍ ។ ថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចេញផ្សាយសៀវភៅមួយដែលកែប្រែខ្លះៗនូវអ្វីដែលខ្ញុំបានសរសេរកាលពីពីរ-បីឆ្នាំកន្លងទៅ ។ សៀវភៅនោះមានចំណងជើងថា “បេក្ខជន៧រូបសម្រាប់ការកាត់សេចក្តី” ដែលក្នុងនោះមានរាយឈ្មោះមេដឹកនាំជាន់ខ្ពស់៧រូបដែលនៅមានជីវិត ហើយភ័ស្តុតាងបញ្ជាក់អំពីកំហុសរបស់អ្នកទាំងនោះមាននៅក្នុងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្នុងចំណោមបេក្ខជនទាំង៧រូប ៦រូបនៅមានជីវិតនៅឡើយ បច្ចុប្បន្ននេះ ហើយនឹងនៅតែស្ថិតក្នុងវង្វង់នៃការចោទប្រកាន់ដដែល ។ អ្នកទាំងនេះមាន នួន ជា, អៀង សារី, ខៀវ សំផន, តា ម៉ុក, ស៊ូ ម៉េត និង មាស មុត ។ ជាការពិតណាស់ នៅក្នុងសៀវភៅនេះមានសរសេរថា មានភ័ស្តុតាងយ៉ាងច្រើនសម្រាប់ប្រឆាំងនឹង ឌុច ដែលជាប្រធានមន្ទីរ ស-២១ ហើយភ័ស្តុតាងទាំងនេះកំពុងតែបន្តកើនឡើង ។ ដូច្នេះ ឌុច ប្រាកដជាបេក្ខជនមួយរូបដែរ ។

ម្យ៉ាងវិញទៀត កាលពីប៉ុន្មានឆ្នាំមុន ខ្ញុំ និង ក្រេក

អេចឆេសាន់ ដែលជាអ្នកស្រាវជ្រាវអំពីខ្មែរក្រហមដែរ បានចេញសេចក្តីថ្លែងការណ៍មួយ យើងមិនមានភស្តុតាងទាក់ទងនឹងលោក ហ៊ុន សែន នៅក្នុងបទល្មើសរបស់បក្សកុម្មុយនិស្តកម្ពុជាទេ ។ អ្នកទាំងអស់គ្នានៅតែអាចរកមើលសេចក្តីថ្លែងការណ៍នេះបាននៅក្នុងវែបសាយផ្សេងៗរបស់រដ្ឋាភិបាល ។ ខ្ញុំចង់ឆ្លៀតយកឱកាសនេះដើម្បីនិយាយថា ប៉ុន្មានឆ្នាំទៅមុខទៀត ឯកសាររាប់ម៉ឺនទំព័រនឹងកើនឡើង បទសម្ភាសន៍រាប់ពាន់ក៏នឹងកើនឡើងដែរ ប៉ុន្តែសេចក្តីថ្លែងការណ៍នោះនៅពិតដដែល ។ ខ្ញុំចង់បញ្ជាក់បន្ថែមទៀតថា តាមចំណេះដឹងរបស់ខ្ញុំ គ្មានអ្នកដែលកំពុងកាន់តំណែងនៅក្នុងរដ្ឋាភិបាលណាម្នាក់ស្ថិតនៅក្នុងប្រភេទអ្នកដែលនឹងត្រូវចោទប្រកាន់ឲ្យទទួលខុសត្រូវបទល្មើសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ខ្ញុំយល់ថា នេះជាអ្វីដែលអ្នកទាំងអស់គ្នាជឿជាក់ ប៉ុន្តែមិនមានភស្តុតាង ។ ខ្ញុំសូមបន្ថែមថា អ្នកដទៃទៀតដែលអាចចូលទៅក្នុងប្រភេទនៃអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនេះ គឺជាមនុស្សដែលមិនមានកេរ្តិ៍ឈ្មោះអាសោច ឬជាមនុស្សដែលគ្មាននរណាស្គាល់ ។ អ្នកដែលនៅក្នុងបន្ទប់នេះប្រហែលជាមិនធ្លាប់ឮឈ្មោះអ្នកទាំងនោះផង ។ ចំណុចនេះបាននាំឲ្យខ្ញុំឈានទៅដល់ការសន្និដ្ឋានថា បើទោះបីជាការពិតទាំងមូលអំពីអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតដទៃទៀតត្រូវបានលាតត្រដាង ក៏ខ្ញុំគិតថាការណ៍នេះនឹងមិននាំឲ្យសង្គមធ្លាក់ចុះឬបែកបាក់ទេ ។

ក៏ប៉ុន្តែ មានបញ្ហាទីបីដែលជាបញ្ហាដ៏ធំទាក់ទងនឹងការលាតត្រដាងការពិត ។ នោះគឺថា ប្រសិនបើសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញមិនមានភាពយុត្តិធម៌ ហើយការកាត់សេចក្តីរបស់សាលាជំនុំជម្រះក្តីនេះត្រូវកម្រិតដោយកត្តានយោបាយជាជាងច្បាប់នោះ សាលាជំនុំជម្រះក្តីមួយនេះនឹងមិនបន្ថែមឲ្យយើងនូវចំណេះដឹងអំពីមូលហេតុនិងអ្វីដែលកើតឡើងនៅក្រោមរបបខ្មែរក្រហមទេ ។ សំខាន់បំផុតនោះគឺថា សាលាជំនុំជម្រះក្តីនេះមិនអាចដោះស្រាយនូវអ្វីដែលខ្ញុំមើលឃើញថាជាសំណួរមានលក្ខណៈប្រវត្តិសាស្ត្រសំខាន់ជុំវិញបទល្មើសរបស់បក្សកុម្មុយនិស្តកម្ពុជា ពោលគឺៈ ក) តើបទល្មើសនេះជាលទ្ធផលនៃការសមគំនិតគ្នារវាងមេដឹកនាំខ្លះ ឬទាំងអស់ ដើម្បីឲ្យអ្នកនៅក្រោមបង្គាប់របស់ខ្លួនប្រព្រឹត្ត? ឬ ខ) បទឧក្រិដ្ឋកម្មនេះជាលទ្ធផលនៃការប្រើប្រាស់មិនសមរម្យនូវអំណាចដែលបានផ្ទេរឲ្យ មានន័យថាជាការប្រព្រឹត្តដោយមិនមានបញ្ជា ឬក៏ផ្ទុយទៅនឹងបញ្ជារបស់ថ្នាក់លើ ហើយដែលថ្នាក់លើមិនបានដឹងពីការប្រព្រឹត្តនេះ? ដោយផ្អែកលើភស្តុតាងដែលមានកន្លងមក ទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំគឺថា យើងត្រូវតែលាតត្រដាង វិភាគ និងយល់ឲ្យបានច្បាស់នូវចំណុចទាំងពីរខាងលើ ប្រសិនបើយើងពិតជាចង់ធ្វើឲ្យមានការរីកចម្រើននូវការទទួលខុសត្រូវផ្នែកច្បាប់ ផ្នែកប្រវត្តិសាស្ត្រ និងផ្នែកសីលធម៌ នៃបទឧក្រិដ្ឋរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ការដោះស្រាយនូវបញ្ហានេះក៏ជួយយើងក្នុងការប្រឈមមុខនឹងការពិភាក្សាជាញឹកញាប់អំពីមូលហេតុនៃឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនិស្តកម្ពុជា ថាតើឧក្រិដ្ឋកម្មនេះជាលទ្ធផលនៃឥទ្ធិពលមនោគមវិជ្ជាបរទេស ឬក៏ឥទ្ធិពលនៃសារជាតិវប្បធម៌ខ្លួនឯង ។ សូម្បីតែការជំនុំជម្រះសេចក្តីដែលយុត្តិធម៌និងគ្រប់ជ្រុងជ្រោយបំផុតក៏មិនអាចផ្តល់ចម្លើយនេះបានដែរ ហើយការពិភាក្សាដែលស្រដៀងគ្នានេះនៅតែបន្តក្នុងចំណោមអ្នកដែលព្យាយាមពន្យល់ពីការសម្លាប់រង្គាលជនជាតិជ្វីហ្វ អំពើប្រល័យពូជសាសន៍នៅរ៉ាន់ដា និងការសម្លាប់រង្គាលនៅសហភាពសូវៀត ប៉ុន្តែការពិភាក្សាទាំងនេះមិនទាក់ទងទៅនឹងយុត្តិធម៌នៃការជំនុំជម្រះសេចក្តីទេ ។ គំនិតរបស់ខ្ញុំនោះគឺថា ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញអាចកាត់សេចក្តីដោយយុត្តិធម៌ ការជំនុំជម្រះសេចក្តីទាំងអស់នេះនឹងអាចរួមចំណែកសំខាន់ក្នុងការស្វែងរកមូលហេតុនៃឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហម ។

នៅទីនេះ ខ្ញុំចង់ត្រឡប់ទៅរកការផ្តល់យោបល់ពីដំបូងរបស់ខ្ញុំដែលថា ការកំណត់ទុកជាមុននូវមេដឹកនាំជាន់ខ្ពស់គឺមានបញ្ហា ប៉ុន្តែបញ្ហានេះអាចការពារបាន ។ ខ្ញុំគិតថាមិនមែនជាបញ្ហាចាំបាច់ទេក្នុងការបង្កើតនូវគោលការណ៍ទទួលខុសត្រូវមួយដែលថា ប្រសិនបើអ្នកជាមេដឹកនាំជាន់ខ្ពស់ អ្នកត្រូវតែទទួលកំហុស ទោះបីជាកំហុសនោះតិចតួចជាងមេដឹកនាំជាន់ខ្ពស់ដទៃទៀត ឬតិចតួចជាងអ្នកដែលមានឋានៈទាបជាងអ្នកក៏ដោយ ។ មានកំហុសតិចតួចជាងអ្នកដទៃមិនមែនមានន័យថាគ្មានកំហុសនោះទេ ហើយក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ ជាពិសេសអ្នកដែល

ល្បីនិងមានឥទ្ធិពល (ទោះបីជាមិនមែនជាអ្នកដែលមានអំណាចខ្ពស់បំផុត) មានន័យថាអ្នកមានការទទួលខុសត្រូវពិសេសមួយរួចទៅហើយ ។ ការកំណត់ទុកជាមុននូវមេដឹកនាំជាន់ខ្ពស់បានធ្វើឲ្យអ្នកទាំងឡាយយល់ថា បទល្មើសទាំងអស់ ឬស្ទើរតែទាំងអស់ គឺជាលទ្ធផលនៃការសមគំនិតគ្នារវាងថ្នាក់លើនិងថ្នាក់ក្រោម ហើយដែលខ្ញុំមើលឃើញថាមានបញ្ហានោះគឺនៅពេលដែលការយល់ឃើញនេះមិនមែនជាការពិត ។ ការដោះស្រាយបញ្ហាទាំងនេះនឹងធ្វើឲ្យអ្នកនយោបាយមួយចំនួនទទួលនូវការអាម៉ាស់ជាមិនខាន ។ បើទោះបីមិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតក៏ដោយក៏អ្នកនយោបាយទាំងនោះមិនចង់ឲ្យនរណាដឹងថា ខ្លួនជាអតីតខ្មែរក្រហមដែរ ។ សូម្បីតែអតីតទាហានខ្មែរក្រហមតូចតាចក៏មិនចង់ឲ្យនរណាស្គាល់ដែរ ប៉ុន្តែខ្ញុំគិតថាអ្នកទាំងនេះជាមនុស្សសំខាន់សម្រាប់ការស្វែងយល់ពីមូលហេតុដែលថ្នាក់ក្រោមបានសម្លាប់មនុស្សនៅគ្រប់ទីកន្លែង ។ លុះត្រាតែប្រជាជនកម្ពុជានិងអ្នកទាំងអស់គ្នាស្វែងយល់អំពីចំណុចសំខាន់នៃបញ្ហានេះ បើមិនដូច្នេះទេ កេរដំណែលនៃបទល្មើសរបស់បក្សកុម្មុយនិស្តកម្ពុជានៅតែមានទម្ងន់ដដែល ។ ខ្ញុំមើលមិនឃើញថា សាលាជំនុំជម្រះក្តីនេះអាចជួយយើងឲ្យដើរលើផ្លូវមួយនេះបានឆ្ងាយឡើយ ។

បញ្ហាទីបួនគឺថា ប្រសិនបើការកាត់សេចក្តីរបស់សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមបង្ហាញថាប្រព័ន្ធតុលាការនៅកម្ពុជាអាចបំពេញភារកិច្ចរបស់ខ្លួនដោយឯករាជ្យ មិនលម្អៀង និងយុត្តិធម៌នោះ សាលាជំនុំជម្រះក្តីនេះនឹងមានផលប្រយោជន៍ជាវិជ្ជមានដល់ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា រួមទាំងការធ្វើកំណែទម្រង់ផ្នែកច្បាប់និងតុលាការផង ។ ផ្ទុយមកវិញ ប្រសិនបើសាលាជំនុំជម្រះក្តីនេះមិនអាចបំពេញភារកិច្ចរបស់ខ្លួនដោយឯករាជ្យ យុត្តិធម៌ និងមិនម្អៀងទេ ឥទ្ធិពលដែលទទួលបានប្រាកដជាអវិជ្ជមានជាមិនខាន ។

បញ្ហាទីប្រាំនោះគឺថា សហគមន៍អន្តរជាតិចង់ឲ្យអ្វីៗដំណើរការទៅដោយអស់ថវិកាតិចបំផុត ។ ការណ៍នេះនឹងធ្វើឲ្យបញ្ហារបស់សាលាជំនុំជម្រះក្តីនេះកាន់តែធ្ងន់ធ្ងរឡើង ។ ជាការពិតណាស់ ការចំណាយអស់ថវិកាច្រើនមិនប្រាកដថានឹងទទួលបានសាលាជំនុំជម្រះក្តីដែលល្អនោះទេ ប៉ុន្តែការចំណាយថវិកាតិចប្រាកដជាធ្វើឲ្យចុះថយនូវលទ្ធភាពដែលអាចធ្វើឲ្យសាលាជំនុំជម្រះក្តីប្រសើរឡើងជាមិនខាន ។

គោលការណ៍ដែលជាបទដ្ឋានសម្រាប់ខ្ញុំគឺថា ប្រសិនបើរដ្ឋាភិបាលមានភាពក្លាហាននិងព្យាយាម ហើយប្រសិនបើអ្នកដែលចង់ឲ្យមានសាលាជំនុំជម្រះក្តីនេះក្លាហាននិងព្យាយាមដែរនោះ យើងនឹងមានឱកាសក្នុងការធ្វើឲ្យសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនេះទទួលបានផលល្អតាមថវិកាដែលចំណាយ ។ ខ្ញុំមិនលាក់ទេ ខ្ញុំមែនជាអ្នកដែលមានសុទិដ្ឋិនិយមបំផុតទេជុំវិញបញ្ហាសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ហើយខ្ញុំក៏គិតថាមិនមានមនុស្សប៉ុន្មាននាក់ដែរដែលមានទុទិដ្ឋិនិយមច្រើនជាងខ្ញុំជុំវិញបញ្ហានេះ ។ ប៉ុន្តែខ្ញុំនៅតែនិយាយថា លទ្ធផលរបស់ "អង្គជំនុំជម្រះវិសាមញ្ញ" នៅតែវិជ្ជមាននិងមានតម្លៃ បើទោះបីជាមានអ្នកខ្លះសន្និដ្ឋានថា ការជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញប្រាកដជាមិនសុក្រឹត មិនពេញលេញ ទុកចោលសំណួរជាច្រើនមិនដោះស្រាយ ហេតុដូច្នេះហើយតម្រូវឲ្យមានការស្រាវជ្រាវ ការស៊ើបអង្កេត ការត្រួតពិនិត្យ និងការពិភាក្សាផ្នែកច្បាប់និងប្រវត្តិសាស្ត្របន្ថែមទៀត ។ ទោះបីជាការកាត់សេចក្តីនោះយុត្តិធម៌ពេញលេញនិងមិនមានការលូកដៃពីសំណាក់អ្នកនយោបាយយ៉ាងណាក៏ដោយ ក៏នោះមិនមែនជាចំណុចបញ្ចប់នៃការពិភាក្សាទេ ។ សញ្ញាណនៃ "ការបិទទំព័រប្រវត្តិសាស្ត្រ" គឺផ្ទុយគ្នាពីការស្វែងរកការពិតនិងការស្វែងយល់ ហើយក៏ផ្ទុយគ្នានឹងយុត្តិធម៌និងការការពារមិនឲ្យកើតឡើងម្តងទៀតដែរ ។

**ហេឡែន ហ្សាវីសៈ** ខ្ញុំនិយាយនេះក្នុងនាមខ្លួនខ្ញុំផ្ទាល់ ។ សព្វថ្ងៃនេះខ្ញុំកំពុងតែធ្វើការជាមួយក្រុមការងាររបស់រាជរដ្ឋាភិបាលសម្រាប់រៀបចំការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ប៉ុន្តែខ្ញុំមិនមែនជាអ្នកនាំពាក្យរបស់រដ្ឋាភិបាលទេ ។ ខ្ញុំចង់និយាយបន្តិចអំពីអ្វីដែលប្រជាជនកម្ពុជា រដ្ឋាភិបាលកម្ពុជា និងអ្នកដទៃទៀតចង់បាននោះគឺៈ ការបង្កើតសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ ខ្ញុំសូមចាប់ផ្តើមជាមួយនឹងសំណួរទីពីរ "តើសាលាជំនុំជម្រះក្តីនេះមានអត្ថប្រយោជន៍ឬទេ ហើយបង្កើតសម្រាប់អ្នកណា?" ។ ខ្ញុំសូមចាប់ផ្តើមដោយពិចារណាអំពីសាធារណជនទូទៅ ហើយខ្ញុំនឹកឃើញថាមានការស្ទាបស្ទង់មតិមួយចំនួន

ដែលមានការខ្វះខាតច្រើនទាំងចំនួនមនុស្សទាំងផ្នែកវិធីសាស្ត្រ ប៉ុន្តែអ្វីដែលល្អនោះគឺជាលទ្ធផលដែលដូចគ្នានៃការស្ទាបស្ទង់មតិ ។ ខ្ញុំមិនទាន់បានមើលឯកសារស្ទង់មតិនេះឡើងវិញនៅឡើយទេ ប៉ុន្តែបើយោងទៅតាម គ្រេក អេចឆេសាន់ មានការស្ទង់មតិប្រហែល១០ដែលបានធ្វើកាលពីទសវត្សរ៍កន្លងទៅ ហើយលទ្ធផលដែលទទួលបានគឺដូចគ្នាច្រើន ដែលក្នុងនោះ៨០ភាគរយបានគាំទ្រឲ្យមានការទទួលខុសត្រូវតាមផ្លូវច្បាប់ ។ ខ្ញុំសូមលើកឡើងនូវការស្ទង់មតិរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមអំពីសំណួរថាតើសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមមានអត្ថប្រយោជន៍ឬមិនមានអត្ថប្រយោជន៍ដល់ការផ្សះផ្សាជាតិ ។ លទ្ធផលដែលទទួលបានគឺ៨២ភាគរយគាំទ្រឲ្យមានតុលាការ ។ អ្នកដែលតាមដានបញ្ហានេះប្រហែលជាបានឮអំពីរបាយការណ៍កាលពីសប្តាហ៍មុនអំពីការស្ទង់មតិដែលធ្វើឡើងដោយវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ ដែលក្នុងនោះ៩៧ភាគរយឆ្លើយថាចង់បានតុលាការ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានការស្ទង់មតិមួយចំនួនដែរ ហើយខ្ញុំមិនដែលបានឮការស្ទង់មតិណាមួយប្រកាសថាប្រជាជនភាគច្រើនមិនចង់បានតុលាការនោះទេ ។ ប៉ុន្មានឆ្នាំចុងក្រោយនេះមិនទាន់មានការធ្វើប្រជាមតិទូទាំងប្រទេសឬក៏បោះឆ្នោតជាទូទៅអំពីសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនៅឡើយទេ ។

មានការស្ទាបស្ទង់មតិដ៏ទូលំទូលាយមួយកាលពីឆ្នាំ១៩៨៣ ដែលធ្វើឡើងដោយគណៈកម្មាធិការស្រាវជ្រាវរបស់រណសិរ្សអន្តរជាតិ ។ នៅរវាងឆ្នាំ១៩៨២និងឆ្នាំ១៩៨៣ គណៈកម្មាធិការនេះបានចុះទៅខេត្តក្រុងចំនួន១៩ ។ កាលណោះគឺធ្វើក្នុងទម្រង់ដែលហៅថា "ញត្តិ" ដែលប្រជាជនសរសេរអំពីអ្វីដែលបានកើតឡើងចំពោះខ្លួន ឬក៏កើតឡើងចំពោះអ្នកភូមិ រោងចក្រ ក្រុមពិសេសណាមួយ និងរាយការណ៍ពីចំនួនសមាជិកក្រុមគ្រួសារដែលបានបាត់បង់ជីវិត ។ល ។ ឥឡូវនេះមានភាពមិនច្បាស់លាស់ជាច្រើនអំពីបញ្ហានេះ និងដោយមិនមានការសង្ស័យនោះគឺការរាប់ចំនួនមនុស្សស្លាប់ដែលធ្វើដល់ទៅពីរដង ។ ឧទាហរណ៍ៈ មនុស្សម្នាក់រាយការណ៍ថា "ប្អូនស្រីរបស់ខ្ញុំត្រូវសម្លាប់" ហើយមនុស្សម្នាក់ផ្សេងទៀតរាយការណ៍ថាអ្នកដដែលនោះត្រូវសម្លាប់ ។ ក៏ប៉ុន្តែចំណុចសំខាន់នោះគឺថា មនុស្សជាងមួយលាននាក់បានផ្តិតមេដៃដើម្បីស្នើសុំឲ្យអង្គការសហប្រជាជាតិបដិសេធខ្មែរក្រហម និងចាត់វិធានការតាមផ្លូវច្បាប់ ។ នេះប្រហែលជាការស្ទង់មតិដែលទូលំទូលាយបំផុត ។

ខ្ញុំក៏ចង់ក្រឡេកមើលទៅបញ្ហាគោលជំហររបស់រដ្ឋាភិបាលនៅពេលនោះដែរ ។ ប្រសិនបើយើងត្រឡប់ទៅមុនពេលបង្កើតរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ពោលគឺពេលដែល ប៉ុល ពត នៅកាន់អំណាចនៅឡើយនោះ "រណសិរ្ស" (ដែលត្រូវបានបង្កើតនៅខែធ្នូឆ្នាំ១៩៧៨) បានអំពាវនាវឲ្យមានការដាក់ទោសអ្នកដែលពេលនោះគេហៅថាអ្នកជំពាក់បំណុលឈាមធ្ងន់ធ្ងរ និងអំពាវនាវឲ្យព្យាយាមកសាងប្រទេស ។ នោះជាគោលជំហរផ្លូវការរបស់ "រណសិរ្ស" នៅពេលដែលចូលកាន់អំណាចនិងផ្តួលរំលំខ្មែរក្រហម ។

នៅខែកក្កដាឆ្នាំ១៩៧៩ ក្រឹត្យច្បាប់លេខ១ដែលជាក្រឹត្យច្បាប់ដំបូងបំផុតរបស់របបថ្មី បានបង្កើត"តុលាការប្រជាជនបដិវត្តន៍" ដើម្បីកាត់ទោស ប៉ុល ពត និង អៀង សារី ពីបទប្រល័យពូជសាសន៍ ។ អ្នកទាំងអស់គ្នាប្រហែលជានៅចាំថា កាលពីខែសីហា ឆ្នាំ១៩៧៩ មានការកាត់សេចក្តីកំបាំងមុខមួយលើអ្នកទាំងពីរនេះ ។ ការកាត់សេចក្តីនេះបានអានរបាយការណ៍ពីគណៈកម្មាធិការ៨ផ្សេងៗគ្នា និងអត្ថបទពីសាក្សីប្រមាណ ៣៩រូប ហើយក្រុមការងារបានចុះទៅមើលកន្លែងផ្សេងៗនៅតាមខេត្តមួយចំនួន ។ តុលាការនេះបានទទួលនូវការរិះគន់យ៉ាងខ្លាំងក្លា ហើយត្រូវបានបដិសេធដោយប្រើពាក្យថាជា "តុលាការល្មោភ" ។ នេះជាបញ្ហាដ៏ស្មុគស្មាញមួយ ហើយយើងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីពិភាក្សាអំពីបញ្ហានេះនៅពេលនេះទេ ។ ខ្ញុំឆ្ងល់ថាមានលក្ខណៈសម្គាល់អ្វីខ្លះដែលអាចកំណត់ថាតុលាការមួយជាតុលាការល្មោភ ហើយក្នុងពិភពលោកសព្វថ្ងៃនេះមានតុលាការល្មោភចំនួនប៉ុន្មាន ។ ដូច្នេះខ្ញុំគិតថា ភាពទន់ខ្សោយរបស់ក្រុមការងារតុលាការរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាមិនមែនចម្លែកខុសគេនោះទេ ។ អ្វីដែលខ្ញុំចង់លើកឡើងនៅទីនេះគឺមិនមែនការពារថា"តុលាការប្រជាជនបដិវត្តន៍"មានភាពត្រឹមត្រូវនោះទេ ប៉ុន្តែដើម្បីបង្ហាញថានោះជាកិច្ចខិតខំប្រឹងប្រែងរបស់

រដ្ឋាភិបាលទាំងនៅពេលដែលខ្លួននៅខ្វះធនធានយ៉ាងខ្លាំងបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ។ អ្វីដែលអ្នកទាំងឡាយប្រហែលជាមិនដឹងនោះគឺថា ពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ រដ្ឋាភិបាលបានអំពាវនាវសុំឲ្យមានសាលាជំនុំជម្រះក្តីអន្តរជាតិ ។ សាលាជំនុំជម្រះក្តីនៅឆ្នាំ១៩៧៩មិនមានការទទួលស្គាល់ដូចដែលរដ្ឋាភិបាលរំពឹងទុក ។ តាមទស្សនៈរបស់ខ្ញុំ នេះប្រហែលជាដោយសារហេតុផលនយោបាយច្រើនជាងហេតុផលច្បាប់ ។ នៅពេលនោះទាំងរដ្ឋាភិបាលនិង"តុលាការប្រជាជនបដិវត្តន៍" មិនត្រូវបានទទួលស្គាល់ឡើយ ។ ពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ រដ្ឋាភិបាលនិង "រណសិរ្ស" និងអង្គការផ្សេងទៀត បានព្យាយាមរៀបចំសន្និសីទកិច្ចប្រជុំ និងបានផ្ញើញត្តិ ព្រមទាំងបានចូលរួមសន្និសីទសន្តិភាពនៅជុំវិញពិភពលោក និងបានអំពាវនាវឲ្យមានសាលាជំនុំជម្រះក្តី ។

នៅខែកញ្ញា ឆ្នាំ១៩៨៦ សម្តេច ហ៊ុន សែន បានសរសេរលិខិតផ្ញើជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងបានអំពាវនាវឲ្យមានសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ សូម្បីតែមុនពេលនោះ ពោលគឺនៅក្នុងឆ្នាំ១៩៧៩និងឆ្នាំ១៩៨០ ឯកសារផ្សេងៗសម្រាប់សាលាជំនុំជម្រះក្តីត្រូវបានផ្ញើជូនអង្គការសហប្រជាជាតិ ។ ហេតុដូច្នេះហើយមានការអំពាវនាវឲ្យមានសាលាជំនុំជម្រះក្តីច្រើនលើកណាស់ ។ ខ្ញុំគិតថាវាមានសារសំខាន់ក្នុងការលើកឡើងនូវករណីនេះ ពីព្រោះមនុស្សជាច្រើននៅតែនិយាយថាអ្វីដែលកើតឡើងសព្វថ្ងៃនេះគឺជារឿងថ្មីសុទ្ធសាធ ប៉ុន្តែខ្ញុំមិនកាន់គោលជំហរដូច្នេះទេ ។ មានអង្គការអ្នកច្បាប់ បញ្ញាជននិងសកម្មជនអន្តរជាតិជាច្រើនដែលបានព្យាយាមពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ដើម្បីឲ្យបង្កើតឡើងនូវសាលាជំនុំជម្រះក្តី ។ មានការព្យាយាមដើម្បីយកករណីនេះទៅដាក់ជូន"តុលាការយុត្តិធម៌អន្តរជាតិ" ។ មានកិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការព្យាយាមរករដ្ឋមួយដែលមានចំណាប់អារម្មណ៍ក្នុងរឿងក្តីនេះធ្វើជាភាគី (តុលាការយុត្តិធម៌អន្តរជាតិ) ដើម្បីដាក់ពាក្យបណ្តឹងចោទប្រកាន់នៅក្រោមអនុសញ្ញាប្រល័យពូជសាសន៍ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងនេះត្រូវបានធ្វើមិនដឹងមិនឮ ។

ក្រុមទីបីដែលខ្ញុំគិតថាគួរឲ្យចាប់អារម្មណ៍នោះគឺសភាជាតិ ។ នៅក្នុងឆ្នាំ១៩៨៣ សភាជាតិបានអនុម័តនូវសេចក្តីសម្រេចចិត្តមួយគាំទ្រការបង្កើតគណៈកម្មាធិការស្រាវជ្រាវដែលខ្ញុំបានលើកឡើងពីដំបូង ។ នៅឆ្នាំ២០០១ ក្នុងឱកាសពីរផ្សេងគ្នា (ខែមករា និងខែកក្កដា) រដ្ឋសភាជាតិបានអនុម័តច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ដោយសារតែត្រូវការធ្វើវិសោធនកម្មបច្ចេកទេស ច្បាប់នេះបានវិលត្រឡប់ទៅកាន់សភាជាលើកទីពីរហើយត្រូវបានអនុម័តជាឯកច្ឆន្ទ ។ នៅឆ្នាំនេះ (២០០៤) មានការបោះឆ្នោតចំនួនពីរលើកនៅក្នុងរដ្ឋសភាជាតិ ។ នៅថ្ងៃទី៤ ខែតុលា ការផ្តល់សច្ចាប័នទៅលើកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិត្រូវបានអនុម័តដោយសំឡេងគាំទ្រ១០៧សំឡេង លើ១០៧សំឡេង ។ នៅថ្ងៃបន្ទាប់នោះ វិសោធនកម្មលើច្បាប់ "បង្កើតអង្គជំនុំជម្រះវិសាមញ្ញ" ដើម្បីធ្វើឲ្យឯកសារទាំងពីរនេះស៊ីសង្វាក់គ្នា ត្រូវបានអនុម័តដោយសំឡេងគាំទ្រ៩៦លើ ៩៨សំឡេង ។ ដូច្នេះហើយ ខ្ញុំគិតថាគោលជំហររបស់រដ្ឋសភាក្នុងការការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅតែមិនផ្លាស់ប្តូរ ។

ឆ្លើយតបទៅនឹងសំណួរថា"តើអង្គជំនុំជម្រះវិសាមញ្ញ មានប្រយោជន៍ឬទេ" ខ្ញុំគិតថាអ្នកទាំងអស់គ្នាមិនត្រូវគិតត្រឹមតែក្នុងផ្នែកហិរញ្ញវត្ថុទេ ប៉ុន្តែត្រូវគិតដល់កិច្ចខិតខំប្រឹងប្រែងនិងចំណុចដែល ស៊ីវ បានលើកឡើងអំពីចលាចលសង្គមឬក៏ការគំរាមកំហែងដល់រចនាសម្ព័ន្ធសង្គមផង ។ ទាក់ទងទៅនឹងបញ្ហាថវិកា ខ្ញុំដឹងថាថ្មីៗនេះមានអ្នកខ្លះបាននិយាយថា គួរតែយកលុយ៥៧លានដុល្លារនេះទៅចំណាយលើអ្វីផ្សេងវិញ និងថា ប្រជាជនត្រូវការរបស់ផ្សេងៗមុនពេលត្រូវការសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ ខ្ញុំចង់និយាយថា ប្រសិនបើមិនមានសាលាជំនុំជម្រះក្តីនេះ យើងក៏នឹងមិនទទួលបានថវិកា៥៧លានដុល្លារសម្រាប់យកទៅធ្វើអ្វីផ្សេងដែលប្រជាជនត្រូវការដែរ ។ ខ្ញុំគិតថា លទ្ធភាពក្នុងការប្រើប្រាស់លុយសម្រាប់អភិវឌ្ឍន៍គឺមិនដូចគ្នាទៅនឹងលទ្ធភាពក្នុងការប្តេជ្ញាចិត្តចំពោះសាលាជំនុំជម្រះក្តីនេះទេ ។ ខ្ញុំគិតថានេះជាសំណួរទាក់ទងនឹងនយោបាយ ។

រឿងនេះក៏មានការទាក់ទងទៅនឹងការចូលរួមរបស់ប្រទេសដទៃៗទៀត ដូច្នេះខ្ញុំគិតថា ប្រសិនបើយើងមិនបង្កើតសាលាជំនុំជម្រះក្តី យើងក៏នឹងមិនទទួលបាននូវថវិកាច្រើនជាងនេះសម្រាប់ការចំណាយផ្សេងៗដែរ ។ ខ្ញុំគិតថាអ្នកទាំងអស់គ្នា

ប្រាកដជាសួរអំពីការចំណាយ ហើយរាល់ការចំណាយតែងតែមានការខាតបង់ឱកាសរវាងផ្នែកផ្សេងៗដែលត្រូវចំណាយ ។ ប្រសិនបើយើងចំណាយច្រើនលើផ្នែកសុខភាព តើយើងត្រូវតែចំណាយតិចលើផ្នែកអប់រំឬយ៉ាងណា? ប្រសិនបើយើងចំណាយច្រើនលើផ្នែកអប់រំនៅបឋមសិក្សា តើយើងត្រូវតែចំណាយតិចលើផ្នែកអប់រំនៅមធ្យមសិក្សាឬយ៉ាងណា? មានការពិភាក្សាអំពីបញ្ហានេះ ហើយខ្ញុំគិតថាអ្នកទាំងអស់គ្នាគួរតែរៀបចំកិច្ចពិភាក្សាដោយលើកសំណួរថា ហេតុអ្វីបានជាមិនគួរចំណាយលុយនៅក្នុងប្រទេសកម្ពុជាទាល់តែសោះ? តើនៅជុំវិញពិភពលោកសព្វថ្ងៃនេះមិនមានវិបត្តិដែលបន្ទាន់ជាងនេះដែលទាក់ទងនឹងការស្លាប់រស់ទេឬ? អ្នកទាំងអស់ពិតជាអាចជំទាស់ចំពោះបញ្ហានេះ ។ អ្នកទាំងអស់គ្នាអាចក្រឡេកមើលទៅរបៀបចំណាយថវិការបស់សង្គម ឬក៏របៀបដែលរដ្ឋាភិបាលទាំងឡាយសម្រេចចំណាយថវិកាលើការបំពាក់សព្វាវុធ លើហាងទំនិញលើការផ្សាយពាណិជ្ជកម្ម និងលើការកម្សាន្ត ។ មានការអះអាងដែលគួរឲ្យជឿមួយចំនួនដែលលើកឡើងអំពីផ្នែកដែលគួរតែចំណាយថវិកា ។ ដូច្នេះខ្ញុំគិតថា ក្នុងការផ្តោតអារម្មណ៍ទៅលើការយកថវិកា៥៧លានដុល្លារទៅចំណាយលើអ្វីផ្សេងដែលមិនមែនជាគំនិតស្តាបនានោះទេ ហើយការចំណាយ៥៧លានដុល្លារលើសាលាជំនុំជម្រះក្តីនេះក៏មិនមែនជាការដកយកលុយពីការចំណាយលើអ្វីដែលល្អចំពោះប្រទេសកម្ពុជានោះដែរ ។

ខ្ញុំគិតថានេះជាបញ្ហានិងជាការផ្តោតអារម្មណ៍របស់ប្រទេសកម្ពុជាជាយូរមកហើយ ហើយចំពោះការណ៍ដែលនិយាយថា "សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនេះមិនមានប្រយោជន៍" ឬថា "ប្រហែលជាមិនខុបត្ថម្ភថវិកា" ឬថា "សូមទោស យើងមិនអាចលៃលកថវិកាឲ្យបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានទេ" នឹងបង្កើតជាស្ថានការណ៍ខូចខាតយ៉ាងខ្លាំង ។ ខ្ញុំក៏បានគិតដែរថា មានការលើកឡើងថាប្រជាជនកម្ពុជាត្រូវបានបំភ្លេចចោលអស់រយៈពេលជាច្រើនឆ្នាំណាស់មកហើយ ហើយមានសាលាជំនុំជម្រះក្តីជាច្រើននៅកន្លែងផ្សេងៗនៃពិភពលោកដែលបង្កើតឡើងជួនកាលធ្វើឲ្យមានភាពប្រសើរឡើង ឬជួនកាលធ្វើឲ្យកាន់តែអាក្រក់ ហើយប្រជាជនកម្ពុជាគួរតែមានសាលាជំនុំជម្រះក្តីមួយ ។ ខ្ញុំគិតថា យើងបានចំណាយពេលយ៉ាងយូរទម្រាំតែសម្រេចបានយឺតៗនូវកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាដែលត្រូវបានអនុម័តដោយសំឡេងជាឯកច្ឆន្ទ ។ ខ្ញុំគិតថាអ្វីដែលកម្ពុជាបានធ្វើក្នុងការរៀបចំបង្កើតសាលាជំនុំជម្រះក្តីគឺផ្ទុយគ្នាស្រឡះពីសាលាជំនុំជម្រះក្តីអន្តរជាតិ ឬសាលាជំនុំជម្រះក្តីចម្រុះផ្សេងៗ ព្រោះសាលាជំនុំជម្រះក្តីទាំងអស់នោះត្រូវបានរៀបចំរួចជាស្រេចពីខាងក្រៅ ។ នេះហើយដែលធ្វើឲ្យការបង្កើតសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមមានភាពយឺតយ៉ាវ ហើយប្រហែលជាលំបាកទៀតផង ប៉ុន្តែខ្ញុំគិតថាសាលាជំនុំជម្រះក្តីមួយនេះប្រហែលជាគំរូដ៏រឹងមាំមួយ ។

**ឯកឧត្តម កែវ រ៉េមី៖** នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ខ្ញុំមានអាយុទើបតែ១៨ឆ្នាំទេនៅឆ្នាំ១៩៧៥ ។ ខ្ញុំនិងក្រុមគ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញឲ្យទៅរស់នៅខេត្តបាត់ដំបង ។ នៅតាមផ្លូវ ខ្ញុំឃើញទាហានខ្មែរក្រហមសម្លាប់ប្រជាពលរដ្ឋជាបណ្តើរៗ ជាពិសេសមន្ត្រីរាជការ តំណាងរាស្ត្រ ឬក៏មេដឹកនាំជាន់ខ្ពស់របស់ប្រទេស ។ បើអង្គការស្រាវជ្រាវឃើញ អង្គការសម្លាប់សូម្បីតែកុមារ ។ ការសម្លាប់មនុស្សនៅក្នុងរបបខ្មែរក្រហមមានពីរប្រភេទ ។ ទីមួយ ការបង្អត់អាហារ ចំណែកឯប្រភេទទីពីរគឺតាមរយៈការស្រាវជ្រាវ ។ ប្រសិនបើក្មេងៗជានិស្សិត ជាមន្ត្រីរាជការ ជាប៉ូលិស ជាទាហាន គេចាប់ផ្តើមយកទៅសម្លាប់បណ្តើរៗ ។ ការសម្លាប់ទាំងពីរប្រភេទនេះបាននាំទៅដល់ការស្លាប់បាត់បង់ជីវិតប្រជាជនអស់យ៉ាងច្រើន ។

បងប្អូនបង្កើតរបស់ខ្ញុំចំនួន៧នាក់និងឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមសម្លាប់ ។ សាច់ញាតិរបស់ខ្ញុំជាច្រើននាក់ទៀតក៏បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមដែរ ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានឃើញអ្នកខ្លះដែលធ្វើការនៅក្នុងរដ្ឋសភានិងតុលាការកម្ពុជាគឺជាអតីតខ្មែរក្រហម ដូច្នេះខ្មែរក្រហមនៅតែមានកាន់តំណែងផ្សេងៗនៅក្នុងរចនាសម្ព័ន្ធអំណាចរបស់ប្រទេសកម្ពុជា ។ ដូចដែលខ្ញុំធ្លាប់លើកឡើងកាលពីដំបូងរួចមកហើយច្បាប់កាត់ទោសខ្មែរក្រហមនេះគឺសម្រាប់តែមេដឹកនាំជាន់ខ្ពស់ប៉ុណ្ណោះ ។ ហើយសាលាជំនុំជម្រះក្តីមួយនេះខុសគ្នាពីសាលាជំនុំជម្រះក្តីណាហ្សីអ៊ីខ្វែរ ពីព្រោះសាលាជំនុំជម្រះក្តីនៅប្រទេស

អាល្លឺម៉ង់កាត់ក្តីទាំងមេដឹកនាំជាន់ខ្ពស់ ទាំងទាហាននិងប៉ូលិសដែលសម្លាប់ជីវិតមនុស្ស ។

ទាក់ទងទៅនឹងបញ្ហានៃការបំពេញការងាររបស់ចៅក្រមនិងព្រះរាជអាជ្ញាខ្មែរ យើងឃើញថាប្រព័ន្ធយុត្តិធម៌របស់ប្រទេសកម្ពុជាត្រូវគ្រប់គ្រងដោយគណបក្សនយោបាយ ។ ខ្ញុំសូមលើកឡើងនូវការយល់ឃើញជាទូទៅមួយ ។ ប្រព័ន្ធបោះឆ្នោតរបស់ប្រទេសយើងគឺជាប្រព័ន្ធបោះឆ្នោតជ្រើសរើសអ្នកតំណាងនៅក្នុងសភា ។ គណបក្សឈ្នះឆ្នោតជ្រើសរើសមនុស្សនៅក្នុងបក្សឲ្យអង្គុយនៅលើអាសនៈដែលប្រជាជនបានបោះឆ្នោតឲ្យ ។ ...ដូច្នេះសម្រាប់អ្នកទាំងឡាយណាដែលចង់បានតំណែងនេះត្រូវតែចូលរួមក្នុងគណបក្សនយោបាយ ។ ...តាមទស្សនៈរបស់ខ្ញុំ វាកាន់តែលំបាកថែមទៀតនៅក្នុងការស្វែងរកចៅក្រមនិងព្រះរាជអជ្ញាដែលឯករាជ្យ ។ ខ្ញុំបាននិយាយថា យើងគួរតែមានសាលាជំនុំជម្រះក្តីមួយសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ហើយតាមរយៈសាលាជំនុំជម្រះក្តីនេះប្រហែលជាយើងអាចរកឃើញយុត្តិធម៌ជូនជនរងគ្រោះជាងពីរលាននាក់ដែលបានបាត់បង់ជីវិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងរកឲ្យឃើញថាតើអ្នកណាដែលនៅពីក្រោយខ្នងរបបខ្មែរក្រហម? អ្នកណាដែលពាក់ព័ន្ធនឹងសង្គមកម្ពុជា? ហើយនឹងថាតើអ្នកណាដែលទុកឲ្យប្រជាជនកម្ពុជាស្លាប់? សំខាន់ជាងគេបំផុតនោះគឺ ខ្ញុំគិតថាចៅក្រមនិងព្រះរាជអាជ្ញាកម្ពុជាអាចរៀនសូត្រពីចៅក្រមបរទេសអំពីដំណើរការរបស់សវនាការ ហើយតាមរយៈនេះ ចៅក្រមកម្ពុជាពិតជាអាចធ្វើឲ្យមានការរីកចម្រើននៅក្នុងការកាត់សេចក្តីជាមិនខាន ។ ចំណុចចុងក្រោយទាក់ទងនឹងសាលាជំនុំជម្រះក្តីនេះគឺថា វាជាការជូនដំណឹងមួយទៅដល់ឧក្រិដ្ឋជននិងមេដឹកនាំប្រទេសផ្សេងៗទៀតនៅក្នុងពិភពលោក...ប្រសិនបើមិនដូច្នោះទេយើងនឹងមិនអាចរកយុត្តិធម៌ឃើញឡើយ ។ ...ចំណុចមួយទៀតនោះគឺថា ប្រសិនបើយើងមិនបង្កើតសាលាជំនុំជម្រះក្តីនេះទេ វប្បធម៌រួចទោសនឹងនៅតែមានជាបន្ត ។ អ្នកនយោបាយខ្លះបានស្នើសុំឲ្យយកលុយសម្រាប់ដំណើរការសាលាជុំនុំជម្រះក្តីនេះទៅអភិវឌ្ឍប្រទេសវិញ ។ ប៉ុន្តែចំពោះការយល់ឃើញរបស់ខ្ញុំគឺខ្ញុំស្នើសុំកុំឲ្យបង្វែរលុយសម្រាប់សាលាជម្រះក្តីនេះទៅប្រើប្រាស់សម្រាប់ជម្រើសផ្សេងទៀតដូចជាការអភិវឌ្ឍជាដើម ។ សូមកាត់ទោសមេដឹកនាំខ្មែរក្រហមទៅ ប្រសិនបើគ្មានតុលាការនេះទេ វប្បធម៌រួចទោសនឹងនៅតែបន្ត ។ ប្រសិនបើយើងមិនធ្វើដូច្នេះទេ ប្រជាជនមិនយល់អំពីយុត្តិធម៌សង្គមទេ ។ ដូច្នេះអ្វីដែលអ្នកនយោបាយបាននិយាយអំពីការមិនប្រើប្រាស់ថវិកាសម្រាប់សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម គឺដោយសារតែមិនចង់ឲ្យមានសាលាជម្រះក្តីនេះ ព្រោះតែអ្នកទាំងនោះជាប់ពាក់ព័ន្ធនឹងការសម្លាប់នេះ ។

**រ៉ាឈល ស្នាយដឺៈ** សូមអរគុណ ។ យើងទុករយៈពេលពីរបីនាទីដើម្បីទទួលសំណួរ ។ ប្រសិនបើលោកអ្នកមានសំណួរសូមអញ្ជើញ ។

**អ្នកចូលរួមៈ** តើយើងគ្រាន់តែកាត់ទោសមេដឹកនាំនយោបាយ ឬក៏កាត់ទោសទាំងអ្នកសម្លាប់មនុស្សដែរ?

**ស៊ីវ ហេង័រៈ** ផ្នែកមួយនៃចម្លើយនោះគឺថា អ្នកដឹកនាំនយោបាយហាក់បីដូចជារងការគំរាមកំហែង ។ នេះគឺមិនមែននិយាយអំពីអ្នកដែលសម្លាប់មនុស្សដោយផ្ទាល់ដៃនោះទេ ។ នៅក្នុងអារម្មណ៍របស់ខ្ញុំ អ្នកដែលសម្លាប់មនុស្សដោយផ្ទាល់ដៃមិននៅក្នុងចំណោមអ្នកដែលត្រូវកាត់ទោសទេ ។ ខ្ញុំគិតថានៅពេលដែលនិយាយអំពីអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតគឺប្រហែលជាសំដៅទៅរកអ្នកដែលមានអំណាចក្នុងការសម្រេចចិត្តភ្លាមៗនៅនឹងកន្លែង ។ អ្នកទាំងនោះមានឋានៈទាបជាងមេដឹកនាំខ្ពស់បំផុត ហើយក៏មិនមែនជាអ្នកដែលសម្លាប់មនុស្សដោយផ្ទាល់ដៃដែរ ។ ខ្ញុំគិតថាភ័ស្តុតាងជាទូទៅបានបង្ហាញថាអ្នកដែលសម្លាប់មនុស្សដោយផ្ទាល់ដៃមិនមែនជាអ្នកដែលមានសិទ្ធិសម្រេចចិត្តទេ ។

**ហេឡែន ហ្វារីសៈ** ខ្ញុំគិតថាយើងត្រូវតែបន្ថែមថា ការធ្វើជាមេដឹកនាំខ្ពស់បំផុតមិនមែនជាបទល្មើសទេ ។ បើទោះបីជាមេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុតក៏ដោយ អ្នកទាំងនេះនៅតែទទួលខុសត្រូវចំពោះបទល្មើសផ្សេងៗគ្នាដែលបានប្រព្រឹត្ត ។

**អ្នកចូលរួមៈ** លោក កូហ្វី អាណាន់ បានចេញមុខនៅក្នុងសប្តាហ៍នេះ ហើយបាននិយាយថាត្រូវការថវិកាចំនួន១៩លានដុល្លារសម្រាប់ឆ្នាំទី១ នៃសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។

*ឥឡូវនេះមានតែថវិកាចំនួន៣លានដុល្លារដែលជាវិភាគទានរបស់ប្រទេសអូស្ត្រាលីប៉ុណ្ណោះ តើមានសង្ឃឹមថានឹងអាចរៃអង្គាសថវិកាបានគ្រប់ដែរឬទេ?*

**ហេឡែន ហ្វារីស:** សំណួរនោះគឺថាតើចំនួនថវិកាដែលត្រូវការប៉ុន្មាន? ហើយតើធ្វើដូចម្តេចដើម្បីរកថវិកាទាំងនេះ? ប៉ុន្តែចំនួនថវិកានេះត្រូវបានកំណត់រួចហើយ ។ ក្រុមការងារបច្ចេកទេសរបស់អង្គការសហប្រជាជាតិមិនទាន់បានធ្វើដំណើរមកកម្ពុជាដើម្បីបញ្ចប់បញ្ហាថវិកានៅឡើយទេ ហើយក៏មានកិច្ចព្រមព្រៀងពីរបីទៀតមិនទាន់បានចុះហត្ថលេខាដែរ ។ ប៉ុន្តែតួលេខថ្មីៗនេះគឺ ៥៧លានដុល្លាត្រូវបានស្នើសុំដើម្បីចំណាយសម្រាប់ដំណើរការរយៈពេលប្រហែលជាបីឆ្នាំរបស់សាលាជំនុំជម្រះក្តីនេះ ។ ប្រទេសតែមួយគត់ដែលបានសន្យាថានឹងជួយដល់សាលាជំនុំជម្រះក្តីមួយនេះគឺប្រទេសអូស្ត្រាលី ។ ចំនួនទឹកប្រាក់ដែលសន្យាឲ្យនោះគឺ៣លានដុល្លារអូស្ត្រាលី ដែលប្រហែលជា២,២លានដុល្លារសហរដ្ឋអាមេរិក និងអាចឡើងច្រើនជាងនេះ ប៉ុន្តែថវិកានេះមិនគ្រប់គ្រាន់សម្រាប់ដំណើការនេះទេ ។ នៅមានផ្លូវដ៏វែងឆ្ងាយទៀតដែលនៅសល់ ហើយបើតាមការយល់ឃើញរបស់ខ្ញុំការប្រកាសនាពេលថ្មីៗនេះដោយព្រឹទ្ធសភារបស់សហរដ្ឋអាមេរិកគឺពិតជាមានភាពក្រៀមក្រំបន្តិចចំពោះការរួមវិភាគទានរបស់សហរដ្ឋអាមេរិកនៅក្នុងសាលាជម្រះក្តីនេះ ។ ខ្ញុំសង្ឃឹមថាការមិនចូលរួមរបស់សហរដ្ឋអាមេរិកនឹងមិនប៉ះពាល់ដល់ប្រទេសផ្សេងៗទៀតក្នុងការរួមវិភាគទានដែរនោះទេ ។ តួលេខឧបត្ថម្ភផ្សេងៗទៀតក៏ត្រូវបានផ្តល់ឲ្យដែរ បើទោះបីជានៅក្នុងរបាយការណ៍របស់លោកអគ្គលេខាធិការបានលើកឡើងតែមួយចំនួនក៏ដោយ ។ គួរកត់សម្គាល់ដែរថា បើទោះបីជារបាយការណ៍នេះទើបតែចេញផ្សាយនៅប៉ុន្មានថ្ងៃមុននេះក៏ដោយ ប៉ុន្តែកាលបរិច្ឆេទរបស់របាយការណ៍នេះគឺថ្ងៃទី១២ ខែតុលា ។ ដូច្នេះការសន្យាឧបត្ថម្ភដល់សាលាជំនុំជម្រះក្តីដែលមានសរសេរក្នុងរបាយការណ៍នោះមិនទាន់បានបញ្ចូលនូវការសន្យានាពេលថ្មីៗនេះទេ ។ ខ្ញុំគិតថា ប្រទេសទាំងឡាយកំពុងតែរង់ចាំមើលការបញ្ចប់កាតព្វកិច្ចតាមផ្លូវច្បាប់របស់ប្រទេសកម្ពុជាសិន ទើបបញ្ជាក់អំពីគោលជំហររបស់ខ្លួន ។ ប្រទេសកម្ពុជាបានបញ្ចប់កាតព្វកិច្ចតាមផ្លូវច្បាប់របស់ខ្លួនរួចហើយកាលពីថ្ងៃទី២៧ ខែតុលា ។ ឥឡូវនេះគួរតែមានបេសកកម្មមួយទៀតពីអង្គការសហប្រជាជាតិដើម្បីបញ្ចប់បញ្ហាថវិកាជាមួយប្រទេសកម្ពុជា និងដើម្បីអំពាវនាវរកថវិកាជាផ្លូវការ ។ យើងមានសង្ឃឹមថាសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមអាចឆ្ពោះទៅមុខទៀតបាន ។ ពីមុនយើងកំណត់ថា ថវិកាដែលត្រូវចំណាយគឺ៦០លានដុល្លារ ។ ចំនួននេះមិនច្រើនទេបើធៀបទៅនឹងថវិកាចំណាយទៅលើសាលាជំនុំជម្រះក្តីផ្សេងៗទៀត ។

ខ្ញុំគិតថាវាពិតជាត្រឹមត្រូវក្នុងការនិយាយថា ដើម្បីបង្កើតសាលាជំនុំជម្រះក្តីអន្តរជាតិឬសាលាជំនុំជម្រះក្តីចម្រុះពិតជាចំណាយថវិកាអស់ច្រើន ។ ជាពិសេសគឺចំណាយលើប្រាក់បៀវត្សរ៍របស់ចៅក្រមអន្តរជាតិ និងចំណាយផ្សេងៗទៀតដែលមិនមែនជាប្រាក់បៀវត្សរ៍ ។ ក្រៅពីនេះគឺជាការចំណាយទៅលើបៀវត្សរ៍របស់មន្ត្រីសំខាន់ៗដូចជាចៅក្រមស៊ើបអង្កេតនិងព្រះរាជអាជ្ញា ប្រសិនបើអ្នកទាំងពីរនេះស្ថិតនៅក្នុងរង្វង់ចំណាយនៃប្រាក់បៀវត្សរ៍របស់អង្គការសហប្រជាជាតិ ។ លោកអគ្គលេខាធិការបានមានប្រសាសន៍ថា គាត់គិតថាមិនសមទេដែលភ្នាក់ងារជាន់ខ្ពស់របស់សាលាជំនុំជម្រះក្តីទទួលការឧបត្ថម្ភពីប្រទេសផ្សេងៗដូចដែលប្រទេសខ្លះបានស្នើ ។ ប្រសិនបើមន្ត្រីសាលាជំនុំជម្រះក្តីទទួលបានប្រាក់បៀវត្សរ៍ពេញតាមបទដ្ឋានរបស់អង្គការសហប្រជាជាតិ សាលាជំនុំជម្រះក្តីនេះពិតជាត្រូវចំណាយអស់ថវិកាច្រើនណាស់ ។ ផ្នែកផ្សេងៗទៀតក៏ត្រូវការចំណាយថវិកាច្រើនដែរ ។ មេធាវីរបស់ជនជាប់ចោទក៏ត្រូវការថវិកា ហើយមិនទាន់ច្បាស់លាស់នៅឡើយទេអំពីចំនួនជនដែលត្រូវចោទប្រកាន់ ហើយតើជនជាប់ចោទប៉ុន្មាននាក់ដែលនឹងស្នើសុំជំនួយពីសាលាជំនុំជម្រះក្តីនេះ ។ អង្គការសហប្រជាជាតិព្រួយបារម្ភអំពីបញ្ហាសន្តិសុខ ហើយបានលើកឡើងថានឹងប្រុងប្រយ័ត្នចំពោះសុវត្ថិភាពរបស់បុគ្គលិកអន្តរជាតិបន្ទាប់ពីមានការផ្ទុះគ្រាប់បែកនៅទីក្រុងបាដាដកាលពីឆ្នាំកន្លងទៅ ។ មានសម្ភារខ្លះៗដូចជា រថយន្តកុំព្យូទ័រ ដែលត្រូវតែមានដំណាលគ្នានឹងការមកដល់របស់បុគ្គលិកអន្តរជាតិ ។ ការបកប្រែភាសានឹងត្រូវចំណាយអស់ថវិកាជាច្រើន ហើយសាលាជំនុំជម្រះក្តីនេះប្រើប្រាស់បីភាសាជាផ្លូវការ

មាន ភាសាបារាំង អង់គ្លេស និងខ្មែរ ។ ឯកសារទាំងឡាយត្រូវតែបកប្រែដែលនឹងត្រូវចំណាយអស់ថវិកាជាច្រើន ។

**អ្នកចូលរួមៈ** តើឧបសគ្គធ្ងន់ធ្ងរបំផុតដែលយើងមាននោះជាអ្វី? ប្រសិនបើដំណើរការរបស់សាលាជំនុំជម្រះក្តីមានកំហុសឆ្គង តើនឹងខុសឆ្គងយ៉ាងដូចម្តេច? តើយើងអាចមើលឃើញតាមរបៀបណា? ចុះចំណែកឯចំណុចដែលល្អបំផុតវិញ?

**ស៊ីវ ហេងៈ** ខ្ញុំគិតថាខ្ញុំគ្មានចម្លើយទៅនឹងសំណួរ «ប្រសិនបើករណីទាំងអស់នោះមានកំហុសឆ្គង តើនឹងខុសឆ្គងខ្លាំងយ៉ាងដូចម្តេច?» ។ ការយល់ឃើញជាទូទៅរបស់ខ្ញុំអំពីករណីដែលធ្ងន់ធ្ងរនោះគឺ អ្នកបំពេញការងារក្នុងការស៊ើបអង្កេត ការកោះហៅសាក្សី និងការងារដទៃៗទៀតទាក់ទងនឹងសាលាជំនុំជម្រះក្តីនេះ មើលឃើញថាខ្លួនឯងស្ថិតក្រោមការគំរាមកំហែង ។ បន្ទាប់មកទៀតឧបសគ្គផ្សេងៗនឹងកើតឡើងជាមិនខាន ហើយឧបសគ្គទាំងនេះនឹងធ្វើឲ្យដំណើរការសាលាជំនុំជម្រះក្តីនេះមិនមានភាពរលូន ។ ខ្ញុំមិនចង់គិតថាតើឧបសគ្គទាំងអស់នោះនឹងកើតឡើងយ៉ាងដូចម្តេចទេ ប៉ុន្តែខ្ញុំមានអារម្មណ៍ថាឧបសគ្គរបៀបនេះប្រាកដជាកើតឡើងមិនខាន ហើយទំនងជាកើតឡើងយ៉ាងធំទៀតផង ដែលអ្នកខ្លះប្រហែលជានិយាយថាចម្លែក ។ យើងមិនអាចមើលឃើញឧបសគ្គទាំងនោះច្បាស់ទេ វាប្រហែលជាចំណុចតូចៗដែលនឹងបន្តជារឿងមួយដ៏ធំបាន ។

**អ្នកចូលរួមៈ** តើត្រូវកាត់ទោសអ្នកដែលស្លាប់ហើយឬទេ?

**ហេឡែន ហ្ជាវីសៈ** ខ្ញុំគិតថានេះជាសំណួរដ៏គួរឲ្យចាប់អារម្មណ៍មួយ ។ ប្រហែលជាអ្នកទាំងអស់គ្នាអាចយកកូនសៀវភៅដែលមានចំណងជើងថា «ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម» ទៅអានបាន ។ សៀវភៅនេះចេញផ្សាយដោយលេខាធិការដ្ឋានក្រុមការងាររបស់រាជរដ្ឋាភិបាលសម្រាប់រៀបចំការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។ នៅពេលយើងធ្វើសេចក្តីព្រាងសៀវភៅនេះជាលើកទីមួយ យើងបានទៅជួបកម្មវិធីហ៊ុកហ៊ីនរបស់សមាគមអាស៊ាន ហើយអ្នកកាសែតបានសួរសំណួរមកយើង ។ យើងបានបញ្ចូលសំណួរនេះទៅក្នុងសៀវភៅណែនាំរបស់យើង ។ នៅពេលដែលមនុស្សលើកឡើងនូវសំណួរនេះ មនុស្សដំបូងដែលអ្នកសួរនឹកឃើញនោះគឺ ប៉ុល ពត ។ ហេតុអ្វីបានជាយើងមិនកាត់ទោស ប៉ុល ពត? នេះគឺដោយសារតែនៅក្នុងផ្លូវច្បាប់ យើងមិនអាចកាត់ទោសនរណាម្នាក់ដែលមិនមានជីវិតដើម្បីការពារខ្លួនឯងនៅក្នុងតុលាការនោះទេ ។ ហេតុដូច្នេះ បើទោះបីជាភស្តុតាងអាចត្រូវបានបញ្ជូនទៅតុលាការ ហើយតុលាការអាចលើកឡើងពីកំហុសរបស់អ្នកដែលបានបាត់បង់ជីវិតរួចទៅហើយមែនក្តី ក៏ប៉ុន្តែតុលាការមិនអាចនាំយកជននោះមកកាត់ទោសបានទេ ។

**អ្នកចូលរួមៈ** ក្នុងនាមជាពលរដ្ឋកម្ពុជាម្នាក់ ខ្ញុំពិតជាគាំទ្រការស្វែងរកយុត្តិធម៌និងការផ្សះផ្សាជាតិ ។ យើងទាំងអស់គ្នាដឹងហើយថាខ្មែរក្រហមដែលមានឈាមប្រឡាក់ពេញដៃកំពុងតែរស់នៅជាមួយយើង ។ តើសាលាជំនុំជម្រះក្តីនេះមានន័យអ្វីបើខ្មែរក្រហមទាំងនោះមួយចំនួននៅតែបន្តប្រើប្រាស់អំពើហិង្សាដដែល? តើអ្វីៗនឹងបញ្ចប់? ឬបន្ទាប់ពីសាលាជំនុំជម្រះក្តីនេះ តើយើងអាចធ្វើអ្វីផ្សេងៗទៀតដើម្បីឲ្យដឹងច្រើនជាងនេះ និងដើម្បីបន្តសាលាជំនុំជម្រះក្តីនេះដោយឈរលើមូលដ្ឋានផ្សះផ្សាជាតិ? ដែលលើកឡើងយ៉ាងនេះ ខ្ញុំគិតថាខ្ញុំកំពុងតែសំណូមពរឲ្យយើងទាំងអស់គ្នាសម្លឹងទៅខាងមុខ ។ សូមអរគុណ ។

**ឯកឧត្តម កែវ រ៉េមីៈ** ខ្ញុំគាំទ្រយោបល់របស់លោកទាំងស្រុង ។ ខ្ញុំគួរតែនិយាយថា នៅក្នុងប្រទេសកម្ពុជាយើងមានអតីតមេដឹកនាំខ្មែរក្រហម ហើយមួយចំនួនកាន់តំណែងនៅក្នុងរដ្ឋាភិបាលកម្ពុជាទៀតផង ។ នេះហើយជាមូលហេតុដែលអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាបង្កើតច្បាប់ដើម្បីកាត់ទោសខ្មែរក្រហមទាំងនេះ ។ រឿងនេះស្មុគស្មាញណាស់ ដោយសារខ្មែរក្រហមដែលមានតំណែងនៅក្នុងរដ្ឋាភិបាលចង់បន្តវប្បធម៌រួចទោសតទៅទៀត ដើម្បីការពារកុំឲ្យខ្លួនឯងត្រូវតុលាការកាត់ទោស ។ ហើយនេះជាមូលហេតុដែលកាត់ទោសតែមេដឹកនាំខ្ពស់បំផុតរបស់របបខ្មែរក្រហម ។

**អ្នកចូលរួមៈ** ខ្ញុំមានសំណួរពីរបី ។ យើងមានភាពដូចគ្នាខ្លះ ។ ខ្ញុំដឹងថាស្ថានភាពទាំងមូលចាប់ផ្តើមឡើងជាមួយនយោបាយ ហើយអ្នកមានអំណាចនៅក្នុងប្រទេសនេះនិងប្រទេសមហាអំណាចនៅក្នុងពិភពលោកកំពុងតែដោះស្រាយបញ្ហានេះជាមួយយើង ។ សំណួររបស់ខ្ញុំគឺថា តើសាលាជំនុំជម្រះក្តីនេះពាក់ព័ន្ធនឹងនយោបាយ

ច្រើនប៉ុនណា នៅពេលដែលមហាអំណាចដូចជាសហរដ្ឋអាមេរិក និងអង្គការសហប្រជាជាតិមិនបានធ្វើអ្វីទាល់តែសោះអស់រយៈពេលជាយូរមកហើយ ហើយមេដឹកនាំខ្មែរក្រហមក៏ចេះតែស្លាប់ជាបណ្តើរៗ? ឥឡូវនេះនិយាយពីរឿងយុត្តិធម៌ម្តង ។ តើយើងធ្វើយ៉ាងដូចម្តេចដើម្បីឲ្យសាលាជំនុំជម្រះក្តីនេះត្រូវតាមបទដ្ឋានអន្តរជាតិ? តើចៅក្រមនិងព្រះរាជអាជ្ញាត្រូវជ្រើសចេញពីក្រុមណា? ខ្ញុំគិតថាមានមនុស្សជាច្រើនដែលពាក់ព័ន្ធនឹងអំពើយង់ឃ្នងក្នុងរបបខ្មែរក្រហមកំពុងតែរស់នៅដោយសេរីភាព ។ ប្រជាជនកម្ពុជាជាច្រើនបានបាត់បង់សាច់ញាតិរបស់ខ្លួន ។ តើត្រូវវិនិច្ឆ័យទោសជនសង្ស័យទាំងនោះយ៉ាងដូចម្តេច? បើប្រៀបធៀបទៅនឹងចៅក្រមអន្តរជាតិ តើត្រូវផ្តល់ប្រាក់បៀវត្សរ៍ឲ្យចៅក្រមកម្ពុជាយ៉ាងដូចម្តេច? ១៥ដុល្លារក្នុងមួយខែឬយ៉ាងណា? តើចៅក្រមកម្ពុជាជិះម៉ូតូនៅពេលដែលចៅក្រមអន្តរជាតិទទួលបាននូវការការពារ២៤ម៉ោងឬយ៉ាងណា? យើងហាក់បីដូចជាយកចិត្តទុកដាក់ខ្លាំងចំពោះសន្តិសុខនិងសុវត្ថិភាពរបស់ចៅក្រមអន្តរជាតិ ។ តើចៅក្រមខ្មែរនិងចៅក្រមអន្តរជាតិមានអ្វីខុសគ្នា? តើសាលក្រមនឹងមានភាពយុត្តិធម៌យ៉ាងដូចម្តេច បើចៅក្រមកម្ពុជាទទួលបាន១៥ដុល្លារ ហើយចៅក្រមអន្តរជាតិទទួលបាន១ម៉ឺន៥ពាន់ដុល្លារ?

**ឯកឧត្តម កែវ រ៉េមី៖** យោងទៅលើច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមដែលរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តរួច ខ្ញុំឃើញថា បៀវត្សរ៍សម្រាប់ចៅក្រមកម្ពុជានិងអន្តរជាតិមិនខុសគ្នាទេ ។ សំណួរដែលថា តើត្រូវជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញាយ៉ាងដូចម្តេចនោះ យើងទាំងអស់គ្នាមានការព្រួយបារម្ភថា ចៅក្រមឬព្រះរាជអាជ្ញាដែលមានសាច់ញាតិក្រុមគ្រួសារបាត់បង់ជីវិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមអាចធ្វើឲ្យការជម្រះសេចក្តីនោះមិនយុត្តិធម៌ ប៉ុន្តែប្រសិនបើយើងអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវនោះយើងនឹងមិនមានបញ្ហានេះទេ ។

**ហេឡែន ហ្ចាវីស៖** ច្បាប់ចែងថា ចៅក្រមត្រូវមានលក្ខខណ្ឌស្មើភាពគ្នា ប៉ុន្តែមិនបានចែងថាទទួលប្រាក់បៀវត្សរ៍ស្មើគ្នាដែរនោះទេ ។ ដូច្នេះមិនទាន់មានភាពច្បាស់លាស់ជុំវិញបញ្ហាថវិកានៅឡើយទេ ។ នេះជាសំណួរដែលប្រទេសផ្តល់ជំនួយត្រូវយកទៅពិចារណា ។ តើត្រូវឲ្យអ្នកដែលអង្គុយលើកៅអីនៅក្នុងតុលាការតែមួយមានបៀវត្សរ៍ខុសគ្នាឬយ៉ាងណា? ...ខ្ញុំមិនដឹងអំពីករណីប្រទេសទីម័រខាងកើតទេ ប៉ុន្តែនៅក្នុងប្រទេសសេរ៉ាឡេអូន រ៉្វាន់ដា និងយូហ្គោស្លាវី ចៅក្រមទាំងអស់ទទួលបានប្រាក់បៀវត្សរ៍ដូចៗគ្នា ។ បញ្ហានេះនៅតែជាបញ្ហាដែលត្រូវលើកយកមកពិភាក្សាគ្នា ។ កម្ពុជាបានសន្យាថានឹងទទួលខុសត្រូវចំពោះប្រាក់បៀវត្សរ៍របស់បុគ្គលិកកម្ពុជា ។ នោះជាកាតព្វកិច្ចតាមផ្លូវច្បាប់ ហើយអ្វីៗលើសពីនេះគឺស្រេចទៅលើអ្នកផ្តល់ជំនួយជាអ្នកធ្វើវិភាគទាន ។ ប្រសិនបើមានអ្នកតំណាងប្រទេសផ្តល់ជំនួយចូលរួមនោះ អ្នកទាំងនោះប្រាកដជាបានគិតដល់បញ្ហាដែលលើកឡើងអំពីភាពយុត្តិធម៌នៃលក្ខខណ្ឌសេវានិងប្រាក់បៀវត្សរ៍ជាមិនខាន ពីព្រោះនេះមិនមែនជាសំណួរដែលមានសារសំខាន់សម្រាប់តែចៅក្រមប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់អ្នកទាំងអស់ដែលធ្វើការងារឲ្យសាលាជំនុំជម្រះក្តីនេះ ។

ចំពោះសំណួរថា តើការជំនុំជម្រះក្តីសេចក្តីអាចមានភាពយុត្តិធម៌ដែរឬទេបើចៅក្រមនិងព្រះរាជអាជ្ញាក៏ជាជនរងគ្រោះនៃរបបខ្មែរក្រហមដែរនោះ ខ្ញុំយល់ថា ប្រជាជនកម្ពុជាទាំងអស់សុទ្ធតែបានទទួលរងនូវការឈឺចាប់ដោយសារតែរបបខ្មែរក្រហម ។ អ្នកខ្លះត្រូវធ្វើទារុណកម្ម សមាជិកក្រុមគ្រួសារខ្លះត្រូវសម្លាប់ អ្នកខ្លះបានបាត់បង់នូវជីវភាពជាកុមារនិងមិនបានទទួលការសិក្សា ។ ប្រជាជនទាំងអស់នៅក្នុងប្រទេសនេះជាជនរងគ្រោះដោយសារភាពខ្វះខាតជំនាញនិងភាពក្រីក្រ ហើយខ្ញុំគិតថា ទាំងអស់គ្នាទទួលការប៉ះពាល់ដោយសារតែរបបនេះ ។ ដូច្នេះប្រសិនបើនិយាយថាចៅក្រមឬព្រះរាជអាជ្ញាជាជនជាតិកម្ពុជាមិនអាចចូលរួមក្នុងសាលាជំនុំជម្រះក្តីនេះ នោះមានន័យថា ជនកម្ពុជាដែលបានចូលរួមក្នុងតុលាការគឺមានតែជនជាប់ចោទប៉ុណ្ណោះ ។ ហើយខ្ញុំគិតថាប្រជាពលរដ្ឋកម្ពុជាគួរតែចូលរួមនៅក្នុងគ្រប់ផ្នែកទាំងអស់របស់សាលាជំនុំជម្រះក្តីនេះ ។

**អ្នកចូលរួម៖** (សួរសំណួរដែលទាក់ទងនឹងការបដិសេធរបស់សហរដ្ឋអាមេរិកក្នុងការផ្តល់ជំនួយចំពោះតុលាការខ្មែរក្រហម)

**ស៊ីវ ហេដ័រ:** ខ្ញុំគិតថាគ្មាននរណាម្នាក់ក្នុងចំណោមនេះអាចឆ្លើយទៅនឹងសំណួររបស់លោកបានល្អទេ ។ ខ្ញុំគិតថា អ្វីដែលជាឧបសគ្គដល់ការប្រមូលមូលនិធិនេះគឺកើតឡើងមកអំពីការព្រួយបារម្ភថាសាលាជំនុំជម្រះក្តីដែលនឹងកើតឡើងក្នុងពេលឆាប់ៗនេះខ្វះភាពឯករាជ្យ... ហើយវាមានការលំបាកណាស់ក្នុងការសុំជំនួយពីប្រទេសផ្តល់ជំនួយ នៅពេលដែលយើងមិនអាចធានាបទដ្ឋានអន្តរជាតិនៃសាលាជំនុំជម្រះក្តីនេះ ។ ស្ទើរតែគ្រប់គ្នាមានអារម្មណ៍ថាបើទោះបីជាមានបញ្ហាបែបនេះក៏ដោយ សាលាជំនុំជម្រះក្តីនេះត្រូវតែបង្កើតឡើង ហើយប្រសិនបើចង់ឲ្យសាលាជំនុំជម្រះក្តីនេះកើតឡើង ត្រូវតែមានថវិកាគ្រប់គ្រាន់ ។

ចំពោះសំណួរទីពីរខ្ញុំគិតមានចម្លើយដ៏ងាយស្រួលមួយ ។ គោលជំហររបស់សភានិងរដ្ឋាភិបាលអាមេរិកក្នុងការមិនផ្តល់ជំនួយគឺមិនផ្លាស់ប្តូរទេ ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ហើយក៏គ្មានការផ្លាស់ប្តូរដែរ ។ យើងបានដឹងថាសហរដ្ឋអាមេរិកនឹងធ្វើដូច្នេះ ។ គោលជំហរនេះអាចប្តូរប្រសិនបើលោក ប៊ូស ចាញ់ឆ្នោត ហើយលោក ឃែរី ឈ្នះឆ្នោត ។ លោក ឃែរី ប្រាកដជារកមធ្យោបាយដើម្បីលូកដៃចូលក្នុងបញ្ហានេះជាមិនខាន ដោយសារតែគាត់ធ្លាប់បានចូលរួមធ្វើឲ្យកើតឡើងនូវកិច្ចព្រមព្រៀងទាំងនេះ ។ យើងដឹងច្បាស់ណាស់ថាឥឡូវនេះគឺស្រេចទៅលើប្រទេសផ្សេងៗក្នុងការជំរុញដំណើរការសាលាជំនុំជម្រះក្តីនេះឲ្យទៅមុខ ដោយសារតែសហរដ្ឋអាមេរិកបានដកខ្លួនចេញទៅហើយ ។ អ្នកដែលជួយជ្រោមជ្រែងខ្លាំងបំផុតនោះគឺប្រទេសជប៉ុននិងបារាំង ហើយពិតណាស់ដែលប្រទេសទាំងពីរនេះនឹងជួយជ្រោមជ្រែងផ្នែកថវិកា ។ ប្រទេសទាំងពីរនេះគួរតែឧបត្ថម្ភថវិកាឲ្យបានច្រើន ហើយប្រទេសផ្សេងៗទៀតក៏ត្រូវតែចូលរួមឧបត្ថម្ភដែរ ។

**អ្នកចូលរួម:** ខ្ញុំគិតថាទាំងអស់គ្នាព្រមព្រៀងគ្នាថា សាលាជំនុំជម្រះក្តីនេះគឺជាគំនិតដ៏ល្អមួយ... ។ ចុះចំណែក ឯមេដឹកនាំខ្មែរក្រហមដែលនៅក្រៅឃុំសព្វថ្ងៃនេះ តើមានការព្រួយបារម្ភថាអ្នកទាំងនោះអាចគេចខ្លួនចេញពីប្រទេសកម្ពុជាដែរឬទេ?

**ស៊ីវ ហេដ័រ:** ខ្ញុំគិតថានៅពេលដែលតុលាការនេះចាប់ផ្តើមដំណើរការ ជនសង្ស័យជាច្រើននឹងត្រូវឃាត់ខ្លួន ។ ខ្ញុំមិនគិតថាត្រូវចំណាយពេលជាច្រើនសប្តាហ៍ឬក៏ច្រើនឆ្នាំដើម្បីចាប់ខ្លួនជនទាំងនេះទេ ហើយសាលាជំនុំជម្រះក្តីនេះអាចដំណើរការកាត់ទោសជនជាប់ចោទនិងអ្នកដែលជាប់ឃុំឃាំងមិនហួសពីរយៈពេលមួយឆ្នាំកន្លះឡើយ... ។ យើងដឹងច្បាស់ថាអ្វីដែលអ្នកទាំងនោះអាចធ្វើបានគឺគេចខ្លួនទៅព្រំដែនថៃឬក៏ជិះយន្តហោះទៅប្រទេសចិន ។ ខ្ញុំគិតថាទាំងរដ្ឋាភិបាលចិននិងថៃមិនចង់ជាប់ពាក់ព័ន្ធនៅក្នុងរឿងនេះទេ ។ ពិតជាគ្មានកន្លែងដែលអាចគេចខ្លួនដោយស្រួលនោះទេ ដូច្នេះហើយ អ្នកទាំងនោះនឹងនៅទីនេះនិងងាយស្រួលក្នុងការចាប់ខ្លួនជាមិនខាន ។

**កែវ រ៉េមី:** ខ្ញុំចង់បន្ថែមលើចំណុចនេះ ។ យើងក៏មានការព្រួយបារម្ភចំពោះអ្វីដែលលោកបានលើកឡើងដែរ ។ ការគេចខ្លួនទៅភាគខាងលិច (ប្រទេសថៃ) គឺមិនមែនងាយស្រួលនោះទេ ប៉ុន្តែបើគេចខ្លួនទៅភាគខាងកើត (ប្រទេសវៀតណាម) គឺអាចងាយស្រួល ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកទាំងនោះនឹងមិនអាចគេចខ្លួនរួចឡើយ ។

**ម៉ៃឃើល វេវត្តនុ:** សូមថ្លែងអំណរគុណចំពោះការអញ្ជើញចូលរួមរបស់អស់លោកទាំងអស់ ។ សូមថ្លែងអំណរគុណជាពិសេសចំពោះវាគ្មិនកិត្តិយសរបស់យើងគឺ ឯកឧត្តម កែវ រ៉េមី, លោក ស៊ីវ ហេដ័រ, និងលោកស្រី ហេឡែន ហ្វារីស ។ សូមថ្លែងអំណរគុណចំពោះក្លឹបអ្នកសារព័ត៌មានបរទេស ។

**(ប្រែសម្រួលក្រៅផ្លូវការដោយ ជី ធេរិទ្ធ)**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@online.com.kh
Home page: www.dccam.org

# ជីវិតក្នុងភាពនឹងថ្កល់

## មជ្ឈមណ្ឌលឯកសារកម្ពុជា

### បាន សារឿន, អតីតកម្មកររោងចក្រ

*(បទសម្ភាសន៍ជាមួយសាមីខ្លួនអាយុ៦៧ឆ្នាំ នៅស្រុកសន្ទុក ខេត្តកំពង់ធំ)*


បាន សារឿន ឆ្នាំ២០០៤

ខ្ញុំនិងប្តីខ្ញុំធ្វើការនៅរោងចក្រផលិតសរសៃកប្បាស ។ នៅពេលដែលការប្បាំងគ្នាចាប់ផ្តើមនៅខេត្តកំពង់ចាមក្នុងឆ្នាំ១៩៧២ មានប្រជាជនជាច្រើននាក់បានស្លាប់ ដូច្នេះយើងក៏បានរត់ទៅរស់នៅទីក្រុងភ្នំពេញ ។ នៅទីនោះប្តីខ្ញុំធ្វើការជាអ្នកប្រមូលស្ថិតិខាងវិស័យកសិកម្មឲ្យក្រសួងផែនការនិងស្ថិតិនៃរបបសាធារណរដ្ឋខ្មែរ ចំណែកឯខ្ញុំដំបូងធ្វើចម្ការលុះក្រោយមកខ្ញុំលក់នំកង ។

ក្រោយមក ការប្រយុទ្ធគ្នាបានចូលមកដល់ទីក្រុងភ្នំពេញ ។ ដោយសារតែមានការទម្លាក់គ្រាប់បែកច្រើនលើកច្រើនសា យើងបានរត់ទៅលាក់ខ្លួននៅក្នុងលេណដ្ឋាន ។ ខ្ញុំត្រូវអម្បែងគ្រាប់ត្រង់ដើមដៃ ខ្ញុំក៏ត្រឡប់មកភូមិកំណើតវិញ ហើយប្តីខ្ញុំមកតាមក្រោយ ។

បន្ទាប់មកយើងត្រូវជម្លៀសទៅខេត្តក្រចេះ ។ ខ្មែរក្រហមបានហៅយើងថាប្រជាជនមូលដ្ឋាន ។ ប្រសិនបើយើងជាប្រជាជនថ្មី ខ្មែរក្រហមអាចនឹងសម្លាប់យើង ។ នៅខេត្តក្រចេះ មានបុរសម្នាក់ចំណាំខ្ញុំហើយនិងប្តីខ្ញុំថាជាកម្មកររោងចក្រ ។ គាត់បានចោទប្រកាន់ប្តីខ្ញុំថាជាអ្នកមានបុណ្យស័ក្តិខ្ពស់នៅក្នុងជួររដ្ឋាភិបាល តែមានអ្នកដែលធ្លាប់ធ្វើការជាមួយប្តីខ្ញុំនៅនៅរោងចក្រនោះជួយការពារគាត់ដោយនិយាយថាប្តីខ្ញុំធ្វើការខាងកសិកម្ម មិនមែនជាអ្នកមានឋានៈធំដុំនោះទេ ។

អង្គការចោទប្តីខ្ញុំថាជាអ្នកមានឋានៈខ្ពស់ដោយសារគាត់មានក្បាលពោះធំដែលមើលទៅដូចជាអ្នកមានបុណ្យស័ក្តិធំអីចឹង ។ ខ្មែរក្រហមមិនបានសម្លាប់ប្តីរបស់ខ្ញុំនៅពេលនោះទេ ទុកចាំសម្លាប់ពេលក្រោយ ។

ថ្ងៃមួយប្តីខ្ញុំបាននិយាយថា “មានប្រុសៗពីរនាក់សុំឲ្យបងទៅធ្វើការជាមួយឈ្មោះ ពឿ វ៉ាត់” ។ គាត់ដឹងច្បាស់ថាគាត់នឹងត្រូវខ្មែរក្រហមសម្លាប់ ។ គាត់ក៏ប្រាប់ខ្ញុំថាគាត់ចង់ហូបសាច់មាន់អាំងជាមួយទឹកត្រី ពីព្រោះថ្ងៃស្អែកគាត់ពិតជាស្លាប់ ។ ខ្ញុំបានអាំងមាន់មួយឲ្យគាត់ហូប ។ បន្ទាប់ពីហូបរួច គាត់បានទៅចូលរួមប្រជុំ ។ ខ្ញុំឮមេៗប្រជុំថាចង់សម្លាប់ប្តីរបស់ខ្ញុំ ។ ខ្ញុំក៏វារតាមជួរគ្រាប់ចូលទៅក្នុងផ្ទះដ៏តូចរបស់ខ្ញុំ ។ ពេលមកដល់ផ្ទះ ខ្ញុំសម្លៀងកាំបិតឲ្យមុតស្រួច ។


កូនប្រុស និងក្មួយស្រីរបស់ បាន សារឿនៈ ឯក សិទ្ធី, ស្រីណាក់ ថតនៅក្រចេះ ប្រហែលក្នុងអំឡុងឆ្នាំ១៩៧៨

ប្តីខ្ញុំបានឲ្យថ្នាំបំពុលមកខ្ញុំ ។ គាត់ប្រាប់ខ្ញុំថាបើសិនជា ពឿ វ៉ាត់ ឈ្នះ គាត់នឹងលេបថ្នាំបំពុលនោះសម្លាប់ខ្លួន តែបើគាត់ឈ្នះ គាត់នឹងសម្លាប់ វ៉ាត ហើយមកនាំខ្ញុំទៅរស់នៅប្រទេសវៀតណាម ។ នៅពេលព្រឹក វ៉ាត់ ស្នើប្តីខ្ញុំទៅជាមួយគាត់ ។ ប្តីខ្ញុំ និយាយថា គាត់មិនអាចទៅបានទេ ព្រោះគាត់ឈឺក្បាល ។ ថ្ងៃស្អែកឡើង វ៉ាត់ មកសួរគាត់ទៀត ប្តីខ្ញុំនៅតែឆ្លើយដដែល ។ ក្រោយមក វ៉ាត់ ដឹងថា ប្តីប្រពន្ធខ្ញុំមានកូន១៥នាក់នៅក្នុងបន្ទុក គាត់មានការអាណិតអាសូរដល់យើង ហើយក៏បានរាយការណ៍ប្រាប់ថ្នាក់លើថា គាត់បានសម្លាប់ប្តីខ្ញុំរួចហើយ ប៉ុន្តែតាមពិតគាត់អត់សម្លាប់ទេ ។

មួយខែក្រោយមក មេក្រុមនិងអ្នកដែលមានតំណែងដទៃទៀតនៅក្នុងភូមិត្រូវអង្គការសម្លាប់ ហើយយើងត្រូវអង្គការយកទៅដាក់គុកកោះសុក្រំ ។ នៅទីនោះមានប្រជាជនជិត៥០នាក់ ។ ឈ្លបដែលប្រដាប់ដោយកាំភ្លើងនៅយាមចាំឃ្លាំមើលយើងនៅពេលដែលយើងកំពុងតែដាំដុះនិងប្រមូលផលអំពៅ ។ យើងបានគាបយកទឹកអំពៅទៅធ្វើស្ករ ប៉ុន្តែយើងមិនអាចហូបបានទេ ពីព្រោះទុកសម្រាប់អង្គការ ។

យើងនៅទីនោះប្រមាណពីរឆ្នាំ ។ ពេលមួយ ខ្ញុំយល់សប្តិឃើញអគារស៊ីម៉ង់ត៍មួយដែលនៅក្បែរនោះរលំ ។ ពេលដែលជញ្ជាំងធ្លាក់មកលើខ្ញុំ ស្រាប់តែវាឈប់ទ្រឹងទៅវិញ ។ លុះក្រោយមកប្រជាជនមកពីភូមិភាគនិរតីបានមកដោះលែងយើងចេញពីមន្ទីរឃុំឃាំង ។

បន្ទាប់ពីនោះ ខ្ញុំបានយល់សប្តិមួយផ្សេងទៀត ។ ម្តងនេះខ្ញុំយល់សប្តិឃើញទឹកជំនន់ ហើយឃើញឡានជាច្រើនបើកគេចចេញពីទឹកជំនន់នោះ ។ ថ្ងៃបន្ទាប់មកទៀតកងទ័ពវៀតណាមក៏មកដល់ ខ្ញុំនិងប្តីខ្ញុំបានរត់ទៅខេត្តស្ទឹងត្រែង ។ នៅទីនោះមានការប្រយុទ្ធគ្នានៅតាមព្រំដែនទន្លេ ធ្វើឲ្យខ្មែរក្រហមបរាជ័យ ។

នៅតាមផ្លូវមកផ្ទះ ប្តីខ្ញុំត្រូវកងទ័ពវៀតណាមចាប់ចង ។ គាត់ភ័យខ្លាំងណាស់រហូតដល់ស្វាយបប្ញូរមាត់ ។ បុរសម្នាក់ចំណាំប្តីខ្ញុំបានក៏សួរកងទ័ពវៀតណាមថា «ហេតុអ្វីបានជាចាប់ចងគាត់ដូច្នោះ ? » គាត់ជាកូនរបស់តាឆោម ។ បុរសនោះប្រាប់កងទ័ពវៀតណាមថាប្តីខ្ញុំធ្វើស្រែចម្ការទេ ទើបកងទ័ពវៀតណាមដោះលែងប្តីខ្ញុំ ។

ពេលដែលយើងត្រឡប់មកដល់ភូមិវិញ ឪពុកក្មេកខ្ញុំកំពុងតែកាប់ឆ្ការព្រៃ ហើយបានឲ្យដីមួយកន្លែងដល់យើង ។ ខ្ញុំបានក្លាយជាគ្រូបង្រៀនម្នាក់ ។

ខ្ញុំបានរក្សាទុករូបថតទាំងអស់នេះនៅក្នុងរបបខ្មែរក្រហម ដោយដាក់នៅក្នុងកន្ទេលកខ្វក់មួយ ហើយកប់វានៅក្នុងដីដែលមានជម្រៅប្រហែលដប់សង់ទី-ម៉ែត្រ ។ ខ្ញុំខ្លាចតែខ្មែរក្រហមប្អូនណាម្នាក់រកឃើញទេ ព្រោះអង្គការចង់សម្លាប់



បាន សារឿន និងកូនទាំងបីៈ ឯក ចាន់ឌី អាយុ៨ឆ្នាំ, ឯក ចាន់ដា អាយុ៧ឆ្នាំ និង ឯក ភ័ណនី អាយុ៦ឆ្នាំ ថតប្រហែលក្នុងអំឡុងឆ្នាំ១៩៧៥

ប្តីខ្ញុំ ។

ក្នុងរូបថតនេះគឺកូនរបស់ខ្ញុំបីនាក់ គឺ ចាន់ឌី, ចាន់ដា, និង ភ័ណនី ។ ខ្ញុំមិនដឹងថា ម្នាក់ទៀតជាខ្ញុំឬក៏មិនមែនទេ ព្រោះខ្ញុំមិនចំណាំសារុងនោះ ប៉ុន្តែចំណាំកន្លែងថត គឺនៅក្បែរទន្លេថ្កុកជ្រៅ ។ ប្តីខ្ញុំថតរូបនេះនៅឆ្នាំ១៩៧៥ ពេលដែលយើងកំពុងរត់ចេញពីភ្នំពេញ ។ កូនប្រុសខ្ញុំ ឯក សិទ្ធី មានអាយុ១៦ឆ្នាំ នៅពេលដែលខ្មែរក្រហមបាញ់សម្លាប់វា ។ ខ្ញុំមិនបានដឹងថាហេតុអ្វីបានជាខ្មែរក្រហមសម្លាប់វាទេ ។

ប្អូនស្រីរបស់ខ្ញុំឈ្មោះ សារ៉ន ធ្លាប់រស់នៅជាមួយឪពុកម្តាយខ្ញុំ ។ ក្រោយមកនាងក៏ទៅរស់នៅទីក្រុងភ្នំពេញ ។ ដោយសារទាហានលន់ណុលចង់រៀបការជាមួយនាង នាងក៏រត់ចូលក្នុងព្រៃបាត់ទៅ ។ ក្រោយពេលដែលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ខ្ញុំមិនដែលបានឃើញនាងឬក៏ប្តីនាងម្តងទៀតសោះ ។ ខ្ញុំឮថានាងនិងប្តីនាងស្លាប់អស់ហើយ ។ មានអ្នកប្រាប់ខ្ញុំថាបងប្អូនស្រីរបស់ខ្ញុំត្រូវខ្មែរក្រហមទាញទម្លាក់ពីលើឡាន ហើយវាយនាងបាក់ធ្មេញអស់ ។ មកទល់ឥឡូវនេះ ខ្ញុំសន្មតថានាងស្លាប់ហើយ ។ ខ្ញុំតែងតែរៀបចំសែនព្រេនចំណីឲ្យព្រលឹងរបស់នាង ។

ស្រីខ្ញុំឈ្មោះ សារ៉ាត ត្រូវទាហានលន់ណុលចាប់ដាក់គុកនៅព្រៃសអស់រយៈពេលពីរបីឆ្នាំប្រហែលឆ្នាំ១៩៧២ដោយសារនាងបានប្រឆាំងនឹងការបណ្តេញសម្តេច សីហនុ ។ ខ្ញុំបានទៅសួរសុខទុក្ខនាងនិងយកម្ហូបអាហារឲ្យនាងនៅទីនោះ ។ នាងបានប្រាប់ខ្ញុំថាទាហានលន់ណុលបានចោទប្រកាន់នាងថាជាខ្មែរក្រហម ដោយវាយធ្វើបាបនាង ចាក់ទឹកត្រីចូលមាត់របស់នាង ហើយវាយបំបាក់ឆ្អឹងជំនីរមួយចំហៀងខ្លួនរបស់នាង ។ បន្ទាប់ពីនាងត្រូវបានដោះលែង នាងបានមកលេងខ្ញុំនៅខេត្តក្រចេះ ។ នាងបានប្រាប់ខ្ញុំថានាងបានរៀបការរួចហើយ ។ ខ្ញុំមិនបានទទួលដំណឹងពីនាងតាំងតែពីពេលនោះមក ។ មានអ្នកផ្សេងប្រាប់ខ្ញុំថានាងបានទៅតំបន់ភ្នំហើយស្លាប់នៅទីនោះ ដោយសារឈឺឆ្អឹងជំនីរដែលបាក់និងដោយសារជំងឺ ។

សព្វថ្ងៃ ខ្ញុំតែងតែមើលរូបថតទាំងនេះនៅពេលដែលខ្ញុំនឹកបងប្អូនប្រុសស្រីរបស់ខ្ញុំ ។ ខ្ញុំបួងសួងសូមឲ្យវិញ្ញាណក្ខន្ធរបស់អ្នកទាំងអស់គ្នាបានទៅកាន់សុគតិភព ។

# ស្រ៊ុន សុង, អតីតអ្នកថតរូប

*(បទម្ភាសន៍ជាមួយម្តាយរបស់ ស្រ៊ុន សុង ឈ្មោះ ទ្រី យន អាយុ៦៩ឆ្នាំ និងបងប្រុសឈ្មោះ ស្រ៊ុន ស្រៀន អាយុ ៤៩ឆ្នាំ នៅស្រុកកោះធំ ខេត្តកណ្តាល)*



ទ្រី យន

**ទ្រី យនៈ** នៅឆ្នាំ១៩៧២ ពេលដែលយើងកំពុងតែហូបបាយថ្ងៃត្រង់ស្រាប់តែប្រធានភូមិនិងអ្នកភូមិផ្សេងទៀតមកផ្ទះ យើងហើយប្រាប់កូនប្រុសខ្ញុំឲ្យចូលធ្វើបដិវត្តន៍ ។ ខ្ញុំតបទៅវិញថាសុំឲ្យវាបាយទឹករួចរាស់អស់សិនសឹមនិយាយ ។ ប្រធានភូមិថា អង្គការនឹងផ្តល់អាហារឲ្យវាច្រើនជាងនេះក្រោយពេលវាចូលរួមក្នុងបដិវត្តន៍ ។

ខ្ញុំសួរមេភូមិថាចង់យកកូនប្រុសខ្ញុំទៅណា គាត់ឆ្លើយថា "កុំសួរខ្ញុំអីចឹង" ។ ខ្ញុំយំ មិនដឹងថាគាត់យកកូនប្រុសខ្ញុំទៅណាទេ ឬមួយក៏គាត់យកវាទៅសម្លាប់ ។



ស្រ៊ុន សុង
ថតប្រហែលក្នុងអំឡុងឆ្នាំ១៩៧៥

ពីរឆ្នាំក្រោយមក សុង បានធ្វើជាយុទ្ធជននៅឃុំព្រែកស្តី ។ មានអ្នកភូមិបានជួបកូនខ្ញុំហើយប្រាប់ខ្ញុំថា "កូនយាយឯងស្គមខ្លាំងណាស់" ។ ខ្ញុំនិងប្តីខ្ញុំក៏នាំគ្នាទៅលេងកូនហើយបានឃើញវាឈឺជាទម្ងន់ ។ យើងស្នើសុំវាឲ្យមកនៅជាមួយយើង ប៉ុន្តែខ្មែរក្រហមមិនយល់ព្រម ។ ក្រោយមកប្តីខ្ញុំក៏លួចយកកូនមកផ្ទះ ។ យើងគ្មានលុយសម្រាប់ទិញថ្នាំពេទ្យឬចំណីអាហារអីទេ ប៉ុន្តែខ្ញុំបានយកស្ករសឲ្យវា ។ ក្រោយពីវាហូបហើយវាបានគ្រាន់បើជាងមុន ។ ខ្ញុំមានលទ្ធភាពដូរបានថ្នាំសង្កូវខ្លះ ព្រោះខ្ញុំមានមាសបន្តិចបន្តួចជាប់នឹងខ្លួន ។

កន្លះខែក្រោយមក ថ្ងៃមួយ ពេលធ្វើស្រែរួច ខ្ញុំហៅកូនប្រុសរបស់ខ្ញុំ តែអត់ឮវាឆ្លើយសោះ ព្រោះខ្មែរក្រហមបានមកលបយកវាត្រឡប់ទៅសមរភូមិវិញ ។ វាបានត្រឡប់មកផ្ទះម្តងទៀតប្រហែល១៥ថ្ងៃបន្ទាប់ពីបដិវត្តន៍ចាប់ផ្តើមឡើង ។ សុង

ប្រាប់ខ្ញុំថា ប្រសិនបើមានអង្គការមកសុំកូនប្រុសម្នាក់ទៀតឲ្យចូលបដិវត្តន៍ ខ្ញុំមិនត្រូវយល់ព្រមទេ ។ ពេលដែលវាមកលេងនឹងខ្ញុំ វាបានយកដែកកេះមកឲ្យខ្ញុំដើម្បីទុកគ្រាន់ដូរយកមានហូប ។ វាបានថតរូបទាំងអស់នេះឲ្យយើងទុកជាអនុស្សាវរីយ៍ ។ ក្រោយឆ្នាំ១៩៧៩ វាត្រឡប់មកម្តងទៀត តែយើងមិនបានជួបគ្នា ដោយសារខ្ញុំជាប់រវល់ធ្វើការ ពេលដែលខ្ញុំរត់ទៅរកមើលវា វាបានត្រឡប់ទៅវិញបាត់ទៅហើយ ។

ក្រោយមក អ្នកភូមិខ្ញុំមកសួររកប្រវត្តិរូបរបស់កូនប្រុសខ្ញុំឈ្មោះ ស្រៀន ហើយសួរទៀតថាតើមានបងប្រុសធ្វើការជាជាងថតរូបនៅភ្នំពេញទេ ។ ខ្ញុំប្រាប់ថា សុង មិនមែនធ្វើការនៅក្នុងគុកទេ វាធ្វើការនៅការិយាល័យមួយនៅទីក្រុងភ្នំពេញ ។ ស្រៀន ក៏ត្រូវចាប់ដាក់គុក ។

ក្រោយពេលកងទ័ពវៀតណាមចូលមករំដោះប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ មានបុរសម្នាក់ប្រាប់ខ្ញុំថា សុង រស់នៅឯឃុំលើកដែក ។ ខ្ញុំក៏ទៅមើលវា តែអត់ឃើញវានៅទីនោះទេ ។ មានអ្នកផ្សេងទៀតថាបានឃើញ សុង ជិះសេះនៅឯភ្នំ ហើយថាបានសុំឲ្យវាមកភូមិជាមួយវិញ ប៉ុន្តែ សុង និយាយថា ខ្លាចកងទ័ពវៀតណាម វាមិនត្រឡប់មកវិញទេ លុះត្រាតែកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជាអស់សិន ។ ខ្ញុំបានរង់ចាំវាតាំងតែពីពេលនោះរហូតមក ។

**ស៊្រុន ស្រៀនៈ** ខ្ញុំចូលធ្វើបដិវត្តន៍ នៅឆ្នាំ១៩៧៤ ។ ខ្ញុំជាយុទ្ធជននៅកងកុមារ ហើយកាលណោះខ្ញុំក៏មានកាំភ្លើងមួយដើមដែរ ។ ក្រោយពេលរំដោះ ខ្ញុំទៅធ្វើជាអ្នកយាមឲ្យកងពលលេខ១១២នៅចាក់អង្រែ ទីក្រុងភ្នំពេញ ។

ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមស្នើខ្ញុំឲ្យទៅរស់នៅជាមួយ ឡេង ដែលជាមេបញ្ជាការកងកាំភ្លើងធំ ។ ក្រោយមក ឡេង ត្រូវអង្គការចាប់ខ្លួន ។ ដោយសារខ្មែរក្រហមបានដឹងជាមុនថា ខ្ញុំមានទំនាក់ទំនងជាមួយ ឡេង ខ្មែរក្រហមក៏បញ្ជូនខ្ញុំទៅមន្ទីរ០៨ នៅភ្នំពេញ ។ សន្តិសុខគុកបានដាក់ខ្នោះខ្ញុំដោយចោទថាខ្ញុំរត់ចោលសមរភូមិ ហើយថាខ្ញុំជាទាហានលន់ណុល និងជាខ្សែបណ្តាញរបស់ ឡេង ។

ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនទៅមន្ទីរសន្តិសុខព្រៃសនៅឆ្នាំដដែល ។ ខ្ញុំជាមនុស្សល្អ តែសន្តិសុខគុកប្រាប់មេបញ្ជាររបស់ខ្ញុំថា ខ្ញុំមិនល្អ ហើយថែមទាំងចោទខ្ញុំថាជាខ្មាំងទៀត ។ សន្តិសុខគុកដាក់ខ្នោះដៃខ្នោះជើងខ្ញុំនៅពេលយប់ ។ មិនត្រឹមតែប៉ុណ្ណោះ សន្តិសុខគុកសំពងក្បាលខ្ញុំនឹងដងពូថៅ ហើយថែមទាំងឆក់ខ្សែភ្លើងខ្ញុំទៀត ។ សន្តិសុខឈ្មោះ ឈួន បានចងជើងខ្ញុំព្យួរឡើងទៅលើ ។

នៅឆ្នាំ១៩៧៦ ខ្ញុំបានឃើញបង សុង ជិះកង់ទៅថតរូបអ្នកទោស ។ គាត់ថតរូបអ្នកទោសនៅទីក្រុងភ្នំពេញ និងពេលខ្លះនៅព្រៃសរ ។ ខ្ញុំបានស្រែកហៅគាត់ ។ គាត់បានប្រាប់អ្នកយាមឲ្យថែរក្សាខ្ញុំ ប៉ុន្តែអ្នកយាមទាំងនោះមិនជឿថាយើងជាបងប្អូនបង្កើតនឹងគ្នាទេ ព្រោះបង សុង មានសម្បុរខ្មៅ ចំណែកខ្ញុំមានសម្បុរជ្រះ ។ បង សុង ក៏តបទៅវិញថា គាត់កាត់ទោរកម្តាយ ហើយខ្ញុំកាត់ទៅខាងឪពុក ។ ទីបំផុត សន្តិសុខគុកក៏ជឿគាត់ ។

ពីមុន ខ្ញុំបានទទួលរបបបបរបីកំប៉ុងក្នុងមួយថ្ងៃ តែក្រោយពេលដែលបងប្អូនយើងជួបគ្នា ខ្ញុំទទួលបានរបបបបរច្រើនជាងមុន ។ សន្តិសុខគុកបានដោះខ្នោះប្រវាក់ចេញពីខ្ញុំនិងបញ្ជូនឲ្យខ្ញុំទៅធ្វើស្រែ ។ បងសុង ធ្លាប់បានឲ្យស្បែកជើងមួយគូមកខ្ញុំ ហើយជួនកាលក៏ឲ្យបារីដែរ ។ គាត់បានថតរូបឲ្យខ្ញុំ ។ ខ្ញុំបានដាក់រូបថតនៅក្នុងហោប៉ៅរហូតតែក្រោយមកក៏បាត់ទៅ ។ ក្រោយមកទៀត អង្គការបញ្ជូនខ្ញុំទៅឃ្វាលគោក្របីនៅវត្តកណ្តាល ។

នៅរវាងឆ្នាំ១៩៧៧និង១៩៧៨ អង្គការបានបញ្ជូនខ្ញុំទៅធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង ។ ខ្ញុំបានព្យាយាមធ្វើការយ៉ាងសកម្ម និងចូលរួមរាល់ការប្រជុំនានា ។ នៅឆ្នាំ១៩៧៨ អង្គការចាត់ឲ្យខ្ញុំត្រឡប់ទៅព្រៃសរវិញដោយខ្ញុំមិនបានដឹងពីមូលហេតុឡើយ ។ ខ្ញុំឃ្វាលគោក្របីនៅព្រៃស ។ ខ្ញុំធ្វើការជាមួយក្រុមស្ត្រីចំណាស់ដែលភាគច្រើនមានវ័យពី៣០ទៅ៥០ឆ្នាំ ខ្លះទៀតចាស់ជាងនេះក៏មាន ។ ខ្ញុំរស់នៅព្រៃសរហូតដល់ឆ្នាំ១៩៧៩ ។

នៅពេលកងទ័ពវៀតណាមវាយលុកចូលប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ ខ្ញុំបានរត់ចូលព្រៃ ។ ដោយសារខ្វះទឹកនិងអាហារអស់រយៈពេលយូរពេក ខ្ញុំបានដឹកទឹកនោមខ្លួនឯង ហើយសម្រេចចិត្តវិលត្រឡប់មកផ្ទះវិញ ។ បុរសម្នាក់នៅក្នុងភូមិបានវាយខ្ញុំនឹងពូថៅ និងចោទថាខ្ញុំជាខ្មែរក្រហម ហើយគាត់ក៏បើកឡានគូចចេញទៅ ។

**ទ្រី យន៖** ផ្ទះខ្ញុំត្រូវដុតបំផ្លាញនៅក្នុងរបបលន់ណុល ។ ទាហានវៀតណាមចុះមក ភូមិយើងតាមទូកពីទន្លេមេគង្គ ហើយប្រើសាំងដុតផ្ទះខ្ញុំ ។ ឃើញដូច្នេះ ខ្ញុំនិងកូនខ្ញុំឡើងឡានត្រឡប់ទៅភ្នំពេញ ហើយក៏បានជួបបងថ្លៃរបស់ខ្ញុំនៅទីនោះ ។ យើងមានតែខោអាវដែលស្លាយពីក្រោយខ្នងប៉ុណ្ណោះ ។ ប្តីខ្ញុំមិនដឹងថាត្រូវរកការងារអ្វីធ្វើឡើយនៅភ្នំពេញ ។ គាត់ក៏ធាក់ស៊ីក្លូ ។

នៅឆ្នាំ១៩៧២ ប្តីខ្ញុំនិយាយថា "ភ្នំពេញពិបាករស់នៅណាស់" ដូច្នេះយើងក៏ត្រឡប់មកនៅភូមិកំណើតវិញ ។ ខ្ញុំចង់ទៅបាត់ដំបង ប៉ុន្តែប្តីរបស់ខ្ញុំចង់រស់នៅភូមិព្រោះងាយស្រួលរកផ្លែឈើហូប ។ ពេលដែលយើងមកផ្ទះវិញបែរជាគ្មានអាហារគ្រប់គ្រាន់ ហើយនៅតែមានការទម្លាក់គ្រាប់បែក ។ អ្នកភូមិថាឲ្យខ្ញុំថាខ្ញុំនេះដូចឆ្កែ ។ ដូច្នេះខ្ញុំពកូនប្រុសម្នាក់ឈ្មោះ គីម រត់ទៅរកអាហារនៅកន្លែងឆ្ងាយៗ ។ ខ្ញុំលួចស្រូវហើយខ្ចប់ដាក់ក្នុងសំពត់ឲ្យវា ។ ខ្ញុំធ្វើដូចនេះរាល់ថ្ងៃ បើខ្ញុំមិនធ្វើដូច្នោះទេ វាពិតជាស្លាប់ ។

នៅភូមិយើងអស់រយៈពេលជាង៦ខែ ខ្មែរក្រហមបញ្ជូនខ្ញុំទៅដាក់គុកពោធិទន្លេដែលនៅត្រើយម្ខាងទៀត ។ ម្តាយខ្ញុំនិងកូនទាំងប្អូនរបស់ខ្ញុំក៏ទៅជាមួយខ្ញុំដែរ ។ ខ្ញុំអត់មានធ្វើអ្វីខុសទេ តែអង្គការប៉ងសម្លាប់ខ្ញុំនៅទីនោះ ។ មួយសប្តាហ៍ក្រោយមកមាននរណាម្នាក់ផ្ញើសំបុត្រឲ្យប្រធានមន្ទីរឃុំឃាំងថា ខ្ញុំមកពីគ្រួសារល្អទេ ត្រូវតែដោះលែង ។

ខ្ញុំធាក់រហាត់ទឹក ស្ទូងស្រូវ និងដាំបន្លែបង្ការដូចជាពោតសណ្តែក ។ បើមានអ្នកណាម្នាក់លួចសូម្បីតែពោតមួយផ្លែ នោះប្រាកដជាត្រូវអង្គការសម្លាប់ចោល ។ ខ្ញុំអាណិតកូនស្រីខ្ញុំណាស់ ។ នាងគ្មានអ្វីបរិភោគគ្រប់គ្រាន់ រីឯកូនស្រីរបស់គណៈភូមិបែរជាមានមិនខ្វះ ។ ថ្ងៃមួយខ្ញុំធ្វើការនៅឯសហករណ៍ចិញ្ចឹមមាន់និងនៅផ្ទះបាយ ហើយបានឃើញពោតមួយចំនួន ។ ខ្ញុំក៏យកពោតមួយផ្លែទៅចម្អិនលាយជាមួយបាយ ។ ខ្ញុំក៏បានចែកប្រជាជនដទៃទៀត ប៉ុន្តែមិនបានឲ្យកូនស្រីខ្ញុំទេ ។ ក្រោយមក មានអ្នកចោទ



គ្រួសាររបស់ ស្រ៊ុន សុង៖ គីម, ទូច, ទ្រី យន, លក និង ស៊ីម

ខ្ញុំថាលួចពោតឲ្យកូនស្រីខ្លួនឯង ។ ខ្ញុំបានលួចអង្ករឲ្យកូនស្រីខ្ញុំជារៀងរាល់ថ្ងៃ ។ ខ្ញុំមិនសប្បាយចិត្តនឹងធ្វើដូច្នេះទេ តែខ្ញុំចង់ឲ្យនាងមានជីវិតរស់បន្តទៀត ។

មានពេលមួយ គណៈភូមិបានជ្រមុជក្បាលខ្ញុំទៅក្នុងទឹកទន្លេ ដោយចោទខ្ញុំថាលួចពងមាន់ ។ ម្ដាយខ្ញុំឃើញដូចនេះក៏ស្រែកឡើង ហើយគណៈភូមិក៏ដោះលែងខ្ញុំ ។ បន្ទាប់ពីនោះ ខ្ញុំក៏រៀនហែលទឹក ព្រោះខ្ញុំខ្លាចត្រូវជ្រមុជទឹកម្ដងទៀត ។

# ស្រី យ៉េង, សមាជិកដឹកជញ្ជូនជ័រកៅស៊ូ

*(បទសម្ភាសន៍ជាមួយប្រពន្ធរបស់ ស្រី យ៉េង ឈ្មោះ គឹម ម៉ែន អាយុ៥៥ឆ្នាំ នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម)*



ស្រី យ៉េង
ថតក្នុងអំឡុងឆ្នាំ១៩៧២-៧៣

ខ្ញុំនិងប្ដីខ្ញុំជួបគ្នានៅពេលដែលគាត់អាយុ២១ឆ្នាំ ហើយខ្ញុំអាយុ១៩ឆ្នាំ ។ គាត់ឃើញខ្ញុំធ្វើការនៅឯស្រែក៏សុំខ្ញុំរៀបការនៅក្នុងឆ្នាំ១៩៦៩ ។ គាត់បានចូលរួមធ្វើបដិវត្តន៍ដើម្បីការពារអ្នកភូមិពីទាហានលន់ណុល ។ ដំបូងគាត់ជាអ្នកយាមនៅមន្ទីរឃុំ ហើយធ្វើស្រែនៅពេលល្ងាច ។ នៅឆ្នាំ១៩៧៦ គាត់ត្រូវអង្គការចាត់ឲ្យទៅធ្វើការនៅចម្ការកៅស៊ូនៅបឹងកេត ។ ខ្ញុំធ្វើការខាងប្រមូលជ័រកៅស៊ូចម្ងាយប្រហែល១០គីឡូម៉ែត្រពីកន្លែងគាត់ធ្វើការ ។ គាត់មិនបានប្រាប់ខ្ញុំអំពីមុខងាររបស់គាត់នៅក្នុងជួរខ្មែរក្រហមទេ ហើយខ្ញុំក៏មិនបានសួរនាំគាត់ដែរ ។

នៅឆ្នាំ១៩៧៧ ខ្ញុំដឹងថាប្រធាននៅចម្ការកៅស៊ូឈ្មោះ សេត ហៅគាត់ទៅរៀនសូត្រ ។ ខ្ញុំអស់សង្ឃឹម ព្រោះខ្ញុំដឹងថាគាត់ស្លាប់ហើយ ។ ពេលដែលខ្មែរក្រហមហៅប្រជាជនទៅរៀនសូត្រ គឺមានន័យថាយកទៅសម្លាប់ ។ ក្រោយមកខ្ញុំទទួលដំណឹងថា សេត និងអ្នកដែលនៅក្នុងកងជាមួយគ្នាប្រមាណ២០នាក់ ត្រូវអង្គការហៅឲ្យទៅរៀនសូត្រក្នុងពេលជាមួយគ្នា ។ អ្នកទាំងនោះត្រូវបញ្ជូនទៅភ្នំពេញមិនដឹងជាទៅកន្លែងណាមួយទេ ។ ខ្ញុំភ័យខ្លាំងណាស់ពេលដែលឮសូរដូចនេះ ។ ខ្ញុំមានអារម្មណ៍ថាថ្ងៃណាមួយ ខ្មែរក្រហមពិតជាសម្លាប់ខ្ញុំដែរជាមិនខាន ។

ខ្ញុំ និង សេត មានកូនស្រី៤នាក់ ។ នៅអំឡុងពេលធ្វើបដិវត្តន៍ កូនខ្ញុំ២នាក់នៅជាមួយខ្ញុំ ឯ២នាក់ទៀតនៅកងកុមារជាមួយស្ត្រីចាស់ៗ ។ ខ្ញុំមិនទុកចិត្តស្ត្រីទាំងនោះប៉ុន្មានទេ ព្រោះអ្នកដទៃមិនថែទាំកូនយើងដូចយើងជាម្ដាយឡើយ ។ កូនរបស់ខ្ញុំនៅតូចៗ នាងបងបង្អស់អាយុ៤-៥ឆ្នាំ ហើយនាងពៅអាយុទើបតែ៦ខែ ។ កូនពៅទើបតែរៀនអង្គុយពេលដែលអង្គការចាប់ខ្លួនឪពុកយកទៅ ។

ពេលល្ងាច ខ្ញុំត្រឡប់មកពីធ្វើការ ខ្ញុំហូបបាយជាមួយកូនៗ រួចដាក់ឲ្យវាដេក ។ ព្រឹកព្រលឹមស្រាងៗខ្ញុំត្រូវយកវាទៅកងកុមារវិញ ។ ជួនកាល ខ្ញុំមានតែបាយក្រៀមបន្តិចបន្តួចក៏ខ្ញុំទុកឲ្យកូន ។ ក្មេងអត់មានអាហារគ្រប់គ្រាន់ទេ ខ្ញុំអាណិតវាណាស់ ។ ខ្មែរក្រហមមិនឲ្យយើងយកអ្វីពីសហករណ៍ តែពេលខ្លះខ្ញុំលួចយកបន្លែខ្លះៗទៅស្ងោរគ្រាន់ឲ្យកូនហូប ។

ថ្ងៃមួយក្នុងឆ្នាំ១៩៧៧ កូនស្រី ខ្ញុំឈ្មោះ ភា មានជំងឺ ។ ខ្ញុំភ័យស្ទន់ ពេលដែលឃើញនាងប្រកាច់ញាក់ និងនិយាយមមើមមាយអត់ដឹងទិសតំបន់ ។ ខ្ញុំក៏ចាប់សរសៃឲ្យនាង ហើយឱបនាងជាប់ ។ អ្នកជិតខាងតែពីរបីនាក់ប៉ុណ្ណោះបានមកមើលនាង ព្រោះខ្លាចគ្រាប់ផ្លោង ។ គ្មានអ្នកណារកពេទ្យរកហ្នឹអីទេ ។ ភា ស្លាប់ក្នុងថ្ងៃដដែល ។ ពេលនោះនាងមានអាយុទើបតែ៤-៥ឆ្នាំប៉ុណ្ណោះ ។

អង្គការបានសម្លាប់ប្រជាជនជាច្រើននាក់នៅចម្ការអណ្ដូង ហើយបោះសាកសពចូលទៅក្នុងអណ្ដូង ។ បុរសម្នាក់ឈ្មោះ ស៊ីម នៅក្បែរផ្ទះខ្ញុំ ត្រូវខ្មែរក្រហមវាយចំកញ្ចឹងក គ្រវែងគាត់ចូលទៅក្នុងអណ្ដូង ហើយបោះសាកសពជាច្រើនទៀតលើគាត់ បន្ទាប់មកបាញ់រះស្រោចពីលើបន្ថែមទៀត ។ ស៊ីម ប្រឹងងើបចេញពីសាកសពទាំងនោះដើម្បីឡើងមកលើ ។ គាត់ស្រែកហៅឪពុកម្ដាយរបស់គាត់ឲ្យជួយទាញគាត់ឡើង ប៉ុន្តែពេលដែលឪពុកនិងបងប្រុសគាត់មកជួយ ខ្មែរក្រហមបានបាញ់សម្លាប់អ្នកទាំងពីរ ចំណែក ស៊ីម បានគេចខ្លួនបាត់ ។

បងប្អូនប្រុសខាងប្ដីខ្ញុំបីនាក់ធ្លាប់ធ្វើជាទាហានខ្មែរក្រហម ។

ចាប់ពីពេលដែលខ្ញុំបាត់ដំណឹងអ្នកទាំងអស់ ខ្ញុំគិតថាគាត់ស្លាប់អស់ហើយ ។ បងប្អូនប្រុសរបស់ខ្ញុំពីរនាក់និងបងប្អូនជីដូនមួយប៉ុន្មាននាក់ក៏បាត់ខ្លួនដែរ ។

ខ្ញុំនៅតែនឹកគិតដល់ប្តីខ្ញុំ ហើយកូនៗរបស់ខ្ញុំនៅតែសួរនាំអំពីប៉ារបស់វា ។ ខ្ញុំប្រាប់កូនៗខ្ញុំថា ឪពុករបស់វាត្រូវអង្គការចាប់ខ្លួន ។ គាត់បាត់ខ្លួនយូរណាស់មកហើយគ្មានផ្លូវដែលថាគាត់នៅរស់ទេ ។

# ឃួន នី និង ឃួន សំបាន់, នារីពេទ្យ

*(បទសម្ភាសន៍ជាមួយប្អូនប្រុសឈ្មោះ ឃួន គុងហេង អាយុ៤៣ឆ្នាំ និងម្តាយឈ្មោះ វ៉រ យ៉ាង អាយុ៨៣ឆ្នាំ នៅស្រុកចម្ការលើ ខេត្តកំពង់ចាម)*


ឃួន គុងហេង

**ឃួន គុងហេង:** បងស្រី សំបាន់ បានថតរូបទាំងនេះទុក ។ គាត់ជាកូនទីប្រាំក្នុងចំណោមគ្រួសារដែលមានកូន៨នាក់ ។ គាត់បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧២ ។ ខ្ញុំមិនដឹងថាគាត់ធ្វើអីទេ ដឹងត្រឹមតែថាគាត់និងប្តីរបស់គាត់នៅទីក្រុងភ្នំពេញ ។ គាត់បានរៀបការជាមួយប្រធានកងវរៈសេនាធំឈ្មោះ ម៉ន ។ បងម៉ន បានរក្សាទុកម៉ាស៊ីនថតគ្រាប់ថតរូបនៅវាលស្រែ និងតាមអូរប្រឡាយនានា ។

នៅឆ្នាំ១៩៧៦ ឪពុកម្តាយ របស់ខ្ញុំបានទទួលការអនុញ្ញាតឲ្យទៅភ្នំពេញពីរថ្ងៃ ។ ពួកគាត់ជួបបងសំបាន់ នៅទីនោះ ។ បងសំបាន់ ប្រាប់ឪពុកម្តាយខ្ញុំថា បងម៉ន ត្រូវអង្គការចាប់ខ្លួន ។ អង្គការចោទ បងម៉ន ថាជាខ្មែរបណ្តាញវៀតណាម ។ ប្រធានរបស់គាត់ឈ្មោះ អឿន ត្រូវបានអង្គការចាប់ខ្លួនពីរសប្តាហ៍មុនពេលចាប់ខ្លួនគាត់ ។ ខ្ញុំគ្មានភ័យខ្លាចអីទាំងអស់ ដោយសារខ្ញុំនៅក្មេងពេក ។ ឪពុកខ្ញុំខ្វល់ខ្វាយអំពីបងស្រីខ្ញុំជាខ្លាំង ។ ឪពុកខ្ញុំនិយាយថា "បើខ្មែរក្រហមសួរឯងពីវណ្ណៈ ឯងប្រាប់ទៅថាឯងនៅវណ្ណៈកណ្តាល កុំប្រាប់គេថាជាអ្នកមានឲ្យសោះ" ។

ក្រោយមកទើបខ្ញុំដឹងថា សំបាន់ ត្រូវចាប់ខ្លួននៅឆ្នាំ១៩៧៧ តែខ្ញុំមិនដឹងថាមូលហេតុអីទេ ។ គាត់មានកូនស្រីម្នាក់ដែលខ្ញុំមិនដែលបានជួបសោះ ។ ខ្ញុំគិតថា ខ្មែរក្រហមបញ្ជូនសំបាន និងកូនស្រីរបស់គាត់ទៅគុកព្រៃសរ (ខ្ញុំអត់ស្គាល់គុកទួលស្លែងទេពេលនោះ) ។

ខ្ញុំមិនបានទទួលដំណឹងពីគាត់និងបងស្រីខ្ញុំម្នាក់ទៀតឈ្មោះ នី តាំងពីពេលនោះមក ។ ខ្ញុំបានរកគ្រូទាយជាច្រើននាក់ដេម្បីសួរអំពីរឿង បងសំបាន់ ។ ពេលដែលគ្រូទាយប្រាប់ខ្ញុំថាគាត់នៅរស់ខ្ញុំសប្បាយចិត្តណាស់ ។ ឥឡូវខ្ញុំបានឃើញរូបថតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញខ្ញុំ ទើបខ្ញុំដឹងថាគាត់ស្លាប់ហើយ ។

បងប្រុសរបស់ខ្ញុំឈ្មោះ វី ជាអតីតទាហានខ្មែរក្រហមបានស្លាប់នៅឆ្នាំ១៩៧៦ ពេលនោះគាត់មានអាយុ២០ឆ្នាំ ។ ទាហានផ្សេងទៀតខឹងនឹងគាត់ណាស់ ព្រោះគាត់មិនឲ្យម៉ាញ៉ូទៅគេ ហើយសុខចិត្តបោះវាចោល ។ ទាហានក៏ឲ្យគាត់ឡើងបេះនិងប្រមូលផ្លែដូង ។ ក្រោយមកគេបានចាក់សម្លាប់គាត់នឹងកាំបិតវែងមួយ ។ បងប្អូនបង្កើតរបស់ខ្ញុំទាំងប៉ុន្មាននាក់សុទ្ធតែនៅរស់ដល់បច្ចុប្បន្នលើកលែងតែបង ស្រីខ្ញុំដែលបានស្លាប់ដោយសារជាន់មីននៅតំបន់ស្រែវាលក្នុងស្រុកនេះ ។

ខ្ញុំបានចូលបដិវត្តន៍នៅឆ្នាំ១៩៧៥មាននាទីជាសមាជិកកងកុមារ៣១០ ។ ពេលនោះខ្ញុំមានអាយុ១២ឆ្នាំ ។ បងសំបាន់ ចុះឈ្មោះឲ្យខ្ញុំដោយប្រាប់ខ្ញុំថា គាត់ចង់ឲ្យខ្ញុំរៀនសូត្រ ។ គាត់និងប្តីរបស់គាត់ដឹកខ្ញុំទៅភ្នំពេញជាកន្លែងដែលខ្ញុំស្នាក់នៅ និងជាកន្លែងបណ្តុះបណ្តាលនៃមន្ទីរពេទ្យ ព្រះកេតុមាលានិងមន្ទីរពេទ្យអង្គឌួង ។ ខ្ញុំនៅទីនោះតែមួយខែសោះ ប៉ុន្តែហាក់បីដូចជាយូរណាស់សម្រាប់ខ្ញុំ ។

ខ្ញុំអត់មានអាហារគ្រប់គ្រាន់ទេ ។ ខ្ញុំផ្លាស់ទៅទួលគោកឯជាយក្រុងភ្នំពេញ ហើយការងារលំបាកយ៉ាប់យ៉ឺនណាស់ ។ ខ្ញុំរែកដីស្រោចបន្លែ និងចាំចម្ការ ។ ជីវិតខ្ញុំលំបាកមិនខុសពីប្រជាជនដែលរស់នៅតាមភូមិទេ ។ ខ្ញុំរស់នៅដោយឡែកពីឪពុកម្តាយ ។ អង្គការឲ្យទៅចាំចម្ការពោត ។

ខ្ញុំត្រឡប់ទៅមន្ទីរពេទ្យអង្គឌួងនៅភ្នំពេញវិញនៅឆ្នាំ១៩៧៨ ។ ខ្ញុំរៀនអក្សរខ្មែរនៅទីនោះ ។ នៅឆ្នាំដដែល ខ្ញុំបានទៅវត្តថ្មោងដែលស្ថិតនៅភាគខាងជើងខេត្តកំពង់ចាមដើម្បីទៅមើលអ្នកត្រូវរបួស ។ ជារៀងរាល់ថ្ងៃ មានទាហានត្រូវរបួសប្រហែលកន្ទះឡាន



យួន នី (ថតនៅភ្នំពេញ)

ធំៗត្រូវដឹកមកដាក់ទីនោះ ។ ភាគច្រើនខ្ញុំទៅយួរទឹកមកលាងរបួស ។ ខ្ញុំបានចាក់ថ្នាំឲ្យទាហានដែលត្រូវរបួសពីរបីដងដែរ តែខ្ញុំមិនបានទទួលការណែនាំអ្វីត្រឹមត្រូវទេ ។ ខ្ញុំមិនស្ទាក់ស្ទើរនឹងធ្វើកិច្ចការនេះទេ ទោះបីជាខ្ញុំមិនមានចំណេះដឹងខាងពេទ្យក៏ដោយ ប៉ុន្តែខ្ញុំពិបាកនឹងមើលអ្នកជំងឺទាំងនោះណាស់ ។ ខ្ញុំពិតជាខ្លើមមុខរបួសខ្លាំងណាស់ ។

ក្រោយមកទៀត ខ្ញុំបានទៅឲ្យចំណីមាន់នៅទួលគី ។ ខ្ញុំនៅទីនោះបានតែមួយខែប៉ុណ្ណោះ មុនពេលដែលកងទ័ពវៀតណាមចូលមកដល់ ។ នៅភ្នំពេញមានការច្បាំងគ្នាយ៉ាងក្តៅគគុក នៅពេលនោះ ដូច្នេះខ្ញុំក៏រត់គេចទៅធ្វើស្រែចម្ការនៅខេត្តពោធិ៍សាត់ រហូតទាល់តែខ្ញុំត្រឡប់ទៅផ្ទះវិញនៅឆ្នាំ១៩៨២ ។

**វីរ យ៉ាង:** ខ្ញុំសប្បាយចិត្ត ហើយភ័យខ្លាចនៅពេលដែលឃើញកូនៗខ្ញុំចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ កូនស្រីខ្ញុំផ្ញើឆ្នាំងដាំបាយធំមួយឲ្យខ្ញុំ ក្រោយមកអង្គការយកឆ្នាំងនោះទៅប្រើប្រាស់ក្នុងសហករណ៍ ។

ប្តីខ្ញុំនិងខ្ញុំបានទៅភ្នំពេញ ព្រោះ សំបាន់ សរសេរសំបុត្រឲ្យខ្ញុំយកអង្ករដំណើបដើម្បីធ្វើបុណ្យសពឲ្យកូនស្រីខ្ញុំឈ្មោះ នី ។ នាងទើបតែស្លាប់ ហើយ សំបាន់ កំពុងតែរង់ចាំយើងទៅបូជាសពនាង ។ ក្រោយមកទៀត នាងប្រាប់ខ្ញុំថា ម៉ន ត្រូវអង្គការចាប់ឃុំនៅឯគុកខាងជើងផ្ទះគាត់ ។ យើងភ័យខ្លាចណាស់ ។ ខ្ញុំយំមិនឲ្យឮសូរទេ តែប្រុសៗដែលនៅជុំវិញខ្ញុំហាក់ដូចជាមួម៉ៅ ។ កាលនោះខ្ញុំឃើញខ្មែរក្រហមបណ្តើរ កូនស្រីខ្ញុំទៅទិសខាងលិច ខ្ញុំឆ្ងល់ថាតើខ្មែរក្រហមយកនាងទៅឯណា ។ ប្តីរបស់ខ្ញុំយល់ថា សំបាន់ ត្រូវខ្មែរក្រហមចងក្នុងបាវស្រូវហើយត្រូវសម្លាប់ចោល ។ ក្រោយមកទៀត មានអ្នកប្រាប់ខ្ញុំថា ខ្ញុំគួរតែទៅមន្ទីរសន្តិសុខស-២១ ប្រសិនបើខ្ញុំចង់ឃើញរូបថតរបស់ សំបាន់ ។

ខ្ញុំបានជួបនឹងកូនស្រីរបស់ សំបាន់ ម្តងកាលនាងនៅជាកូនង៉ែតមិនទាន់ទាំងចេះនិយាយផង ។ ខ្ញុំមិនបានចាំឈ្មោះនាងទេ ។ ខ្ញុំគិតថានាងតូចនោះក៏ត្រូវខ្មែរក្រហមសម្លាប់ដែរ ព្រោះបើឪពុកម្តាយរបស់នាងត្រូវខ្មែរក្រហមសម្លាប់ចោលអស់ទៅហើយនោះ ។

កូនៗខ្ញុំជាមនុស្សល្អត្រឹមត្រូវមិនដែលបង្កការលំបាកដល់ខ្ញុំ និងមិនដែលធ្វើអ្វីខុសម្តងណាឡើយ ។ កូនៗខ្ញុំស្រលាញ់ខ្ញុំណាស់ ។ កូនៗរបស់ខ្ញុំស្លាប់ដោយស្ងប់សុខហើយ ។ ខ្ញុំយល់ថា ព្រលឹងរបស់កូនខ្ញុំពិតជាបានទៅកាន់សុគតិភព ។

# មោង សំអឿន
# កម្មកររោងចក្រថាមពលនិងទឹក

*(បទសម្ភាសជាមួយប្អូនស្រីឈ្មោះ កែប សុធា អាយុ៤៩ឆ្នាំ នៅទីក្រុងភ្នំពេញ)*

ពេលដែលគ្រួសារខ្ញុំត្រូវខ្មែរក្រហមជម្លៀសចេញពីភ្នំពេញនៅឆ្នាំ១៩៧៥ សមាជិកគ្រួសារខ្ញុំភាគច្រើនធ្វើដំណើរទៅខេត្តកណ្តាល ។ ពូខ្ញុំឈ្មោះ ម៉ែន ធីម ប្រាប់ខ្ញុំថា អង្គការប្រកាសរកអ្នកដែលចេះធ្វើប្រព័ន្ធទឹកភ្លើង ។ បងស្រី អឿន និងប្តីគាត់ឈ្មោះ សារ៉ុម ធ្លាប់ធ្វើការខាងរដ្ឋករទឹកនៅភ្នំពេញកាលពីជំនាន់សម្តេចសីហនុ ។ ដូច្នេះគាត់ទាំងពីរនាក់បានត្រឡប់ទៅទីក្រុងវិញ ព្រោះមិនចង់នៅសមរភូមិមុខ ។

គាត់ទៅធ្វើការឲ្យបុរសម្នាក់ឈ្មោះ ព្រាប ជាអ្នកគ្រប់គ្រងនៅរោងចក្រថាមពលនិងទឹក ។ ពូធីម ជាអ្នកបើកឡានឲ្យប្រធានរោងចក្រថាមពលនោះ ។ មិត្តព្រាប ចាត់ទុកគ្រួសារខ្ញុំដូចជាគ្រួសារគាត់ដែរ ។

នៅឆ្នាំ១៩៧៨ អង្គការបានសម្លាប់ មិត្តព្រាប និងឪពុកម្តាយរបស់គាត់ ព្រមទាំងបងប្អូនកូនក្មួយរបស់គាត់អស់លើង ។ មួយអាទិត្យក្រោយមក ពូខ្ញុំឃើញខ្មែរក្រហម៦-៧នាក់មានកាំភ្លើងគ្រប់ដៃមកចាប់ បងអឿន, បងសារ៉ុម, កូនៗរបស់គាត់ ឪពុកម្តាយខ្ញុំ និងសមាជិកដទៃទៀតក្នុងគ្រួសារ សរុប១២នាក់ ដាក់ឡានយកទៅ ។ ពូខ្ញុំគិតថាប្រហែលជាក្រុមគ្រួសារខ្ញុំត្រូវស្លាប់ដោយសារការផារហើយ ។

ក្រោយឆ្នាំ១៩៧៩ ពូខ្ញុំធ្លាក់ខ្លួនឈឺ ។ ជើងគាត់ហើមធំដូចជើងក្របី ។ ខ្ញុំជាអ្នកថែទាំជំងឺគាត់ ។ ពេលគាត់ជាបានស្រួលបួលហើយ គាត់ជិះឡានទៅក្រុងព្រះសីហនុ ហើយក៏ស្លាប់ដោយសារគ្រោះថ្នាក់ក្រឡាប់ឡាន ។ គាត់បន្សល់ទុកកូន៥នាក់ឲ្យខ្ញុំចិញ្ចឹម ។

ប្អូនប្រុសខ្ញុំឈ្មោះសាម៉េត និងក្មួយប្រុសខ្ញុំ ធ្វើការនៅកងចល័តបែកពីផ្ទះពីគ្រួសារ ។ បុរសម្នាក់ស្គាល់ឪពុកខ្ញុំបានប្រាប់ខ្ញុំថា សាម៉េត នៅរស់នៅឡើយ ។ គាត់បានជួប សាម៉េត កាលឆ្នាំ១៩៧៩ ហើយថែមទាំងបានបបួល សាម៉េត រត់ចេញពីកងទាំងអស់គ្នា ប៉ុន្តែប្អូនប្រុសខ្ញុំមិនហ៊ាន ខ្លាចមេកងសម្លាប់វាចោល ។ ឪពុកម្តាយខ្ញុំមានកូនទាំងអស់៧នាក់ ក្នុងនោះ៥នាក់ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល ។ ខ្ញុំនៅមិនច្បាស់នៅឡើយថាតើ សាម៉េត នៅរស់ឬស្លាប់ទេ ។

ឆ្នាំ១៩៧៥ ខ្ញុំនៅធ្វើការនៅរោងចក្រតម្បាញ សេងថៃ ។ ពេលដែលខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ ខ្ញុំកំពុងតែនៅផ្ទះឪពុកម្តាយខ្ញុំ ។ ពេលនោះខ្ញុំក៏រត់យ៉ាងលឿនសំដៅទៅផ្ទះដើម្បីរកប្តីខ្ញុំឈ្មោះ វុទ្ធី ។ ខ្ញុំរត់តាមផ្លូវក្រោយ ទើបមិនជួបកងទ័ពខ្មែរក្រហម ។ ខ្ញុំនិងប្តីខ្ញុំជួបគ្នានៅម៉ោងប្រហែល៥កន្លះល្ងាច ។

កងទ័ពខ្មែរក្រហមមកដល់ផ្ទះខ្ញុំប្រហែលម៉ោង៧យប់ ហើយប្រាប់ខ្ញុំនិងប្តីខ្ញុំកុំឲ្យដេកនៅក្បែរទ្វារផ្ទះ ព្រោះអីកងទ័ពដើរល្បាត ។ ខ្ញុំមានបាយម្ហូបខ្លះៗចែកឲ្យខ្មែរក្រហមទាំងនោះ ។ ពេលហូបចុករួចហើយ កងទ័ពខ្មែរក្រហមប្រាប់យើងកុំឲ្យយកលុយកាក់ទៅជាមួយ ព្រោះប្រទេសខ្មែរនឹងឈប់ចាយលុយហើយ ។ ខ្មែរក្រហមប្រាប់ឲ្យយកតាមខ្លួនតែខោអាវ អំបិល និងប្រហុកតែប៉ុណ្ណោះ ។ ខ្ញុំយកតាមខ្លួននូវរបស់របរតាមដែលកងទ័ពខ្មែរក្រហមនោះប្រាប់ ប៉ុន្តែខ្ញុំនៅមិនជឿពីរឿងឈប់ចាយលុយសោះ ដូច្នេះខ្ញុំក៏បានយកលុយកាក់ទៅជាមួយដែរ ។ ក្រោយមកខ្ញុំអាចចាយវាយលុយមួយចំនួននៅពេលក្រោយ ។

យើងចេញពីភ្នំពេញជិះទូកទៅព្រែកក្តាមនៅខេត្តកណ្តាលចំណាយពេលអស់បួនថ្ងៃបួនយប់ ។ នៅទីនោះ ខ្មែរក្រហមសួរយើងអំពីស្រុកកំណើត ។ ខ្ញុំប្រាប់ថាស្រុកនៅខេត្តតាកែវ ហើយប្តីខ្ញុំនៅបាត់ដំបង ។ ខ្មែរក្រហមសួរទៀតថាចង់ទៅរស់នៅកន្លែងណា ។ ខ្ញុំប្រាប់ថាចង់ទៅបាត់ដំបង ។ ក្រោយមកខ្មែរក្រហមក៏បង្ខំឲ្យខ្ញុំឡើងឡានហ្សីបមួយ ។ ប្តីខ្ញុំយួរវ៉ាលីសដាក់ឥវ៉ាន់ ប៉ុន្តែខ្មែរក្រហមមិនឲ្យគាត់ឡើងឡានទេ ។

ប្រជាជនរាប់លាននាក់នៅតាមផ្លូវខំប្រឹងរត់តោងចូលឡានហ្សីបនោះដែរដោយមានបង្ខិចមកជាមួយផង ។ ក្រោយមកឡានចង្អៀតរហូតដល់ខ្ញុំមិនអាចកម្រើកជើងមិនបាន ។ ពេលនោះខ្ញុំកំពុងតែបីកូនផង ខ្ញុំក៏ស្រែកឲ្យអ្នកទាំងនោះយកឥវ៉ាន់ចេញឲ្យឆ្ងាយ ។ អ្នកបើកឡានហ្សីបបានឈប់ឡាននៅខេត្តកំពង់ធំ ហើយប្រាប់ឲ្យខ្ញុំចុះទៅជិះឡានមួយទៀត ។ ខ្ញុំយំមិនចង់ទៅទេ ព្រោះចង់ចាំប្តីខ្ញុំមួយយប់សិន ។ ខ្មែរក្រហមក៏យល់ព្រមឲ្យខ្ញុំស្នាក់នៅក្នុងវត្តមួយ ។ ព្រះសង្ឃនៅទីនោះចិត្តល្អណាស់ ។ ខ្ញុំប្រគេនវិទ្យុនិងកាសែតខ្លះទៅលោក ។ ខ្ញុំបួងសួងដល់ព្រះសូមឲ្យបានជួបប្តីខ្ញុំវិញ ។ ប្រហែល២០នាទីក្រោយមក ស្រាប់តែប្តីខ្ញុំមកដល់វត្តនោះ គឺគាត់បានដូរវ៉ាលីសជាមួយអ៊ីម្នាក់បានកង់មួយ ។

វុទ្ធី ដឹងថាខ្ញុំតម្រង់ទៅកំពង់ធំ គាត់បានសុំដោយសារឡានមួយដែលដឹកសុទ្ធតែកម្មាភិបាលខ្មែរក្រហម ។ គាត់សំណាងដែរដោយខ្មែរក្រហមព្រមឈប់ឡានឲ្យគាត់ចុះនៅជិតកន្លែងដែលខ្ញុំស្នាក់នៅ ។

ព្រឹកឡើងយើងចេញទៅខេត្តបាត់ដំបង ប៉ុន្តែខ្មែរក្រហមបែរជាដាក់យើងចុះនៅខេត្តកំពង់ចាមទៅវិញ ។ ខ្ញុំភ្ញាក់ផ្អើល

ដោយសារមកខុសទិសដៅ ។ យើងរស់ក៏នៅខេត្តកំពង់ចាមរហូតទាល់តែរបបខ្មែរក្រហមដួលរលំតែម្តង ។

ខ្មែរក្រហមអត់មានធ្វើបាបខ្ញុំនិងប្តីខ្ញុំទេ ដោយសារអ្នកភូមិបានដឹងថាយើងជាកម្មករ ។ យើងដាំបន្លែគ្រប់មុខ តែអង្គការមិនឲ្យយើងហូបបន្លែនោះទាល់តែសោះ ។ ពេលដែលបន្លែបង្កាបានផល យើងចាំបាច់ប្រមូលវាជូនអង្គការ ។ យើងបានបាយហូបបួនខែដែរក្នុងមួយឆ្នាំ ។

គណៈភូមិខ្ញុំចិត្តល្អ គាត់នៅរស់ដល់សព្វថ្ងៃដែរ ។ មានអ្នករាយការណ៍ប្រាប់គាត់ថា ប្តីខ្ញុំជាទាហានដាន់ខ្ពស់នៅកងអាកាស ហើយថាខ្ញុំជាសាស្ត្រាចារ្យ ។ ម្នាក់នោះច្រណែនដោយឃើញខ្ញុំមានគ្រឿងអលង្ការពាក់ ។ តាមធម្មតាបើមាននរណាម្នាក់រាយការណ៍ដូច្នេះ អ្នកឯងនឹងត្រូវអង្គការយកទៅវាយចោលហើយ ប៉ុន្តែគណៈភូមិមកនិយាយជាមួយខ្ញុំនិងប្តីខ្ញុំជាមុនសិន ។ យើងប្រាប់គណៈភូមិដោយស្មោះត្រង់ថា យើងពិតជាកម្មករមែន ហើយគាត់ក៏ជឿយើង មិនយកយើងទៅសម្លាប់ ។


មោង សំអឿន

យ៉ាងណាក៏ដោយគណៈស្រុកមិនជឿខ្ញុំនិងប្តីខ្ញុំទេ ។ គណៈស្រុកប្រឹងតាមដានយើងក្រែងយើងមានទំនាក់ទំនងអ្វី ។ ដូច្នេះខ្ញុំនិយាយតែអំពីគ្រឿងចក្រដើម្បីបង្ហាញថាខ្ញុំជាកម្មករមែន ។ ក្រោយមកគណៈស្រុកនោះត្រូវអង្គការសម្លាប់ចោលដោយចោទថាគាត់ជាបញ្ញវន្ត ។ អង្គការថែមទាំងសម្លាប់គណៈស្រុកបួននាក់ទៀតបន្ទាប់ពីគាត់ ។

នៅក្នុងផ្ទះដែលខ្ញុំរស់នៅមានបួនប្រាំគ្រួសារផ្សេងទៀតដែលជម្លៀសមកពីភ្នំពេញដែរ ។ អង្គការយកគ្រួសារទាំងនោះទៅសម្លាប់ចោលទាំងអស់ ដោយសារតែអ្នកទាំងនោះចេះតែអួតអំពីខ្លួនឯង ។ អ្នកទាំងនោះអួតថាខ្លួនជាអ្នកមាន មានឡានមានអ្វីជាច្រើន តែតាមពិតគ្រួសារទាំងនោះក្រណាស់ ។ អង្គការមានមនុស្សបង្កប់នៅជាមួយយើង និងមានក្មេងនៅលបចាំស្តាប់ក្រោមផ្ទះក្រែងយើងនិយាយអ្វី ។ ខ្ញុំមើលតាមប្រហោងក្តារឃើញក្មេងៗនៅក្រោមផ្ទះ ។ ដូច្នេះខ្ញុំនិយាយតែអំពីការឈឺចាប់របស់ខ្ញុំនិងប្តីខ្ញុំ ។

នៅក្នុងរបបនោះខ្ញុំគ្រប់គ្រងប្រាំពីរគ្រួសារសុទ្ធតែស្ត្រីមេម៉ាយ ។ ផ្ទះខ្ញុំធំណាស់ ។ ដោយក្តីអាណិត ខ្ញុំបានហៅស្ត្រីមេម៉ាយទាំងនោះមករស់នៅជាមួយខ្ញុំ ។ ទោះបីជាខ្ញុំបានជួយស្ត្រីមេម៉ាយទាំងនោះ និងចែករំលែកអាហារឲ្យច្រើនយ៉ាងណាក៏ដោយ ក៏អ្នកទាំងនោះនៅតែមានចិត្តច្រណែនឈ្នានីស ព្រោះឃើញខ្ញុំនិងប្តីខ្ញុំមានម្ហូបអាហារច្រើន ។ ស្ត្រីទាំងនោះជេរប្រមាថខ្ញុំថាៈ «បើយើងមានប្តីវិញណា៎ ប្តីយើងប្រាកដជាចិញ្ចឹមយើងហើយ» មិនត្រឹមតែប៉ុណ្ណោះស្ត្រីទាំងនោះបានរាយការណ៍ទៅថ្នាក់លើថែមទៀត ។ អង្គការក៏សម្លាប់ស្ត្រីមេម៉ាយទាំងនោះចោលអស់ ។

មានទីតាំងមួយហៅថា គាពុំ ដែលអង្គការយកប្រជាជនទៅសម្លាប់នៅទីនោះទាំងយប់ទាំងថ្ងៃ ។ កន្លែងនោះមានចម្ងាយប្រហែលមួយគីឡូម៉ែត្រកន្លះពីវាលស្រែ ។ ពីវាលស្រែទៅខ្ញុំអាចមើលឃើញ អាចឮសំឡេងស្រែកយំថ្ងូចថ្ងូរពេលដែលមានខ្យល់បក់មកម្តងៗ ។ ក្រោយខែច្រូតយើងទៅឃ្វាលគោ ។ ជួនកាលយើងលបចូលទៅជិតវាលគាពុំដើម្បីលួចមើល ។ ខ្ញុំឃើញខ្មែរក្រហមជីករណ្តៅទាំងយប់សម្រាប់ដាក់មនុស្ស ។

រវាងឆ្នាំ១៩៧៧និង១៩៧៨ ការសម្លាប់មនុស្សកើនឡើង ។ បើអង្គការចង់សម្លាប់ម្នាក់នៅថ្ងៃស្អែក អង្គការឲ្យនិរសារជិះសេះមកប្រាប់មេភូមិទាំងយប់ ។ ពេលអ្នកភូមិឮស្នូរជើងសេះគ្មានអ្នកណាម្នាក់ដេកលក់ទេ ។ ស្អែកឡើងប្រាកដជាមាននរណាម្នាក់ត្រូវខ្មែរក្រហមយកទៅសម្លាប់ ។

# សេចក្តីប្រកាសរកកូនប្រុស

នាងខ្ញុំឈ្មោះ សាន យិន អាយុ៧០ឆ្នាំ រស់នៅភូមិរកា ឃុំរកាជន្ទឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល សូមស្វែងរកកូនប្រុសច្បង ឈ្មោះ ទូន ឆាន ហៅ យឿន ដែលបានចូលបដិវត្តន៍កាលពីឆ្នាំ១៩៧៣ ហើយបាត់ខ្លួនរហូតបច្ចុប្បន្ន ។

មុនពេលចូលបដិវត្តន៍ ឆាន បួសជាសង្ឃនៅវត្តស្វាយពោធិ នៅក្នុងស្រុកកំណើត ។ បន្ទាប់មក ឆាន ធ្វើដំណើរទៅរៀនបន្តនៅវត្ត ត្នោតឫស្សីស្រុកនៅខេត្តកំពង់ចាម ។ បីឆ្នាំក្រោយ ពេលដែល ឆាន អាយុ២៥ឆ្នាំនៅឆ្នាំ១៩៧៣ ឆាន ក៏សឹកពីបួស ហើយចូលបម្រើ បដិវត្តន៍ដោយមិនប្រាប់ម្តាយឪពុកឲ្យដឹងឡើយ ។

នៅឆ្នាំ១៩៧៩ ស្ត្រី នៅក្នុងភូមិជាមួយគ្នា បានប្រាប់ខ្ញុំថា គាត់បានជួប ឆាន នៅខេត្តកំពង់ឆ្នាំង ហើយបានបបួល ឆាន ត្រឡប់ មកផ្ទះវិញ ប៉ុន្តែ ឆាន ប្រកែក ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ គ្រួសារខ្ញុំបានទទួលសំបុត្រមួយពី ឆាន ស្វែងរកក្រុមគ្រួសារនៅភូមិ កំណើត ប៉ុន្តែពេលនោះយើងទាំងអស់គ្នាមិនបានយកចិត្តទុកដាក់នឹងសំបុត្រនោះប៉ុន្មានទេ ព្រោះរវល់តែខ្វាយខ្វល់នឹងឪពុករបស់ ឆាន ដែលមានជំងឺជាទម្ងន់ ។ ក្រោយពេលធ្វើបុណ្យសពឪពុករបស់ ឆាន រួចមកសំបុត្រនោះក៏បាត់រហូត ហើយខ្ញុំក៏មិនបានទទួលដំណឹងអ្វីពី ឆាន ទៀតដែរ ។

បើកូនបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនណាបានដឹងដំណឹងអំពី ទូន ឆាន សូមមេត្តាទាក់ទងនាងខ្ញុំនៅភូមិឃុំខាងលើ ឬ ទាក់ទងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារ ០២៣ ២១០ ៣៥៨ ឬតាមរយៈប្រអប់ សំបុត្រ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកប្អូនប្រុស

នាងខ្ញុំឈ្មោះ សែម ផល អាយុ៥៩ឆ្នាំ រស់នៅភូមិថ្នល់ ឃុំដំបែរ ស្រុកដំបែរ ខេត្តកំពង់ចាម មានឪពុកឈ្មោះ ស៊ូ សែម និងម្តាយឈ្មោះ ជាម មាស ។ សព្វថ្ងៃនេះនាងខ្ញុំរស់នៅ ជាមួយបងប្អូន៤នាក់ ១)សែម យឿ ២)សែម សឿន ៣)សែម ផល ៤)សែម ស៊ុំ ។

នាងខ្ញុំសូមស្វែងរកប្អូនប្រុសឈ្មោះ ស៊ូ ដាន ។ នៅមុនឆ្នាំ ១៩៧៥ ដាន ជាយុវជនមន្ទីរតំបន់២១ ក្រោយឆ្នាំ១៩៧៥ មាននាទីជាមេពួកនៅរោងចក្រកែវ ។ កាលពីឆ្នាំ១៩៩៩ ខ្ញុំបានទទួលដំណឹងថា ដាន បានទូរស័ព្ទទៅទីរួមខេត្តកំពង់ចាម ដើម្បីស្វែងរកបងប្អូន ហើយប្រាប់ឲ្យទាក់ទងតាមមនុស្សម្នាក់នៅ ច្បារអំពៅ ។ នាងខ្ញុំព្យាយាមទាក់ទងដែរ ប៉ុន្តែមិនអាចទាក់ទង បានដោយសារតែគ្មានអាសយដ្ឋានច្បាស់លាស់ ។

ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះខាងលើឬសាមីខ្លួនបានឮ សូមទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទ លេខ ០២៣ ២១១ ៨៧៥ ទូរសារលេខ ០២៣ ២១០ ៣៥៨ ឬប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។

សូមអរគុណ ។

# សេចក្តីប្រកាសរកកូនប្រុស


ញ៉ាញ់ គូ

នាងខ្ញុំឈ្មោះ ញ៉ាញ់ គូ អាយុ៧៧ ឆ្នាំ សព្វថ្ងៃរស់នៅភូមិទំលាប់ ឃុំចាន់សែនលើ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ សូមស្វែងរកកូនប្រុសឈ្មោះ ទុន ហៅ ផល ដែលបានបាត់ខ្លួនក្រោយពេលរំដោះឆ្នាំ១៩៧៩ ។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំងឲ្យ ផល ទៅធ្វើការក្នុងកងកុមារនៅ ភូមិឪកស្រោត ។ នៅឆ្នាំ១៩៧៦ អង្គការបញ្ជាឲ្យ ផល ទៅ ឃ្វាលគោនៅឧដុង្គ ក្រោយមក ក៏ត្រូវបងស្រីដែលធ្វើការនៅ រោងចក្រភួយនៅភ្នំពេញយកទៅធ្វើការនៅមន្ទីរពេទ្យ១៧ មេសា ។ ក្រោយពេលបែកឆ្នាំ១៩៧៩ភ្លាម ផល បានត្រឡប់ មកផ្ទះវិញ ប៉ុន្តែស្នាក់នៅបានតែ៤-៥ថ្ងៃ ក៏បន្តដំណើរទៅតាម កងទ័ពខ្មែរក្រហម ហើយបាត់ខ្លួនតាំងពីពេលនោះមក ។

ប្រសិនបើសាមីខ្លួនបានឮ ឬបងប្អូនណាបានស្គាល់ឈ្មោះ ខាងលើ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទ លេខ០២៣ ២១១ ៨៧៥ ឬតាមប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកក្មួយស្រីនិងបងប្រុសជីដូនមួយ

បាត់ដំបងថ្ងៃទី៧ ខែមករា ឆ្នាំ២០០៤

ខ្ញុំសូមជម្រាបសួរលោក យិន នាន ជាទីស្រលាញ់និងជាទីគោរពរាប់អាន បងប្អូនយើងទាំងអស់ក្នុងការងារចងក្រងឯកសារ និងស្វែងរកការពិតនៅទីក្រុងភ្នំពេញប្រទេសកម្ពុជាជាទីរាប់អាននិងទីករពុក ។

ខ្ញុំបាទទទួលលិខិតឆ្លើយតបដោយមានការរៀបរាប់យ៉ាងក្បោះក្បាយនិងជាក់លាក់បំផុត ។ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះឯកឧត្តមអស់លោកដែលបានប្រឹងប្រែងប្រមែប្រមូលឯកសារនិងថែរក្សាបានយ៉ាងគង់វង្សបំផុតនោះ ។ ក្នុងលិខិតនេះ ខ្ញុំសូមអំពាវនាវចំពោះអស់លោកលោកស្រី យាយតា ពូ អ៊ំ មីងមា ណាដែលលោកបានជួបប្រទះក្មេងស្រីទាំងពីរនាក់ កូនស្រីបងខ្ញុំឈ្មោះ ឈួន ឈឿន និង ចាន់ សាយ ធ្វើការនៅអគ្គភាពរទេះភ្លើងភ្នំពេញ ត្រូវអង្គការចាប់បញ្ចូលគុកទួលស្លែង ។ កូនស្រីទីមួយឈ្មោះ ស្រី ទូច អាយុ៣ឆ្នាំកន្លះ (ឆ្នាំ១៩៧៦) កូនស្រីទីពីរឈ្មោះ ស្រី ម៉ៅ អាយុ១ឆ្នាំកន្លះ (ឆ្នាំ១៩៧៦) ។ ប្រសិនបើ វាសនាល្អគុណព្រះរតនត្រៃជួយបីបាច់ថែរក្សាបានគង់វង្សមែននោះ សូមអស់លោកលោកស្រី ពូ អ៊ំ មីងមា យាយតា ឲ្យដំណឹងទៅអ្នកទាំងពីរផងថា រាល់ថ្ងៃក្មួយខ្ញុំមានអ៊ំស្រី ពូៗ និងយាយនៅរស់រានមានជីវភាពរស់នៅធនល្មមអាចពឹងពាក់ស្នាក់អាស្រ័យបាន ។ រាល់ថ្ងៃមានជីដូន អ៊ំប្រុស មីង រស់នៅទីក្រុងបាត់ដំបង ។ នេះជាអាសយដ្ឋានៈ ផ្ទះលេខ១៦៥ ក្រុមទី១១ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ពូខ្លះៗរស់នៅទឹកដីស្រុកកំណើត គឺភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង ។ យើងខ្ញុំជាសាច់ញាតិទាំងអស់គ្រាន់តែចង់ដឹងថា ក្មួយជាសាច់ញាតិប៉ុណ្ណោះទេ យើងខ្ញុំមិនចង់បានផលប្រយោជន៍អ្វីពីក្មួយៗឡើយ គ្រាន់តែចង់ដឹងដំណឹងពិតថាក្មួយៗរស់នៅដោយមានជីវភាពយ៉ាងណា នៅឯណា ។ ចង់ប្រាប់ថា យើងមានញាតិមិត្តផៅសន្តានរស់នៅសព្វថ្ងៃ ។ បើក្មួយៗឬបងប្អូនចង់ពឹងពាក់រាល់ការងារអ្វីៗ ពូ មីង អ៊ំ និងជីដូន នឹងជួយដល់ក្មួយៗនិងចៅគ្រប់ពេលវេលា សូមក្មួយៗសង្ឃឹមជឿជាក់ចុះ ។ ខ្ញុំសង្ឃឹមថា លោកយាយ លោកតាបងប្អូនមីងមា នឹងមិនលាក់បាំងដំណឹងនេះឡើយ ។

នៅក្នុងលិខិតតូចមួយនេះ ខ្ញុំចង់សាកសួរពីដំណឹងបងជីដូនមួយរបស់ខ្ញុំម្នាក់ឈ្មោះ ដួង តារា រស់នៅភូមិស្រុកជាមួយគ្នា និងបានរៀនជាមួយគ្នាទៀត ។ ឪពុករបស់ ដួង តារា ឈ្មោះ ដួង ផាង ស្លាប់នៅឆ្នាំ១៩៦៣ ម្តាយឈ្មោះ ហែម ហ៊ន អាយុ៨៣ឆ្នាំ ស្លាប់នៅឆ្នាំ២០០៥ ។ តារា មានបងប្អូន៤នាក់ (ស្រី២នាក់) ។ ប្រសិនបើគិតមកដល់សព្វថ្ងៃ តារា មានអាយុ៤៧ឆ្នាំ ។ នៅឆ្នាំ១៩៧៦ អង្គការបានចាត់តាំងគាត់ឲ្យបើកត្រាក់ទ័រក្នុងអង្គភាពកសិកម្ម ថ្មគោល ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ខ្ញុំបាទសូមសួរលោកប្រធានសូមលោកជួយពិនិត្យមើលតើក្នុងសំណុំលិខិតខាងលើមានឈ្មោះនេះទេ ។ រាល់ថ្ងៃ ម្តាយចាស់និងប្អូនស្រីកំពុងទន្ទឹងរង់ចាំមើលផ្លូវ ។ នៅពេលរំឭកដល់ឈ្មោះ តារា គាត់តែងតែពោលសម្តីភ្ជាប់នឹងទុក្ខសោកថា កូនទៅមិនឲ្យដំណឹងម៉ែមួយម៉ាត់សោះ មិនដឹងកូនទៅនៅឯណា បាត់ឈឹងគ្មានថ្ងៃវិលត្រឡប់ ។ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ ។ **មករា**

# សេចក្តីប្រកាសរកកូនពីរនាក់

ខ្ញុំបាទឈ្មោះ ម៉ែន បូ អាយុ៧៤ឆ្នាំ និងប្រពន្ធឈ្មោះ អ៊ុយ កាន អាយុ៧៤ឆ្នាំ សព្វថ្ងៃរស់នៅភូមិឈើទាល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ យើងមានកូនទាំងអស់៧នាក់÷ ១) ម៉ែន ខេង, ២) ម៉ែន ខុម ៣) ម៉ែន រ៉ុំ ៤) ម៉ែន ឆុំ ៥) ម៉ែន ឆុន ៦) ម៉ែន ឈួង និង ៧) ម៉ែន ឈួយ ។ ខ្ញុំបាទសូមសួររកកូនពីរនាក់ឈ្មោះ ម៉ែន ខេង និង ម៉ែន ខុម ដែលបានបាត់ខ្លួនតាំងពីឆ្នាំ១៩៧៤ ។ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០០ ខ្ញុំបាទបានឮដំណឹងថាកូនទាំងពីរបានសួររកឈ្មោះខ្ញុំចំនួន៣ដង ប៉ុន្តែមិនបានជួប ។

ប្រសិនបើកូនទាំងពីរបានឮ ឬញាតិមិត្តណាបានស្គាល់ឈ្មោះទាំងពីរខាងលើ សូមមេត្តាជួយផ្តល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ។ សូមអរគុណ ។

*ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា*
*ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ៧០០០រៀល*

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 61, January 2005.**
**Funded by Germany, Norway, Sweden, and USA.**